**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃការសម្ងាត់ពាណិជ្ជកម្ម

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ដល់ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៥

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ហេម ដាវី**
**តាន់ គីមហៀក**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ម៉ូលី បញ្ញា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១១
ឆ្នាំសរសេរសារណា ២០១៥

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ**តាន់ គឹមហៀក** និង**ហេម ដាវី** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី ៤ ជំនាន់ទី ១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលើកដៃក្រាបថ្វាយបង្គំអ្នកមានគុណទាំងទ្វេគឺលោកឪពុក **តាន់ គឹមអេង** អ្នកម្តាយ **ឡៅ សូលី** និង លោកឪពុក **អ៊ុក យឹម** និង អ្នកម្តាយ **ប្រាក់ ផុក** ព្រមទាំងលោក John W. Sakash លោកស្រី Susan K. Sakash ដែលបានផ្តល់ជីវិត និងផ្តល់ការទំនុកបំរុងយ៉ាងល្អបំផុតដល់កូនទាំងផ្លូវកាយ ផ្លូវចិត្ត និងសម្ភារៈ ជាពិសេសផ្តល់ការឧបត្ថម្ភ និងលើកទឹកចិត្តឲ្យយើងខ្ញុំបានបន្តការសិក្សាបានខ្ពង់ខ្ពស់រហូតដល់សព្វថ្ងៃនេះ ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ **មូលនិធិហាប់ស្វែល** ដែលបានផ្តល់អាហារូបករណ៍ និងកន្លែងស្នាក់នៅ និងពង្រឹងសមត្ថភាពអោយក្លាយជាអ្នកដឹកនាំដល់រូបយើងខ្ញុំ។

លើសពីនេះទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំគ្រប់ឋានានុក្រម នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមមាន ឯកឧត្តមសកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យទាំងអស់ ដែលបានគ្រប់គ្រង ដឹកនាំ និងផ្តល់នូវចំណេះវិជ្ជាដ៏មានតម្លៃ និងគុណភាពដែលជាទុនមួយដ៏មានតម្លៃសម្រាប់យកទៅប្រើប្រាស់ និងបំពេញតម្រូវការសង្គម។

យើងខ្ញុំសូមថ្លែងអំណរគុណដោយឡែក ជូនចំពោះអ្នកគ្រូ **ប៉ូលី បញ្ញា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ យល់ព្រមទទួលធ្វើជាលោកគ្រូដឹកនាំសារណារបស់យើងខ្ញុំ។ អ្នកគ្រូ បានផ្តួចផ្តើមគំនិត និងបង្ហាញប្រាប់យើងខ្ញុំអំពីចំនុចខ្លាំង និងចំនុចខ្សោយនៃសារណាទាំងមូល ក្នុងគោលបំណងដើម្បីធ្វើឲ្យប្រាកដថា យើងខ្ញុំពិតជាបានសរសេរសារណាមួយ ប្រកបទៅដោយខ្លឹមសារ ត្រូវតាមក្បួនខ្នាតសិក្សា និងអាចរក្សាទុកជាផលប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកគ្រូ **ស៊ឹម សុខហេង** និងលោកគ្រូ **ឃឹម គីរី** ដែលបានផ្តល់ជាឯកសារ និងដំបូន្មានដ៏មានសារៈសំខាន់លើអត្ថបទមួយនេះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ ដល់លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ដែលបានចូលរួមចំណែកឲ្យសារណាបញ្ចប់ការសិក្សាស្តីពី **របបគតិយុត្តនៃការសម្ងាត់ពាណិជ្ជកម្ម** ឲ្យបានលេចចេញជារូបរាងឡើង ឲ្យមានសុខភាពល្អ មានសុភមង្គល និងមានអាយុយឺនយូរគ្រប់ៗ រូប។

# អារម្ភកថា

ការសម្ងាត់ពាណិជ្ជកម្មគឺ ច្បាប់ដែលមានលក្ខណៈថ្មី ហើយក៏អាចចាត់ថាមានលក្ខណៈចាស់ផងដែរ ព្រោះថាជាក់ស្តែងច្បាប់នេះត្រូវបានទទួលស្គាល់ ហើយថែមទាំងត្រូវបានអនុវត្តនៅក្នុងប្រទេសជាច្រើននៅក្នុងសាកលលោក ស្របពេលជាមួយគ្នានេះ វាមិនទាន់ត្រូវបានអនុវត្តនៅក្នុងបណ្តាប្រទេសមួយចំនួនតូចផងដែរ។ ដូច្នេះហើយ ការសិក្សាពីការសម្ងាត់ពាណិជ្ជកម្មមិនគួរមានការមើលរំលងនោះទេ ព្រោះវាបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើន។ ក្នុងការពិភាក្សាពីគោលដៅផ្តល់ប្រយោជន៍ដល់កិច្ចការពារកម្មសិទ្ធិបញ្ញា គឺមានគោលបំណងលើកទឹកចិត្តដល់ការធ្វើវិនិយោគ។ គ្មានក្រុមហ៊ុនណាមួយហ៊ានប្រថុយរកស៊ីទេ ប្រសិនបើគ្មានកម្មសិទ្ធិបញ្ញានោះ ហើយដូច្នេះ កម្ពុជាត្រូវការពារកម្មសិទ្ធិបញ្ញា ប្រសិនបើកម្ពុជា មានបំណងទាញប្រយោជន៍ពីសេរីភាវូបនីយកម្មនៅក្នុងលំហូរពាណិជ្ជកម្ម និងវិនិយោគឲ្យបានពេញលេញ។ ជាពិសេស ចំពោះផលិតផលឱសថដែលទាមទារឲ្យមានការអនុញ្ញាតដើម្បីដាក់លក់នៅលើទីផ្សារ។ ដូចនេះហើយយើងឃើញថា វាគ្មានអ្វីចម្លែកនោះទេ ដែលរបបគតិយុត្តនៃការសម្ងាត់ពាណិជ្ជកម្ម ត្រូវបានទទួលស្គាល់ និងយកមកអនុវត្តក្នុងបណ្តាប្រទេសមួយចំនួនធំនោះ។ ជាក់ស្តែងដូចកម្ពុជាផងដែរ គួរតែមាននូវរបបគតិយុត្តនេះ កាន់តែឆាប់កាន់តែល្អ ដោយហេតុថា វាក៏ជាផ្នែកមួយក្នុងការជួយជំរុញ វិស័យសេដ្ឋកិច្ចផងដែរ។

ដូចនេះហើយ ក្នុងរបាយការណ៍សារណានេះ យើងបានលើកយកនូវរបបគតិយុត្តនៃការសម្ងាត់ពាណិជ្ជកម្មនេះ មកសិក្សាដើម្បីឲ្យជាប្រយោជន៍ដល់អ្នកដែលមានបំណងចង់ជ្រួតជ្រាបបន្ថែមទៀត ក៏ដូចជាអ្នកដែលមិនទាន់បានដឹងពីវាសោះពីមុនមក។

ក្នុងរបាយការណ៍សារណានេះ យើងខ្ញុំបានលើកយកមកបកស្រាយជាសាកល ពោលគឺច្បាប់រួម គឺអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលហៅកាត់ជាភាសាអង្គគ្លេសថា (WIPO: World Intellectual Property Organization) និងច្បាប់នៅបណ្តាប្រទេសមួយចំនួនដែលបានកំពុងតែអនុវត្តនូវច្បាប់នេះ និងប្រទេសដែលមិនទាន់ទទួលយកវាមកអនុវត្តផងដែរ ហើយយើងក៏បានលើកមកបកស្រាយពីប្រទេសយើងផ្ទាល់ ដែលយើងពុំទាន់បានទទួលស្គាល់វាពេញលេញនៅឡើយទេ ស្របពេលដែលយើងបានដឹងពីអត្ថប្រយោជន៍យ៉ាងធំពីវាហើយនោះ។ ទោះបីជាយើងនេះក្តី ប្រទេសកម្ពុជាកំពុងតែធ្វើនូវសេចក្តីព្រាងច្បាប់ស្តីពីការការពារការសម្ងាត់ពាណិជ្ជកម្មនេះ ដោយមានការធ្វើសេចក្តីព្រាងយ៉ាងល្អិតល្អន់ ដោយមានការសិក្សាទទួលយកពីបណ្តាប្រទេសជិតខាងដែលមានការអនុវត្តវា។

សរុបមក ខាងក្រោមនេះគឺជាខ្លឹមសាររបាយការណ៍សារណាដែលក្រុមយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងវាឡើងជាអត្ថបទ។

# មាតិកា

ទំព័រ

**សេចក្ដីថ្លែងអំណរគុណ**
**អារម្ភកថា**
**សេចក្ដីផ្ដើម** ........................................................................ ០១

## ជំពូកទី១៖
## សញ្ញាណទូទៅ នៃការបង្កើតវិធានការការពារការសម្ងាត់ពាណិជ្ជកម្ម

**ផ្នែកទី១៖ តើអ្វីទៅជាការសម្ងាត់ពាណិជ្ជកម្ម? និង ព័ត៌មានពាណិជ្ជកម្ម**..................... ០៤
**កថាខណ្ឌទី១៖ ព័ត៌មានដែលត្រូវបានទទួលការការពារ** ........................................ ០៥
**កថាខណ្ឌទី២៖ ធាតុផ្សំនៃការសម្ងាត់ពាណិជ្ជកម្ម១០**
វាក្យខ័ណ្ឌទី១៖ ធាតុផ្សំសំខាន់នៃ ភាពសម្ងាត់ ........................................................ ១០
វាក្យខ័ណ្ឌទី២៖ តម្លៃខាងពាណិជ្ជកម្ម ..................................................................... ១៣

**ផ្នែកទី២៖ លក្ខខណ្ឌនៃការកំណត់សម្គាល់ការសម្ងាត់ពាណិជ្ជកម្ម**............................... ១៤
**កថាខណ្ឌទី១៖ អត្ថន័យនៃមាត្រា ៣៩(១) និងមាត្រា ៣៩(២) នៃកិច្ចព្រមព្រៀង TRIPS** ........................................................................ ១៤
**កថាខណ្ឌទី២៖ អត្ថន័យនៃសេចក្ដីព្រាងច្បាប់ស្ដីពី ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម** ........................................................................
វាក្យខ័ណ្ឌទី១៖ ព័ត៌មានសម្ងាត់ សម្រាប់វិញ្ញាបនបត្រអនុញ្ញាតឲ្យចែកចាយ លក់ផលិតផលឪសថ និងផលិតផលគីមីសកម្ម........................................................ ១៧
វាក្យខ័ណ្ឌទី២៖ សេចក្ដីប្រកាសនៅទីក្រុង ដូហា ស្ដីពីសុខភាពសាធារណៈ: ..................... ១៩
វាក្យខ័ណ្ឌទី៣៖ អនុក្រឹត្យស្ដីពី ការសម្ងាត់ពាណិជ្ជកម្ម ................................................ ២៧

## ជំពូកទី២៖
## ទម្រង់នៃការការពារការសម្ងាត់ពាណិជ្ជកម្ម

**ផ្នែកទី១៖ ទម្រង់នៃការការពារការសម្ងាត់ពាណិជ្ជកម្មក្រោមក្របខ័ណ្ឌអន្តរជាតិ**....... ២៨
**កថាខណ្ឌទី១៖ ទម្រង់នៃការការពារការនៅក្រោមក្របខ័ណ្ឌសហគមន៍អឺរ៉ុប** ......... ២៨
**កថាខណ្ឌទី២៖ ទម្រង់នៃការការពារការនៅក្រោមក្របខ័ណ្ឌសហរដ្ឋអាមេរិក**....... ៣០

វាក្យខ័ណ្ឌទី១៖ គោលនយោបាយសាធារណៈរបស់សហរដ្ឋអាមេរិក ............................ ៣០
វាក្យខ័ណ្ឌទី២៖ ការការពារការសម្ងាត់ពាណិជ្ជកម្មប្រឆាំងនឹងការផ្សព្វផ្សាយដោយអ្នកគ្មានសមត្ថកិច្ចនៃភ្នាក់ងាររដ្ឋាភិបាលរបស់សហរដ្ឋអាមេរិក ......................... ៣១

**ផ្នែកទី២៖ ទម្រង់នៃការការពារការការសម្ងាត់ពាណិជ្ជកម្មនៅកម្ពុជា** ......................... ៣៣
**កថាខណ្ឌទី១៖ ការការពារដោយមិនការបើកចំហរ** ............................................ ៣៣
**កថាខណ្ឌទី២៖ ការការពារពីការប្រើប្រាស់មិនស្មោះត្រង់ខាងពាណិជ្ជកម្ម** ............... ៣៤

## ជំពូកទី៣៖
## ទំនួលខុសត្រូវចំពោះការបំពានលើការសម្ងាត់ពាណិជ្ជកម្ម

**ផ្នែកទី១៖ ការបំពានលើការសម្ងាត់ពាណិជ្ជកម្ម (តើស្ថានភាពណាខ្លះ ឬសកម្មភាពណាខ្លះ ដែលចាត់ទុកថាជាការបំពាន?)** ............................................. ៤០
**កថាខណ្ឌទី១៖ ការទទួលបានព័ត៌មានមិនស្របច្បាប់** ........................................ ៤០
**កថាខណ្ឌទី២៖ ការប្រើប្រាស់ ឬការបង្ហើបបង្ហាញព័ត៌មានមិនស្របច្បាប់** .............. ៤០

**ផ្នែកទី២៖ ប្រភេទនៃការទទួលខុសត្រូវការបំពានការសម្ងាត់ពាណិជ្ជកម្ម** ................. ៤១
**កថាខណ្ឌទី១៖ ប្រភេទនៃការទទួលខុសត្រូវក្រោមក្របខ័ណ្ឌអន្តរជាតិ** .................. ៤១
វាក្យខ័ណ្ឌទី១៖ ការទទួលខុសត្រូវក្រោមក្របខណ្ឌសហគមន៍អ៊ឺរ៉ុប .............................. ៤១
វាក្យខ័ណ្ឌទី២៖ ការទទួលខុសត្រូវក្រោមក្របខ័ណ្ឌអាមេរិក ........................................ ៤២
**កថាខណ្ឌទី២៖ ប្រភេទនៃការទទួលខុសត្រូវក្រោមក្របខ័ណ្ឌជាតិ (កម្ពុជា)** ......... ៤៣
វាក្យខ័ណ្ឌទី១៖ សំណងការខូចខាត ........................................................................ ៤៣
វាក្យខ័ណ្ឌទី២៖ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ...................................................... ៤៣

**ផ្នែកទី៣៖ នីតិវិធីនៃការដោះស្រាយវិវាទ** ............................................................ ៤៤
**កថាខណ្ឌទី១៖ ដំណោះស្រាយក្នុងប្រព័ន្ធតុលាការ** ............................................... ៤៤
វាក្យខ័ណ្ឌទី១៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ........................................... ៤៤
វាក្យខ័ណ្ឌទី២៖ ដីកាសម្រេចបណ្ដោះអាសន្ន .............................................................. ៤៥
**កថាខណ្ឌទី២៖ ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ** ............................................ ៤៥
វាក្យខ័ណ្ឌទី១៖ ដំណោះស្រាយតាមការផ្សះផ្សារ ឬការសម្រុះសម្រួល .......................... ៤៦
វាក្យខ័ណ្ឌទី២៖ ដំណោះស្រាយតាមមជ្ឈត្តការ ............................................................ ៤៦

**សេចក្ដីសន្និដ្ឋាន** ........................................................................................... ៤៨
**អនុសាសន៍** ................................................................................................. ៥១

## គន្លនិទ្ទេស
## ឧបសម្ព័ន្ធ

# ពាក្យសរសេរកាត់ (Abbreviation)

| | |
|---|---|
| WIPO | World Intellectual Property Organization |
| TRIPS | Trade-Related Aspects of Intellectual Property Rights |
| TRIPS-Plus | Trade-Related Aspects of Intellectual Property Right Plus |
| WTO | World Trade Organization |
| NAFTA | North American Free Trade Agreement |
| FOIA | Freedom of Information Act |
| NSPA | National Stolen Property Act |
| MWFS | Mail and Wire Fraud Statutes |
| RICO | Racketeer Influenced and Corrupt Organizations Act |

# សេចក្ដីផ្ដើម

បច្ចុប្បន្ន ដោយសារតែបច្ចេកវិទ្យាមានការជឿនលឿន វិស័យពាណិជ្ជកម្ម និងជំនួញមានការកើនឡើង វាជាហេតុនាំឲ្យមាននូវការការពារនូវសិទ្ធិស្ដីពីកម្មសិទ្ធិបញ្ញា។ ដោយហេតុនេះហើយ បទប្បញ្ញត្តិស្ដីពីកម្មសិទ្ធិបញ្ញាត្រូវបានរៀបរៀងចងក្រងឡើងជាច្បាប់ផ្សេងៗ ដើម្បីអនុវត្តក្នុងបណ្ដាប្រទេសជាច្រើននៅលើសកលលោក។ ជាក់ស្ដែង ដូចជាច្បាប់ស្ដីពី សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ក៏ដូចជាច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។ បន្ថែមពីលើនេះទៅទៀត ដើម្បីទទួលបាននូវការការពារប្រកាសនីយបត្រតក្កកម្ម គឺត្រូវតែថ្មី គ្មានការលួចចម្លងស្នាដៃអ្នកដទៃ ហើយអាចប្រើប្រាស់បានក្នុងវិស័យឧស្សាហកម្ម។ ចំនុចដូចដែលបានរៀបរាប់ខាងលើ គឺជាចំនុចដែលបណ្ដាប្រទេសជាច្រើនទទួលស្គាល់ ហើយយកទៅអនុវត្តក្នុងបណ្ដាប្រទេសពួកគេដោយប្រែប្រួលទៅតាមបរិបទនៃរបបនយោបាយ និងការវិវត្តន៍ផ្នែកសេដ្ឋកិច្ចរៀងៗខ្លួន។

ទោះបីជាយ៉ាងនេះក្ដី ប្រព័ន្ធយុត្តាធិការនៃបណ្ដាប្រទេសនីមួយៗមានភាពខុសគ្នា និងកំណត់អំពីលក្ខខណ្ឌរួម និងលក្ខខណ្ឌដោយឡែក ទៅតាមទំហំនៃការការពារកម្មសិទ្ធិបញ្ញានៅក្នុងបណ្ដាប្រទេសទាំងនោះ។ ឧទាហរណ៍ ដូចជានៅសហរដ្ឋអាមេរិក កាណាដា និងសហភាពអឺរ៉ុប ប្រកាសនីយបត្រតក្កកម្មត្រូវបានការពារនៅក្នុងច្បាប់ផ្សេងទៀត។

ជាទូទៅ ក្រោមច្បាប់ស្ដីពី ប្រកាសនីយបត្រតក្កកម្មបានចែងពី ការបង្កើតថ្មី ឧទាហរណ៍ តក្កករម្នាក់បានបង្កើតឡើងនូវអ្វីថ្មីមួយដែលមិនធ្លាប់មានពីមុន ហើយអាចប្រើប្រាស់បានក្នុងវិស័យឧស្សាហកម្ម គឺនាំឲ្យបុគ្គលនោះទទួលបាននូវសិទ្ធិផ្ដាច់មុខចំពោះការបង្កើតថ្មីនោះ ដែលសិទ្ធិនេះគឺរារាំងអ្នកដទៃក្នុងការប្រើប្រាស់តក្កកម្មថ្មីនោះដោយគ្មានការអនុញ្ញាតពីតក្កករ។ ផ្ទុយមកវិញ វាទាមទារឲ្យតក្កករ យល់ព្រមក្នុងការផ្សព្វផ្សាយជាសាធារណៈ នៅពេលដែលតក្កកម្មត្រូវបានផុតអាជ្ញាយុកាលនៃការការពារ។ ទោះបីជាយ៉ាងណាក៏ដោយ លោក Binnie J. បកស្រាយទៅលើ Harvard College v. Canada (Commissioner of Patents) "បុគ្គលដែលប៉ិនប្រសប់ តែងតែលាក់បាំង និងលាក់ទុកនូវអ្វីដែលពួកគេបានខិតខំប្រឹងប្រែងរកឃើញ ជាជាងបង្ហាញវាឲ្យទៅអ្នកដទៃបានដឹងហើយលួចបង្កើតវាឡើងនោះទេ" ("ingenious people may tend to hide and hoard the products of their ingenuity rather than disclose them for others to build on that knowledge")[2]។

ដោយហេតុនេះហើយ ក្នុងករណីដែលតក្កករ បដិសេធមិនធ្វើការផ្សព្វផ្សាយនូវតក្កកម្មរបស់ខ្លួន ការការពារការសម្ងាត់ពាណិជ្ជកម្ម គឺត្រូវបានដើរតួជំនួសឲ្យការការពារប្រកាសនីយបត្រតក្កកម្ម។ ការការពារការសម្ងាត់ពាណិជ្ជកម្ម គឺជាមធ្យោបាយមួយផ្សេងទៀត ដើម្បីធ្វើការការពារនូវ

[2] Hardvard College V. Canada, *Commissioner of Patents*, [2002] 4 S.C.R 45 at s. 3.

ប្រកាសនីយបត្រតក្កកម្មណាដែលលែងទទួលបានការពារក្រោមច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម។ ដោយសារមើលឃើញពីចំនុចនេះហើយ សាស្ត្រាចារ្យ Andrew Beckerman-Rodau បានលើកឡើងថា ច្បាប់ស្តីពី ការសម្ងាត់ពាណិជ្ជកម្ម មានសក្តានុពលការពារស្ទើតែគ្រប់រាល់ការសម្ងាត់ទាំងអស់ ដែលមិនអោយមនុស្សទូទៅដឹងពីការសម្ងាត់ទាំងនោះ ហើយដែលវាមានផលប្រយោជន៍ចំពោះការប្រកួតប្រជែងនៅក្នុងជីវភាពកិច្ចកិច្ចការជំនួញ[3]។ ទាំងអស់នេះ ជាគ្រឿងលើកទឹកចិត្តមួយទៀតចំពោះអ្នករកឃើញនូវអ្វីមួយដែលថ្មី ដែលមិនធ្លាប់មានពីមុនមក (តក្ករ) គឺច្បាប់ស្តីពីការការពារសម្ងាត់ពាណិជ្ជកម្ម មានការការពារជារៀងរហូតទៅលើស្នាដៃទាំងនោះ ស្របពេលដែលច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្មមានការការពារត្រឹមតែ ២០ ឆ្នាំតែប៉ុណ្ណោះ។

ជាហេតុផលមួយទៀតផងដែរ ចំពោះគោលគំនិតនៃការការពារការសម្ងាត់ពាណិជ្ជកម្ម គឺសំដៅទៅលើព័ត៌មាន ឬបច្ចេកវិទ្យាដែលថ្មីទាំងឡាយណាដែល៖ (ក) អាចប្រើប្រាស់បានដោយមិនចាំបាច់បង្ហាញទៅឲ្យអ្នកក្រៅបានដឹង (ខ) វាមិនងាយនឹងអាចរកឃើញបានដោយឯករាជ្យ ឬបដិសេធចោលដោយអ្នកជំនាញ (គ) អាចរក្សាការសម្ងាត់បានដោយពឹងលើវិធានដែលអាចធ្វើទៅបាន។

ការបង្កើតច្បាប់ស្តីពី ការការពារសម្ងាត់ពាណិជ្ជកម្ម បានឆ្លុះបញ្ចាំងឲ្យឃើញពីការរីកចម្រើននៃព័ត៌មាន និងប្រព័ន្ធបច្ចេកវិទ្យាថ្មី នៅក្នុងវិស័យពាណិជ្ជកម្ម និងជំនួញ។ ក្រុមហ៊ុននានា ចាប់ផ្តើមពឹងផ្អែកទៅលើបច្ចេកវិទ្យាដែលកើតចេញពីព័ត៌មាន (ព័ត៌មានសម្ងាត់) ពួកគេចាប់ផ្តើមដឹងពីអត្ថប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច ដែលកើតចេញមកពីការរក្សានូវព័ត៌មានជាសម្ងាត់នេះ។

ការការពារការសម្ងាត់ពាណិជ្ជកម្មនៅក្នុងក្របខណ្ឌអន្តរជាតិ គឺវាមានទំនាក់ទំនង នឹងការអភិវឌ្ឍន៍នាពេលបច្ចុប្បន្ន ទាំងកិច្ចព្រមព្រាងពាណិជ្ជកម្មសេរីនៃអាមេរិកខាងជើង (North American Free Trade Agreement also referred to as "NAFTA") និងទាំងកិច្ចព្រមព្រាងពាណិជ្ជកម្មទាក់ទងទៅនឹងសិទ្ធិនៃកម្មសិទ្ធិបញ្ញា (Agreement on Trade Related Aspects of Intellectual Property Rights also referred to as "TRIPS") ដែលជាមូលហេតុនាំឲ្យការសម្ងាត់ពាណិជ្ជកម្ម ត្រូវបានបង្កើតឡើងជាច្បាប់អនុវត្តនៅក្នុងប្រទេសនីមួយៗ។

នៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៃអាមេរិកខាងជើង (NAFTA) គឺមានចែងយ៉ាងច្បាស់អំពីកិច្ចការពារការសម្ងាត់ពាណិជ្ជកម្ម ស្របពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មទាក់ទងទៅនឹងសិទ្ធិនៃកម្មសិទ្ធិបញ្ញា (TRIPS) បានប្រើប្រាស់ពាក្យ "ព័ត៌មានសម្ងាត់" ជំនួសវិញ។ ភាពខុសប្លែកគ្នា នៃការប្រើប្រាស់ពាក្យនេះ អាចបណ្តាលមកពីអ្នកចរចារបស់សហរដ្ឋអាមេរិក បានទទួលឥទ្ធិពលពីពាក្យ ដែលប្រើប្រាស់នៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី នៃអាមេរិកខាងជើង

[3] Andrew Beckerman-Rodau, "*The Choice Between Patent Protection and Trade Secret Protection: A Legal And Business Decision*" (2002) 84 J.Pat.&Trademark Off. Soc'y at 379.

(NAFTA) ។ ដូចនេះហើយ ពួកគេក៏មានបំណងចង់ប្រើប្រាស់ពាក្យដែលមានក្នុង NAFTA ទៅដាក់ក្នុងបរិបទច្បាប់សហរដ្ឋអាមេរិកគឺ ការការពារព័ត៌មានសម្ងាត់ដែលមាន ចែងនៅក្នុង TRIPS។

ដូចនេះ បញ្ហាគតិយុត្តដែលលើយកមកធ្វើការសិក្សាស្រាវជ្រាវនៅក្នុងសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំបានផ្តោតសំខាន់នូវ បី ជំពូកធំៗ រួមមាន **សញ្ញាណទូទៅនៃការបង្កើតវិធានការណ៍ការពារការសម្ងាត់ពាណិជ្ជកម្ម** ជាជំពូកទី ១ ដែលក្នុងនោះបានធ្វើការបែងចែកជាពីរ ផ្នែក គឺការបកស្រាយទៅលើចំណោទសំនួរ (ផ្នែកទី ១) ថាតើអ្វីទៅជាការសម្ងាត់ពាណិជ្ជកម្ម? និងព័ត៌មានពាណិជ្ជកម្ម? និង (ផ្នែកទី ២) លក្ខខណ្ឌនៃការកំណត់សម្គាល់ការសម្ងាត់ពាណិជ្ជកម្ម។ ឯជំពូកទី ២ វិញគឺ បកស្រាយពី **ទម្រង់នៃការការពារការសម្ងាត់ពាណិជ្ជកម្ម** ដែលក្នុងនោះបែងចែកជាពីរ ផ្នែក គឺទម្រង់នៃការការពារការសម្ងាត់ពាណិជ្ជកម្មក្រោមក្របខណ្ឌអន្តរជាតិ (ផ្នែកទី ១) និងទម្រង់នៃការការពារការសម្ងាត់ពាណិជ្ជកម្មនៅកម្ពុជា (ផ្នែកទី ៣)។ នឹងជាចុងក្រោយជំពូកទី៣ គឺ **ទំនួលខុសត្រូវចំពោះការបំពានការសម្ងាត់ពាណិជ្ជកម្ម** ដែលធ្វើការបែងចែកជាបី ផ្នែក រួមមាន ការបំពានលើការសម្ងាត់ពាណិជ្ជកម្ម (ផ្នែកទី ១) ប្រភេទនៃការទទួលខុសត្រូវ (ផ្នែកទី ២) និងនីតិវិធីនៃការដោះស្រាយវិវាទ (ផ្នែកទី ៣)។

# ជំពូកទី១៖ សញ្ញាណទូទៅនៃការបង្កើតវិធានការការពារការសម្ងាត់ពាណិជ្ជកម្ម

## ផ្នែកទី១៖ តើអ្វីទៅជាការសម្ងាត់ពាណិជ្ជកម្ម? និង ព័ត៌មានពាណិជ្ជកម្ម?

ការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានពាណិជ្ជកម្ម ត្រូវបានគេចាត់ទុកថាជាពាក្យតែមួយ ឬមានន័យថា វាមានន័យដូចគ្នា។ ការប្រើប្រាស់ពាក្យខុសគ្នានេះ គឺទៅតាមប្រទេសនីមួយៗ ដោយហេតុថា ប្រទេសមួយចំនួនមិនចង់យកពាក្យពីប្រទេសដទៃ ទើបព្យាយាមប្រើប្រាស់ពាក្យផ្សេងជំនួស ក៏ប៉ុន្តែអត្ថន័យគឺនៅតែដូចគ្នាដដែល។

យោងតាមមាត្រា៨ នៃច្បាប់ស្តីពី ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម "**ការសម្ងាត់ពាណិជ្ជកម្ម**" គឺជាព័ត៌មានដែល៖

ក. សម្ងាត់នៅក្នុងន័យថា នៅក្នុងទម្រង់ទាំងមូល ឬជារូបសណ្ឋានជាក់លាក់ និងបង្គុំសមាសភាពរបស់វា គេមិនទាន់បានដឹងស្គាល់ជាទូទៅក្នុងចំណោម ឬមិនងាយនឹងអាចធ្លាយឲ្យដឹងឮដល់បុគ្គលដែល ស្ថិតនៅក្នុងជួរក្រុម ដែលជាធម្មតាទាក់ទិនទៅនឹងប្រភេទនៃព័ត៌មានបែបនេះ។

ខ. មានតម្លៃពាណិជ្ជកម្មពិតប្រាកដ ឬតម្លៃពាណិជ្ជកម្មជាសក្តានុពល ដោយសារតែភាពជាសម្ងាត់របស់វា និង

គ. ជាកម្មវត្ថុនៃជំហាននៃការរក្សាជាសម្ងាត់ដ៏សមស្របទៅតាមស្ថានភាពដោយបុគ្គលដែលមានសិទ្ធិគ្រប់គ្រងពត៌មាននោះដោយស្របច្បាប់។

"**ព័ត៌មាន**" សម្រាប់គោលបំណងនៃការឲ្យនិយមន័យនៃការសម្ងាត់ពាណិជ្ជកម្ម "**ព័ត៌មាន**" រួមមានព័ត៌មានដែលបង្កើតបានជា ឬមាននៅក្នុង ឬរួមបញ្ចូលជា (ប៉ុន្តែមិនកម្រិតតែចំពោះ) រូបមន្តគំរូ ផែនការ ឬផែនការ ផលិតផល ការព្យាករណ៍ទីផ្សារ យុទ្ធសាស្រ្ត បញ្ជីអតិថិជន ទិន្នន័យគណនីលក់ គិតទាំងបរិមាណលក់ របាយការណ៍ហិរញ្ញវត្ថុ បញ្ជីគណនេយ្យ ការចងក្រងអ្វីមួយ វិធីសាស្រ្តបច្ចេកទេស ដំណើរការផលិត ផលិតផល កម្មវិធីកុំព្យូទ័រ មធ្យោបាយ ឬយន្តការជាបច្ចេកទេស ឬមិនមែនបច្ចេកទេស ឬទិន្នន័យថ្លៃដើម ឬគំនូសបង្ហាញ ឬវិធីសាស្រ្តអាជីវកម្ម និងប្រភពផ្គត់ផ្គង់វត្ថុធាតុដើម។

"**បុគ្គល**" មានន័យថា រូបវន្តបុគ្គល ក្រុមហ៊ុន អាជីវកម្មទទួលភារៈគ្រប់គ្រង ក្រុមហ៊ុនជួញដូរដីធ្លី អង្គការ អាណត្តិ ក្រុមហ៊ុនសហកម្មសិទ្ធិ សមាគមន៍ ក្រុមហ៊ុនរួមទុន រដ្ឋាភិបាល ភ្នាក់ងារ ឬស្ថាប័នរដ្ឋាភិបាល ឬនីតិបុគ្គល ឬក្រុមហ៊ុនពាណិជ្ជកម្មផ្សេងទៀត។

គេមិនអាចបង្កើតបញ្ជីមួយដើម្បីកំណត់នូវអ្វីដែលជាធាតុផ្សំនៃ **លក្ខណៈផ្ទុយទៅនឹងការអនុវត្តន៍មិនស្មោះត្រង់ខាងពាណិជ្ជកម្ម** បានទេ។ ច្បាប់ដែលត្រូវបានស្នើសុំនេះ បានទទួលយកនូវនិយមន័យដែលបានកំណត់ នៅក្នុងមាត្រា៣៩(២) នៃកិច្ចព្រមព្រៀង TRIPS ដោយមានការបន្ថែមខ្លះទៀត។ ការប្រើប្រាស់ពាក្យថា **មធ្យោបាយផ្សេងៗ** បញ្ជាក់ឲ្យឃើញថា និយមន័យនេះមាន

លក្ខណៈបើកទូលាយ។ ពាក្យ **មធ្យោបាយផ្សេងៗ** នេះរួមមាន ការលួច ការបន្លំ ការស៊ីសំណូក ការដាក់បង្ហាញខុស និងការស្ដាប់ការសន្ទនាដោយគ្មានការអនុញ្ញាត។ និយមន័យនេះគ្របដណ្ដប់ផងដែរទៅលើ ស្ថានភាពរបស់អ្នកទទួលបាន ដោយមិនមានចេតនាទុច្ចរិតដែលជាតតិយជន។

និយមន័យនៃពាក្យ **ការសម្ងាត់ពាណិជ្ជកម្ម** ត្រូវបានផ្ដល់ឲ្យផងដែរនៅក្នុងមាត្រា ៣៩ (៣)(២) នៃកិច្ចព្រមព្រៀង TRIPS ។ ការសម្ងាត់ពាណិជ្ជកម្មជាប់ពាក់ព័ន្ធជាមួយ នឹងកម្មវត្ថុផ្សេងៗគ្នា ឧទាហរណ៍ ការសម្ងាត់លើផលិតផលណាមួយជាក់លាក់ដូចជា រូបមន្តធាតុគីមី ការសម្ងាត់ខាងបច្ចេកវិទ្យាដូចជា ចំណេះដឹងដែលមិនទាន់មាននរណាម្នាក់ផ្សេងទៀតបានបង្កើតនៅឡើយ និងការសម្ងាត់យុទ្ធសាស្ត្រពាណិជ្ជកម្មដូចជា បញ្ជីអតិថិជន ព័ត៌មានទីផ្សារ ការចងក្រងព័ត៌មានទៅតាមឯកទេស ឬចំណេះធ្វើ។ ប៉ុន្តែ ដើម្បីធ្វើឲ្យឃើញនូវភាពផ្ដាច់មុខ និងភាពច្បាស់លាស់ជាងនេះទៅទៀតនោះ និយមន័យនៃពាក្យ **ព័ត៌មាន** ក៏ត្រូវបានកំណត់ផងដែរ។ ប៉ុន្តែ និយមន័យបែបនេះមានន័យទូលាយណាស់ ដែលជាហេតុបណ្ដាលឲ្យមានការដាក់បន្ថែមនូវព័ត៌មានថ្មីៗជាច្រើនទៀតនាពេលអនាគត។ ចំពោះការសម្ងាត់វិញ គេអាចយល់បានថា ដើម្បីបង្កើតការសម្ងាត់ពាណិជ្ជកម្មមួយ ដែលនឹងផ្ដល់ផលប្រយោជន៍ប្រកួតប្រជែងខាងផលិតផល ឬខាងសេវាកម្មលើអ្នកប្រកួតប្រជែងម្នាក់ផ្សេងទៀត វាតែងតែតម្រូវឲ្យមានការវិនិយោគធំមួយ ដែលការវិនិយោគនេះនឹងត្រូវបាត់បង់ ប្រសិនបើការសម្ងាត់នេះត្រូវគេបានដឹងជាសាធារណៈ។

ពាក្យថា **បុគ្គល** សំដៅទៅលើក្រុមហ៊ុនស្របច្បាប់ផ្សេងៗ ដែលក្រុមហ៊ុនមួយចំនួនអាចមិនមាននៅកម្ពុជាទេ។ ប៉ុន្តែ ចាប់តាំងពីក្រុមហ៊ុនទាំងនេះ ក្លាយជាបុគ្គលដែលមានសិទ្ធិកាន់កាប់លើការសម្ងាត់ពាណិជ្ជកម្មពេញច្បាប់ ឬក្លាយជាបុគ្គលដែលបានបំពេញតាមលក្ខខណ្ឌពេញច្បាប់ ក្រុមហ៊ុនទាំងនោះអាចត្រូវបានចុះបញ្ជី។ គ្រប់រដ្ឋាភិបាល និងក្រសួង មន្ទីររបស់ខ្លួន ក៏ត្រូវចុះបញ្ជីដែរ ដោយរួមទាំងរដ្ឋាភិបាលប្រទេសកម្ពុជាផងដែរ និងក្រសួង មន្ទីររបស់រដ្ឋាភិបាលផង។ បើទោះជាមាត្រា ៣ នៃផ្នែកទី១ នៃសេចក្ដីណែនាំការអនុវត្តន៍កិច្ចព្រមព្រៀង TRIPS របស់អង្គការពាណិជ្ជកម្មពិភពលោក បានផ្ដល់យោបល់ថា ស្ថាប័នខាងលើនេះគួរតែទទួលបានអភ័យឯកសិទ្ធិនៃយុត្តាធិការនេះក៏ដោយ ក៏វាហាក់បីដូចជាមិនមានសារៈសំខាន់សោះ នៅក្នុងរឿងកិច្ចការពារការសម្ងាត់ពាណិជ្ជកម្ម ព្រោះរឿងក្ដីភាគីច្រើនកន្លងមក ក៏មានភាគីឯកជនពាក់ព័ន្ធទៅនឹងជម្លោះ ដែលកើតមានឡើងពីការទទួលបានដោយខុសច្បាប់ ការបង្ហើបបង្ហាញ ឬការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្មដោយខុសច្បាប់ (ពីសំណាក់រដ្ឋ)។

### កថាខណ្ឌទី១៖ ព័ត៌មានដែលត្រូវបានទទួលការការពារ

វាពុំមានការទទួលស្គាល់ជាសកលនូវនិយមន័យនៃពាក្យ **ការសម្ងាត់ពាណិជ្ជកម្ម** ទេ។ តាមពិតទៅ វាមានភាពខុសគ្នាគួរឲ្យកត់សម្គាល់ចំពោះនិយមន័យ **ការសម្ងាត់ពាណិជ្ជកម្ម** ដែលចែងនៅក្នុងរដ្ឋនីមួយៗនៅក្នុងសហរដ្ឋអាមេរិក ដែលបានអនុម័តច្បាប់គំរូនេះ។ និយមន័យនៃការសម្ងាត់ពាណិជ្ជកម្មនៅក្នុងច្បាប់គំរូរបស់ កាណាដា ចែងដូចខាងក្រោមនេះ ៖

***ការសម្ងាត់ពាណិជ្ជកម្ម*** *មានន័យថាជាព័ត៌មានដែល ៖*

*ក. ត្រូវបានប្រើ ឬអាចត្រូវបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ឬការធ្វើជំនួញ,*

*ខ. មិនត្រូវបានស្គាល់ជាទូទៅនៅក្នុងពាណិជ្ជកម្មនោះ ឬនៅក្នុងការធ្វើជំនួញនោះ*

*គ. មានតម្លៃខាងសេដ្ឋកិច្ច ដោយហេតុថាវាមិនត្រូវបានស្គាល់ជាទូទៅ និង*

*ឃ. ជាកម្មវត្ថុនៃការខំប្រឹងប្រែងដែលមានហេតុផល ក្រោមកាលៈទេសៈមួយចំនួនដើម្បីការពារវាពីការស្គាល់ជាទូទៅ*

*គោលបំណងនៃនិយមន័យព័ត៌មានសម្ងាត់ពាណិជ្ជកម្ម រួមមាន ព័ត៌មានដែលត្រូវបានបង្កើតឡើងដោយផ្ទុក ឬដោយដាក់បញ្ចូលទៅក្នុង (ប៉ុន្តែមិនកំណត់ត្រឹមចំនុចទាំងនេះទេ) រូបមន្ត គំរូ ប្លង់ការបកស្រាយ កម្មវិធីកុំព្យូទ័រ វិធីសាស្រ្ត បច្ចេកទេស ដំណើរការ ផលិតផង និមិត្តសញ្ញា (device) ឬយន្តការ មួយ។*

នៅសហរដ្ឋអាមេរិក **ការសម្ងាត់ពាណិជ្ជកម្ម** ត្រូវបានឲ្យនិយមន័យលើកដំបូងយ៉ាងចង្អៀតនៅក្នុងច្បាប់ First Restatement of Torts (First Restatement) ដូចខាងក្រោមនេះ ៖

*ការសម្ងាត់ពាណិជ្ជម្មរួមបញ្ចូលនូវ **រូបមន្តណាមួយ គំរូណាមួយ ឧបករណ៍ ឬបណ្តុំនៃព័ត៌មានណាមួយ** ដែលត្រូវប្រើប្រាស់នៅក្នុងការធ្វើពាណិជ្ជកម្មរបស់បុគ្គលណាម្នាក់ ហើយដែលផ្តល់**ផលប្រយោជន៍** ឲ្យគាត់មុនអ្នកប្រកួតប្រជែងផ្សេងទៀត ដែលមិនបានដឹង ឬមិនបានប្រើប្រាស់ព័ត៌មាននេះ។ វាអាចជារូបមន្តបណ្តុំ ធាតុគីមី ដំណើរការផលិត ការប្រើប្រាស់ឧបករណ៍ការពារ គំរូសម្រាប់ម៉ាស៊ីន ឬឧបករណ៍ដទៃទៀត ឬបញ្ជីអតិថិជនមួយ។ វាខុសប្លែកពីព័ត៌មានសម្ងាត់ផ្សេងៗទៀតនៅក្នុងការធ្វើពាណិជ្ជកម្ម ដែលព័ត៌មាននោះ មិនមែនជាព័ត៌មានធម្មតាដូចសកម្មភាពដាច់តែឯងមួយ ឬសកម្មភាពមិនស្ថិតស្ថេរនៅក្នុងការធ្វើពាណិជ្ជកម្ម ឧទាហរណ៍ដូចជា រយៈពេល ឬការកំណត់តម្លៃជាសម្ងាត់សម្រាប់កិច្ចសន្យាមួយ ឬតម្លៃប្រាក់បៀវត្សន៍របស់ និយោជិតមួយចំនួន ឬការវិនិយោគមូលបត្រពាណិជ្ជកម្មដែលត្រូវបានធ្វើ ឬរៀបនឹងធ្វើ ឬកាលបរិច្ឆេទដែលត្រូវបានកំណត់សម្រាប់ការប្រកាសគោលនយោបាយថ្មី ឬសម្រាប់បង្កើតនូវគំរូថ្មី ឬប្រហាក់ប្រហែល។ **ការសម្ងាត់ពាណិជ្ជកម្ម គឺជាដំណើរការមួយ ឬឧបករណ៍មួយសម្រាប់ការប្រើប្រាស់ជាអចិន្ត្រៃយ៍នៅក្នុងប្រតិបត្តិការណ៍ពាណិជ្ជកម្ម។** ជាទូទៅ ការសម្ងាត់នេះទាក់ទងនឹងផលិតកម្មទំនិញ ឧទាហរណ៍ដូចជា ម៉ាស៊ីន ឬរូបមន្តមួយសម្រាប់ផលិតកម្មទំនិញមួយ។ ប៉ុន្តែ ព័ត៌មានសម្ងាត់នេះអាចទាក់ទងនឹងការលក់ទំនិញ ឬប្រតិបត្តិការណ៍ពាណិជ្ជកម្មផ្សេងទៀត ដូចជា **លេខកូដសម្រាប់កំណត់ការចុះតម្លៃ ការបង្វិលប្រាក់** ឬការធ្វើសម្បទានផ្សេងទៀត នៅក្នុងតារាងតម្លៃ ឬសៀវភៅបញ្ជីតម្លៃ ឬបញ្ជីអតិថិជនជាក់លាក់ ឬវិធីសាស្រ្តគណនេយ្យ ឬរបៀបគ្រប់គ្រង ការិយាល័យដទៃទៀត។*

កត្តាផ្សេងទៀត ដែលត្រូវបានកំណត់បន្ថែមលើនិយមន័យនេះ រួមមាន៖

ក. វិសាលភាពដែលព័ត៌មានសម្ងាត់នេះត្រូវបានស្គាល់នៅខាងក្រៅពាណិជ្ជកម្ម

ខ. វិសាលភាព ដែលត្រូវបានស្គាល់ដោយនិយោជិត និងអ្នកពាក់ព័ន្ធដទៃទៀតនៅក្នុងពាណិជ្ជកម្ម

គ. វិសាលភាពនៃការចាត់វិធានការដើម្បីការពារនូវភាពសម្ងាត់នៃព័ត៌មាននេះ

ឃ. តម្លៃនៃព័ត៌មានចំពោះម្ចាស់សិទ្ធិ និងចំពោះអ្នកប្រកួតប្រជែងរបស់គាត់

ង. ការខិតខំប្រឹងប្រែង ឬថវិកាដែលត្រូវបានចំណាយដោយម្ចាស់សិទ្ធិនៅក្នុងការបង្កើតព័ត៌មាន និង

ច. ភាពងាយស្រួល និងភាពលំបាកដែលព័ត៌មានអាចត្រូវបានទទួលស្គាល់ដោយត្រឹមត្រូវតាមច្បាប់ ឬត្រូវបាន ចំលងដោយអ្នកផ្សេងទៀត។

នៅក្នុងឆ្នាំ ១៩៨៥ ច្បាប់រួមស្តីពីពត៌មានសម្ងាត់របស់សហរដ្ឋអាមេរិក បានឲ្យនិយមន័យការសម្ងាត់ពាណិជ្ជកម្ម ថា៖

*ជាព័ត៌មាន ដែលរួមបញ្ចូលនូវរូបមន្ត គំរូ បណ្តុំពត៌មាន កម្មវិធី ឧបករណ៍ វិធីសាស្ត្របច្ចេកទេស ឬដំណើរការមួយដែល (១) បង្កើត **តម្លៃសេដ្ឋកិច្ចឯករាជ្យ**ដោយជាក់ស្តែង ឬមិនជាក់ស្តែងជាការមិនត្រូវបានស្គាល់ ជាទូទៅ និង **ការដែលមិនអាចត្រូវបានរកឃើញរួចហើយ** ដោយមធ្យោបាយស្របច្បាប់ដោយបុគ្គលផ្សេងទៀត ដែលអាចទទួលបានតម្លៃខាងសេដ្ឋកិច្ចពីការបង្ហើបបង្ហាញ ឬការប្រើប្រាស់ការសម្ងាត់ និង (២) ជាកម្មវត្ថុ នៃការខិតខំប្រឹងប្រែងដ៏សមស្របក្រោមកាលៈទេសៈមួយដើម្បីការពារភាពសម្ងាត់របស់វា(បញ្ជាក់បន្ថែម)។*

និយមន័យនៃការសម្ងាត់ពាណិជ្ជកម្ម ត្រូវបានគូសបញ្ជាក់នៅក្នុងច្បាប់ Restatement of the Law Unfair Competition (Third Restatement) ថា៖

*ការសម្ងាត់ពាណិជ្ជកម្ម គឺជាព័ត៌មានណាមួយ ដែលអាចត្រូវបានប្រើប្រាស់នៅក្នុងប្រតិបត្តិការណ៍ពាណិជ្ជកម្ម ឬប្រតិបត្តិការសហគ្រាស ហើយជាព័ត៌មានដែលមានតម្លៃ និងសម្ងាត់គ្រប់គ្រាន់ដើម្បីទទួលបាននូវផលប្រយោជន៍ខាងសេដ្ឋកិច្ចជាក់ស្តែង ឬមិនជាក់ស្តែងមុនបុគ្គលផ្សេងទៀត[1] ។*

វាមានភាពខុសប្លែកពីគ្នារវាង First Restatement និង Uniform Act ដែលបង្ហាញពីលក្ខណៈដែលនៅក្នុងនោះប្រព្រឹត្តិកម្មនៃការសម្ងាត់ពាណិជ្ជកម្មបានវិវត្តក្នុងកំឡុងពេលធ្វើអន្តរាគមន៍ ៥០ ឆ្នាំក្រោយ។ ទាំង Uniform Act និង មាត្រា ៣៩(២) នៃកិច្ចព្រមព្រៀង TRIPS កំណត់ន័យ ការសម្ងាត់ពាណិជ្ជកម្មថាជា **ព័ត៌មាន**។ ដោយយោងទៅតាមការពន្យល់ របស់អ្នកវិភាគមួយរូបដែលបានអនុលោមតាម Model Act បានឲ្យដឹងថា ភាពខុសគ្នាមួយទៀតគឺថា Uniform Act និយាយពី វិធីសាស្ត្រ កម្មវិធី និងបច្ចេកទេសផ្សេងៗ ដែលរួមបញ្ចូលទាំង**ចំណេះធ្វើ** ផងដែរ។ ទី៣ Uniform Act មិនរួមបញ្ចូលនូវ **លក្ខខណ្ឌប្រើប្រាស់ជាអចិន្ត្រៃយ៍** ដែលមាននៅក្នុង First Restatement នោះទេ។

[1] Jerry Cohen, Alan S. Gutterman, *Trade Secrets Protection and Exploitation*. Virginia: Bureau of National Affairs, 1998.

ដូច្នេះ ព្រឹត្តិការណ៍ដែលមិនអាចកើតឡើងម្តងទៀតនៅពេលណាមួយនោះអាចចាត់ទុកថាជា ការសម្ងាត់ ដោយរួមបញ្ចូលទាំងការកំណត់តម្លៃជាសម្ងាត់ ឬការផ្សព្វផ្សាយពាណិជ្ជកម្មដែលនឹងត្រូវធ្វើនាពេលខាងមុខ។ **ព័ត៌មានអវិជ្ជមាន** ក៏ត្រូវបានការពារផងដែរ ដូចជាការណ៍ដែលដំណើរការ ឬវិធីសាស្ត្រពិតប្រាកដណាមួយមិនអាចដំណើរការបាន។ ព័ត៌មាននេះ អាចមានតម្លៃខាងសេដ្ឋកិច្ច ដោយហេតុថាប្រសិនបើ ព័ត៌មានអវិជ្ជមាននេះត្រូវបាន បង្ហើបបង្ហាញឲ្យគេបានដឹង វាអាចអនុញ្ញាតឲ្យអ្នកប្រកួតប្រជែងផ្សេងទៀតជៀសផុតពីផលអវិជ្ជមាននេះ ដែលអាចកើតមានឡើងនៅក្នុងការអភិវឌ្ឍន៍ផលិតផលរបស់ពួកគេ។ ទី៤ Uniform Act គ្រាន់តែតម្រូវថា នឹងចាត់ទុកថាជាការសម្ងាត់ពាណិជ្ជកម្ម ប្រសិនបើព័ត៌មាននេះផ្តល់នូវតម្លៃខាងសេដ្ឋកិច្ចឯករាជ្យជាក់ស្តែង ឬមិនជាក់ស្តែង រីឯ First Restatement តម្រូវឲ្យមាន **ផលប្រយោជន៍នៃការប្រកួតប្រជែង** ពិតប្រាកដដើម្បីអាចកំណត់ថាព័ត៌មានមួយជាការសម្ងាត់ពាណិជ្ជកម្ម។ ទី៥ Uniform Act គ្រាន់តែកំណត់ទៅលើកត្តាមួយក្នុងចំណោមកត្តាទាំង ៦ ខាងលើដែលត្រូវបានកំណត់នៅក្នុង First Restatement ហើយដែលជាលក្ខខណ្ឌមួយ ដែលម្ចាស់សិទ្ធិត្រូវតែចាត់វិធានការសមស្របក្នុងកិច្ចការពារភាពសម្ងាត់នៃព័ត៌មាននោះ។

ការប្រៀបធៀបនេះ បានគូសបញ្ជាក់ឲ្យឃើញនូវលក្ខណៈមួយដែលមាត្រា ៣៩(២) នៃកិច្ចព្រមព្រៀង TRIPS ទទួលឥទ្ធិពលពី Uniform Act ។ មាត្រា ៣៩(២) ចែងពីការសម្ងាត់ពាណិជ្ជកម្មនៃពត៌មាន និងសំដៅលើតម្លៃដែលផ្ទុយទៅនឹងផលប្រយោជន៍ប្រកួតប្រជែង ហើយការរក្សាព័ត៌មានឲ្យសម្ងាត់ គឺជាលក្ខខណ្ឌចាំបាច់មួយ។

របៀបនៃការកំណត់និយមន័យខាងលើក៏បង្ហាញឲ្យឃើញផងដែរពីរបៀបនៃការឲ្យនិយមន័យដែលមាននៅក្នុងច្បាប់គំរូ ដែលបានផ្លាស់ប្តូរជាប្រចាំតាំងពីមានការអនុម័តមក។ ឧទាហរណ៍ រដ្ឋមួយចំនួនបានបង្កើតពាក្យមួយនៅក្នុងកថាខណ្ឌដំបូងថា "**ដោយរួមបញ្ចូល ប៉ុន្តែមិនកំណត់**[3]" ដែលធ្វើឲ្យមានន័យកាន់តែទូលំទូលាយរហូតដល់មិនអាចកំណត់នូវព័ត៌មានប្រភេទណា ដែលអាចចាត់ទុកជា ការសម្ងាត់ពាណិជ្ជកម្មបាន។ រដ្ឋផ្សេងៗទៀតបានពង្រីកតារាងព័ត៌មាននេះ ដោយរួមបញ្ចូលនូវធាតុផ្សំបន្ថែមដូចជា៖ software និងគំនូរ ព័ត៌មានបច្ចេកទេស ឬវិទ្យាសាស្ត្រ ពាណិជ្ជកម្មដែលត្រូវរក្សា ការសម្ងាត់ ឬពត៌មានហិរញ្ញវត្ថុដែលត្រូវរក្សាការសម្ងាត់ បញ្ជីឈ្មោះ អាស័យដ្ឋាន ឬលេខទូរស័ព្ទ គំនូរ ទិន្នន័យតម្លៃ ឬបញ្ជីអតិថិជន ទិន្នន័យបច្ចេកទេស ឬមិនមែនបច្ចេកទេស គំនូរគម្រោងហិរញ្ញវត្ថុ គម្រោងផលិតផល និងរូបមន្ត គំរូ បណ្តុំនៃពត៌មាន កម្មវិធី ឧបករណ៍ វិធីសាស្ត្របច្ចេកទេស និងដំណើរការ។ល។ តុលាការ California បានពង្រីកបញ្ជីនេះដោយបន្ថែម៖

ក. តម្លៃគណនេយ្យ និងតម្លៃពាណិជ្ជកម្មដែលបានទទួល

[3] ឃ្លានេះត្រូវបានបន្ថែមនៅក្នុង ច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្មរបស់រដ្ឋ Illinois, Maine, Virginia, and West Virginia, ចំពោះការពិភាក្សាលើរឿងក្តី ស្តីពី មូលដ្ឋានពីរដ្ឋមួយទៅរដ្ឋមួយ នៅចន្លោះឆ្នាំ ១៩៨៦ និង ២០០២, *see* Brain M. Malsberger, Trade Secrets A State-by-State Survey, 2nd Ed., ABA Section of Labour and Employment Law, 2003។

ខ. ប្រភពនៃការផ្តល់សម្ភារៈ ប្រព័ន្ធ និងវិធីសាស្ត្រនៃការធ្វើពាណិជ្ជកម្ម និងប្រព័ន្ធ និងគំរូនៃការកំណត់ឱកាសពាណិជ្ជកម្មថ្មី

គ. យុទ្ធសាស្ត្រ និងការព្យាករណ៍ទីផ្សារ

ឃ. ការវិភាគលើប្រសិទ្ធិភាពសេដ្ឋកិច្ច និងផលប្រយោជន៍វិស្វកម្ម

ង. របាយការណ៍ចំណូល

ច. តារាងតុល្យភាព

ឆ. របាយការណ៍ហិរញ្ញវត្ថុលំអិត និងបញ្ជីចេញចូលទូទៅ

ជ. បញ្ជីអតិថិជន ការផុតអាជ្ញាយុកាលនៃកិច្ចសន្យា បញ្ជីនៃការគ្រប់គ្រងពាណិជ្ជកម្មសំខាន់ៗ ប្រវត្តិបណ្តឹង និងពត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងតម្រូវការសំខាន់ៗរបស់អតិថិជន និង

ឈ. ឱកាសពាណិជ្ជកម្មដែលផ្អែកលើមូលដ្ឋានចំណេះដឹងនៃការធ្វើពាណិជ្ជកម្មនាពេលខាងមុខ និងផលចំណេញ[4]។

ឧទាហរណ៍មួយចំនួនខាងលើគ្រាន់តែ បង្ហាញអំពីវិសាលភាពនៃនិយមន័យ ដែលត្រូវបានកំណត់ថាជាការសម្ងាត់ពាណិជ្ជកម្មប៉ុណ្ណោះ។ ឧទាហរណ៍ គម្រោងពាណិជ្ជកម្ម និងព័ត៌មានហិរញ្ញវត្ថុ ដែលរួមបញ្ចូលទាំងផែនការ និងយុទ្ធសាស្ត្រទីផ្សារអាចត្រូវបានការពារ ប្រសិនបើវាត្រូវបានរក្សាជាសម្ងាត់[5]។ បញ្ជីអតិថិជនក៏ជាកម្មវត្ថុនៃការការពារដែរ ប៉ុន្តែត្រូវតម្រូវឲ្យមានស្តង់ដាដែលខ្ពស់ជាងនេះ។ អតីតនិយោជិតដែលយកបញ្ជីអតិថិជនទៅប្រើប្រាស់ត្រូវបានហាមឃាត់។ ប្រសិនបើអតីតនិយោជិតរបស់ក្រុមហ៊ុននេះស្គាល់អតិថិជនទាំងនោះ ប៉ុន្តែមិនបានយកបញ្ជីអតិថិជននេះទៅជាមួយទេ កត្តាដែលតុលាការអាចធ្វើការពិចារណារួមមានៈ វិសាលភាពដែលព័ត៌មានជាក់លាក់ត្រូវបានដឹងដល់អ្នកដែលនៅក្រៅពាណិជ្ជកម្ម ព័ត៌មានត្រូវបានដឹងដោយនិយោជិត និងអ្នកផ្សេងទៀតដែលពាក់ព័ន្ធនៅក្នុងការធ្វើពាណិជ្ជកម្មនេះ វិធានការដែលត្រូវបានធ្វើ ឡើងដោយនិយោជកដើម្បី

[4] Jerry Cohen, Alan S. Gutterman, *Trade Secrets Protection and Exploitation*. Virginia: Bureau of National Affairs, 1998, ទំព័រ ៧៥។

[5] ផែនការទីផ្សារមានសិទ្ធិត្រឹមតែទទួលបាននូវការការពារទេ ប្រសិនបើព័ត៌មាននេះមិនទាន់បានត្រៀមរួចរាល់ សម្រាប់ទីផ្សារទេ។ វិធាននេះត្រូវបានតុលាការនៅក្នុងរដ្ឋ Massachusetts យកទៅអនុវត្ត ដែលតុលាការនេះបានបដិសេធនូវការការពារលើព័ត៌មានទីផ្សារ និងការផ្សាយពាណិជ្ជកម្ម ដែលទទួលបានរួចហើយ ឬត្រូវបានចម្លង ដោយភាគីអង្កេតការ។ នៅក្នុងករណីផ្សេងទៀត ការធ្វើសេចក្តីសម្រេចប្រឆាំងទៅនឹងការការពារតម្លៃ និងការកំណត់តម្លៃព័ត៌មាន ត្រូវបានកំណត់ដើម្បីត្រៀមរួចជាស្រេចតាមរយៈមធ្យោបាយស្របច្បាប់។ ជាមួយគ្នានោះដែរ ដោយសារតែការកំណត់តម្លៃព័ត៌មានតែងតែមានការផ្លាស់ប្តូរជាប្រចាំខែ ជាប្រចាំសប្តាហ៍ ឬជាប្រចាំថ្ងៃនោះ ដើមចោទអាចមានបញ្ហាដែលផ្ទុយទៅនឹងសម្អាង ដែលព័ត៌មានត្រូវបានប្រើរួចហើយ និងមិនមានតម្លៃខាងសេដ្ឋកិច្ចឯករាជ្យទៀតទេ។

ការពារភាពសម្ងាត់នៃព័ត៌មាន តម្លៃនៃព័ត៌មានចំពោះនិយោជក និងអ្នកប្រកួតប្រជែងរបស់ខ្លួន តម្លៃនៃការខិតខំប្រឹងប្រែង ឬថវិកាដែលត្រូវបានចំណាយដោយនិយោជក ក្នុងការសម្រិតសម្រាំងព័ត៌មាន ភាពងាយស្រួល ឬភាពពិបាកដែលពត៌មានអាចត្រូវទទួលដោយស្របច្បាប់ ឬត្រូវបានចម្លងដោយអ្នកដទៃ វិសាលភាពនៃទំនាក់ទំនងភ្នាក់ងារជាមួយដៃគូរពាណិជ្ជកម្ម គឺជាទំនុកចិត្ត ឬការធានាមួយ វិធីសាស្ត្រដែលអតីតនិយោជិតបានទទួលការសម្ងាត់នោះ ទំនាក់ទំនងបុគ្គលរបស់អតីតភ្នាក់ជាមួយនឹងអតិថិជន និងផលប្រយោជន៍មិនស្របច្បាប់ដែលអាចនឹងទទួល ឬបានទទួលដោយអតីតភ្នាក់ងារពីការប្រើប្រាស់ព័ត៌មានសម្ងាត់នៃអតីតដៃគូរពាណិជ្ជកម្ម។

តុលាការបានបដិសេធមិនទទួលស្គាល់ បញ្ជីឈ្មោះ និងអាស័យដ្ឋានអតិថិជន ថាជាការសម្ងាត់ពាណិជ្ជកម្មពីព្រោះថា ដំណើរការនៃការធ្វើបង្កុំបញ្ជីនេះ មិនមែនជាការពិបាក ស្មុគ្រស្មាញ ឬទាមទារឲ្យប្រើពេលវេលាយូរឡើយ។ ឋានៈជាការសម្ងាត់ពាណិជ្ជកម្មក៏ត្រូវបានបដិសេធផងដែរនៅក្នុងករណីដែលពត៌មាននេះអាចរកបានជាទូទៅ តាមរយៈការសាកសួរយ៉ាងទូលាយតាមទីផ្សារប្រកួតប្រជែងថ្នាក់ខ្ពស់ និងការប្រកួតប្រជែងពីមុនៗ[6]។ ប៉ុន្តែ តុលាការបានកំណត់ឋានៈសម្ងាត់ពាណិជ្ជកម្មសម្រាប់បញ្ជីអតិថិជនមួយ ដោយសារតែបញ្ជីនេះត្រូវបានបង្កើតឡើយ ដោយ "**ការស្រាវជ្រាវរយៈពេលវែង និងការស្រាវជ្រាវដែលមានតម្លៃថ្លៃ**"[7]។

ឧទាហរណ៍ផ្សេងទៀត ដែលបង្ហាញថាអ្វីដែលត្រូវចាត់ទុកថាជា **ការសម្ងាត់ពាណិជ្ជកម្ម** នោះត្រូវយោងតាម **ព័ត៌មានពាណិជ្ជកម្មទូទៅ**។ ចំណេះដឹង បទពិសោធន៍ និងជំនាញដែលត្រូវបានអភិវឌ្ឍន៍ដោយនិយោជិតម្នាក់នៅកំឡុងពេលបំពេញការងារធម្មតា មិនអាចទទួលបានកិច្ចការពារការសម្ងាត់ពាណិជ្ជកម្មឡើយ។ បញ្ហាដែលចោទឡើងនៅត្រង់ថា តើគេត្រូវការបែងចែកឲ្យដាច់រវាងចំណេះដឹង និងចំណេះធ្វើ ដែលចំណេះធ្វើតែមួយគត់នេះ គឺសម្រាប់ការធ្វើពាណិជ្ជកម្ម និងអាចត្រូវបានចាត់ទុកជាការសម្ងាត់ពាណិជ្ជកម្មច្រើនជាង។ ករណីមួយចំនួនបានឲ្យដឹងថា កិច្ចការពារអាចធ្វើទៅបានចំពោះ "ចំណេះដឹងនៃដំណើរការជាក់លាក់មួយ វិធីសាស្ត្រក្នុងការបង្កើតឧបករណ៍នានាដែលសមស្របបំផុតដើម្បីសម្រេចបានលទ្ធផលដែលចង់បាន"[8]។

---

[6] ឧទាហរណ៍ នៅក្នុងករណីមួយ ដែលលក្ខណៈរបស់ការសម្ងាត់ពាណិជ្ជកម្ម ត្រូវបានបដិសេធមិនឲ្យចុះនៅក្នុង សៀវភៅបញ្ជីរបស់អ្នកផ្សព្វផ្សាយ ដែលអត្តសញ្ញាណរបស់អ្នកផ្សព្វផ្សាយទាំងនោះអាចត្រូវបានដឹងជាទូទៅពីការដាក់បង្ហាញមសៀវភៅនេះដោយខ្លួនឯង។

[7] Jerry Cohen, Alan S. Gutterman, *Trade Secrets Protection and Exploitation*. Virginia: Bureau of National Affairs, 1998, ទំព័រ ១០០-១។

[8] Jerry Cohen, Alan S. Gutterman, *Trade Secrets Protection and Exploitation*. Virginia: Bureau of National Affairs, 1998 , ទំព័រ ១០៤-៥។

## កថាខណ្ឌទី២៖ ធាតុផ្សំនៃការសម្ងាត់ពាណិជ្ជកម្ម

### វាក្យខ័ណ្ឌទី១៖ធាតុផ្សំសំខាន់នៃ ភាពសម្ងាត់

មាត្រា ៣៩(២) ចែងថា **ភាពសម្ងាត់** គឺជាលក្ខខណ្ឌមួយដើម្បីការពារលើព័ត៌មានសម្ងាត់ពាណិជ្ជកម្ម។

ឲ្យតែព័ត៌មាននេះជាការសម្ងាត់នៅក្នុងន័យដែលថា គេមិនដឹងជាទូទៅក្នុងចំណោមបុគ្គលដែលជាធម្មតាពាក់ព័ន្ធនឹងព័ត៌មាននេះ ឬមិនងាយនឹងអាចធ្លាយឲ្យដឹង ឮដល់បុគ្គលដែលស្ថិតនៅក្នុងមជ្ឈដ្ឋាននេះ នៅក្នុងទម្រង់ទាំងមូល ឬជាឬរូបសណ្ឋានជាក់លាក់ណាមួយ និងបង្គុំសមាសភាពនៃព័ត៌មាននេះ។

នៅពេលដែលព័ត៌មាននេះត្រូវបានបង្ហើបបង្ហាញម្តងរួចហើយ ព័ត៌មាននេះមិនអាចត្រូវបានការការពារទៀតទេ។ ដូចគ្នានឹងវិធាននេះដែរ នៅពេលដែលព័ត៌មាននេះត្រូវបានរក្សាជាសម្ងាត់[9] វាអាចត្រូវបានការពារដោយមិនកំណត់រយៈពេលលុះណាតែព័ត៌មាននេះត្រូវបានបង្ហើបបង្ហាញ ឬលែងមានតម្លៃខាងពាណិជ្ជកម្មតទៅទៀត។

តាមច្បាប់របស់សហរដ្ឋអាមេរិក ភាពសម្ងាត់ត្រូវបានកំណត់ថាជា "បញ្ហាចម្បង" ហើយវាមិនមានអញ្ញត្រកម្មចំពោះច្បាប់នេះទេ។ The United States Restatement of Torts ចែងពីលក្ខខណ្ឌនៃភាពសម្ងាត់ដូចខាងក្រោម៖

កម្មវត្ថុនៃការសម្ងាត់ពាណិជ្ជកម្មត្រូវតែសម្ងាត់។ កម្មវត្ថុដែលត្រូវបានគេដឹងជាសាធារណៈ ឬត្រូវបានដឹងជាទូទៅ នៅក្នុងឧស្សាហកម្មមួយមិនអាចចាត់ទុកថាជាការសម្ងាត់ទេ។ បញ្ហាដែលត្រូវបានបង្ហើបបង្ហាញទាំងស្រុងតាម រយៈទំនិញដែលគេដាក់លក់នៅលើទីផ្សារមួយមិនអាចចាត់ទុកថាជាការសម្ងាត់ព័ត៌មាននេះទេ។ ឧទាហរណ៍ អ្នកផ្សេងទៀតក៏អាចដឹងដោយឯករាជ្យផងដែរ នៅពេលដែលពួកគេបានរកឃើញដំណើរការ ឬរូបមន្ត ដោយការច្នៃប្រឌិតឯករាជ្យ ហើយពួកគេកំពុងការពារវាជាសម្ងាត់។ ប៉ុន្តែ ធាតុសំខាន់នៃភាពសម្ងាត់ត្រូវតែមាន។ ដូច្នេះ វាមានការលំបាកក្នុងការទទួលព័ត៌មាននេះណាស់ លើកលែងតែព័ត៌មាននេះត្រូវបានទទួលបានដោយការប្រើប្រាស់មិនត្រឹមត្រូវ។

គំនិតនៃភាពសម្ងាត់មិនត្រូវបានចែងទេ ប៉ុន្តែតុលាការសហរដ្ឋអាមេរិក បានបង្កើតភាពសម្ងាត់នេះដោយផ្អែកលើកត្តាមួយចំនួន ដែលជាធម្មតារួមមាន៖

*១. វិសាលភាព ដែលព័ត៌មានត្រូវបានដឹងជាទូទៅដល់បុគ្គលផ្សេងទៀតនៅខាងក្រៅពាណិជ្ជកម្ម*

*២. វិសាលភាពនៃវិធានការដែលត្រូវបានធ្វើឡើងដោយម្ចាស់សិទ្ធិលើការសម្ងាត់ពាណិជ្ជកម្ម ដើម្បីរក្សាភាពសម្ងាត់ នៃព័ត៌មាននេះ*

[9] Merges, Menell, Lemley, *Intellectual Property in the New Technological Age*, Aspen, 3rd Ed, 2003, at 51.

*៣. ភាពងាយស្រួល ឬភាពលំបាកដែលព័ត៌មាននេះត្រូវបានទទួល ឬចម្លងតាមដោយអ្នកផ្សេងទៀត ដោយមិនប្រើមធ្យោបាយខុសច្បាប់[10]។*

មាត្រា ៣៩(២)(ក) ចែងពីលក្ខខណ្ឌដែលព័ត៌មានមិនត្រូវបានដឹងជាទូទៅ ឬងាយនឹងដឹងឮដល់មនុស្សនៅក្នុងមជ្ឈដ្ឋាននានាដែលទាក់ទងនឹងប្រភេទព័ត៌មាននេះ។ បទប្បញ្ញត្តិនេះចែងថា ភាពសម្ងាត់ពាណិជ្ជកម្មអាចនឹងបាត់បង់នូវឋានៈជាការសម្ងាត់របស់វា ទោះបីជាព័ត៌មាននេះមិនត្រូវបានដឹងជាសាធារណៈក៏ដោយ ឲ្យតែវាត្រូវបានដឹងជាទូទៅនៅក្នុងក្រុមហ៊ុនដែលពាក់ព័ន្ធណាមួយនៅក្នុងករណីនេះ។ ជាមួយគ្នានេះដែរ ការដឹងដោយបុគ្គលច្រើននាក់ ឬក្រុមហ៊ុនច្រើននៅក្នុងឧស្សាហកម្មណាមួយ ការដឹងនេះតែមួយគត់ នឹងមិនអាចតម្រូវឲ្យបាត់បង់កិច្ចការពារព័ត៌មានសម្ងាត់នោះទេ។ អ្នកផ្សេងទៀតអាចប្រើព័ត៌មាននេះដោយស្របច្បាប់ ប្រសិនបើពួកគេបានរកឃើញព័ត៌មាននេះដោយឯករាជ្យ ដោយក្រុមហ៊ុនមួយចំនួនមិនអាចចាត់ទុកជាព័ត៌មានដែលអាចការពារបាន ដោយហេតុថាព័ត៌មាននេះត្រូវបានដឹងជាទូទៅរួចទៅហើយ បើទោះបីជាក្រុមហ៊ុននីមួយៗមានចេតនាការពារលើភាពសម្ងាត់នេះក៏ដោយ។

កិច្ចការពារលើការសម្ងាត់ពាណិជ្ជកម្មអាចត្រូវបានបាត់បង់តាមរយៈមូលហេតុមួយចំនួន។ មូលហេតុទី១ កិច្ចការពារនេះអាចបាត់បង់តាមរយៈវិស្វកម្មបញ្ច្រាស់ ដែលជាសកម្មភាពមួយដែលគេអនុញ្ញាត[11]។ ឋានៈជាការសម្ងាត់ពាណិជ្ជកម្ម អាចត្រូវបានបាត់បង់នៅពេលដែលប្រកាសនីយបត្រតក្កកម្មត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ។ មូលហេតុទី២ ការបើកចំហរអាចកើតមានឡើងតាមរយៈការលក់ផលិតផលពាណិជ្ជកម្ម ដែលមានភ្ជាប់ជាមួយនូវការសម្ងាត់នេះ។ ប៉ុន្តែ វាមានករណីលើកលែងត្រង់ថា ការលក់ Software ក្នុងទម្រង់បើកចំហរជាសាធារណៈដោយការប្រើប្រាស់លេខកូដ។ មូលហេតុទី៣ ការសម្ងាត់ពាណិជ្ជកម្មអាចត្រូវបានផ្សព្វផ្សាយដោយបុគ្គលណាមួយផ្សេងទៀតក្រៅពីម្ចាស់សិទ្ធិលើការសម្ងាត់ពាណិជ្ជកម្មនោះ។ មូលហេតុទី៤ ព័ត៌មានទាំងនេះអាចត្រូវបានបង្ហើបបង្ហាញដោយធ្វេសប្រហែស ដោយការទុកចោលឲ្យសាធារណៈជនបានឃើញ

[10] Jerry Cohen, Alan S. Gutterman, *Trade Secrets Protection and Exploitation*. Virginia: Bureau of National Affairs, 1998, ទំព័រ ៨៣។

[11] ការធ្វើអត្ថាធិប្បាយរបស់បេសកជន ទៅលើ Uniform Act បញ្ជាក់ថា ការបំលែងតាមបែបវិស្វកម្មសកម្មភាពមួយ ដែលត្រូវបានអនុញ្ញាត្តិ៖ ច្បាប់មួយក្នុងចំណោមច្បាប់ដែលបានចែងយ៉ាងទូលាយនោះនៅក្រោមច្បាប់ស្តីពី ការសម្ងាត់ពាណិជ្ជកម្ម គឺ ការការពារមាត្រដ្ឋានសីលធម៌ពាណិជ្ជកម្ម។ The Restatement of Torts, Section 757, comment (f), បានធ្វើការកត់សម្គាល់ថា៖ សៀវភៅវាយឈ្មោះតាមមធ្យោបាយមិនត្រឹមត្រូវ គឺមិនអាចធ្វើទៅបានទេ ប៉ុន្តែ ផ្នែកទី១(១) រួមបញ្ចូលនូវបញ្ជីតាមផ្នែកមួយ៖ មធ្យោបាយសមស្របរួមមាន (១) ការរកឃើញដោយ ការបង្កើតថ្មីដោយឯករាជ្យ, (២) ការរកឃើញដោយការបំលែងវិស្វកម្មដែល, ដោយចាប់ផ្តើមជាមួយនឹងការងារ និងការផលិតដែលត្រូវបានដឹង ផ្ទុយពីការការរកវិធិសាស្ត្រដែលតាមរយៈនេះ វាត្រូវបានធ្វើឲ្យកើនឡើង។ ដូច្នេះ ការទទួលបាននូវផលិតផលដែលត្រូវបានដឹងក៏ត្រូវតែជាការរកឃើញដោយមធ្យោបាយយុត្តិធម៌ និងស្មោះត្រង់ ដូចជាតាមរយៈការទិញផលិតផលនៅក្នុងទីផ្សារដោយបើកចំហរចំពោះការបំលែងវិស្វកម្ម ដើម្បីទទួលបាននូវលក្ខណៈស្របច្បាប់។ (៤) ការអង្កេតទំនិញជាសាធារណៈ ឬតាមការដាក់បង្ហាញជាសាធារណៈ។

ជាដើម។ មូលហេតុចុងក្រោយ ពេលខ្លះភ្នាក់ងាររបស់រដ្ឋាភិបាលត្រូវការឲ្យមានការបង្ហាញការសម្ងាត់ពាណិជ្ជកម្ម ដោយភាគីឯកជនដើម្បីបំរើដល់ផលប្រយោជន៍សាធារណៈ។ នេះជាចំនុចដ៏សំខាន់មួយ ដែលត្រូវតែធ្វើការពិចារណានៅក្នុងការធ្វើសេចក្តីព្រាងច្បាប់ ដោយហេតុថាសិទ្ធិរបស់រដ្ឋាភិបាលចំពោះការធ្វើឲ្យមានតុល្យភាពរវាងផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ឯកជនត្រូវបានការពារ។

កត្តាទាំងនេះ មានកំណត់នៅក្នុងមាត្រា ៣៩(២)(ក) ដែលចែងថា ព័ត៌មានសម្ងាត់មិនត្រូវបានដឹងជាទូទៅ ឬងាយនឹងធ្វើឲ្យគេដឹងឡើយ។ បទប្បញ្ញត្តិនេះត្រូវបានគេយល់ថាជាវត្ថុវិស័យមួយ ប៉ុន្តែ ស្តង់ដារពាក់ព័ន្ធនឹងវិស័យនេះមិនតម្រូវថា ម្ចាស់សិទ្ធិត្រូវតែជាបុគ្គលតែមួយគត់ដែលជាអ្នកធ្វើដូច្នេះឡើយ។

### ខ-តម្លៃខាងពាណិជ្ជកម្ម

មាត្រា ៣៩(២)(ខ) ចែងថា ព័ត៌មាននេះត្រូវមាន **តម្លៃខាងពាណិជ្ជកម្មដោយសារតែភាពសម្ងាត់របស់វា**។ បន្ថែមលើភាពសម្ងាត់នេះ តម្លៃខាងសេដ្ឋកិច្ច គឺជាលក្ខខណ្ឌសំខាន់មួយដើម្បីទទួលបានកិច្ចការពារដែលមានវិសាលភាពការពារដល់ព័ត៌មានជាក់លាក់ផ្សេងទៀត។ ការរួមផ្សំនៃភាពសម្ងាត់ និងតម្លៃខាងសេដ្ឋកិច្ចនេះ អាចត្រូវបានប្រៀបធៀបជាមួយនឹងលក្ខខណ្ឌនៃភាពថ្មី និងមានជំហានរកឃើញថ្មីដើម្បីការពារប្រកាសនីយបត្រតក្កកម្ម។

មិនមាននិយមន័យណាមួយត្រូវបានកំណត់ចំពោះពាក្យ **តម្លៃខាងពាណិជ្ជកម្ម** ហើយក៏មិនមានការណែនាំដើម្បីបញ្ជាក់ពីកម្រិត ឬប្រភេទនៃតម្លៃដែលត្រូវបានតម្រូវនេះដែរ។ បញ្ហាដែលចោទឡើង គឺថា តើពត៌មាននៅក្នុងករណីនេះ ជាពត៌មានដែលត្រូវបានគេប្រើប្រាស់រួចហើយ ឬយ៉ាងណា។ Restatement on Torts របស់សហរដ្ឋអាមេរិកបានកំណត់លក្ខខណ្ឌយ៉ាងច្បាស់លាស់ថា ព័ត៌មាននេះត្រូវតែត្រូវបានប្រើ ដោយចែងថា "ការសម្ងាត់ពាណិជ្ជកម្មរួមមាន រូបមន្ត គំរូ ឧបករណ៍ ឬបណ្តុំព័ត៌មានដែលត្រូវបានប្រើនៅក្នុងពាណិជ្ជកម្មរបស់គេ"។ ការផ្លាស់ប្តូរសំខាន់មួយចេញពី First Restatement ទៅក្នុង Uniform Law និង Third Restatement គឺគេមិនទាមទារឲ្យមានការប្រើប្រាស់ជាអចិន្ត្រៃយ៍នោះទេ។ មាត្រា ៣៩(២) បានប្រកាន់ជំហរតាម Uniform Law និង Third Restatement ចែងច្បាស់ជាងនេះ ដោយបានបញ្ជាក់ថាព័ត៌មាននេះអាចជាព័ត៌មានជាក់ស្តែង ឬសក្តានុពល ប៉ុន្តែមិនមែនមានន័យថា លក្ខខណ្ឌតម្រូវដោយកិច្ចព្រមព្រៀង TRIPS ត្រូវបានកំណត់យ៉ាងចង្អៀតពេកនោះទេ។ ការសម្ងាត់ពាណិជ្ជកម្ម គឺជាព័ត៌មានទាំងឡាយណាដែលត្រូវបានប្រើនៅក្នុងប្រតិបត្តិការពាណិជ្ជកម្ម ឬនៅក្នុងសហគ្រាសក្រុមហ៊ុនផ្សេងៗទៀត និងដែលមានតម្លៃ និងភាពសម្ងាត់គ្រប់គ្រាន់ដើម្បីទទួលបាននូវផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែង ឬសំខាន់មុនគេ។

បច្ចុប្បន្ននេះ លក្ខខណ្ឌនៃ **តម្លៃខាងសេដ្ឋកិច្ចឯករាជ្យ** ត្រូវបានបកស្រាយថាជា *ការចងក្រងលក្ខខណ្ឌក្នុងប្រព័ន្ធច្បាប់ Common-Law ចាស់ៗស្ទើរតែទាំងអស់ដែលតម្រូវឲ្យការសម្ងាត់ពាណិជ្ជ*

*កម្មនេះ ត្រូវផ្តល់ផលប្រយោជន៍នៃការប្រកួតប្រជែងឲ្យទៅម្ចាស់សិទ្ធិ។* លើសពីនេះទៅទៀត គេមិនចាំបាច់បង្ហាញថាការសម្ងាត់ពាណិជ្ជកម្ម ត្រូវបង្កើតឲ្យមានផលប្រយោជន៍សេដ្ឋកិច្ចសំខាន់ច្រើននោះទេ។ ប៉ុន្តែ វាត្រូវបានតម្រូវថា ការសម្ងាត់ពាណិជ្ជកម្មនេះ ត្រូវមានតម្លៃសំខាន់ពិតប្រាកដមួយ ហើយតម្លៃបែបនេះមិនមែនជា **ពិតប្រាកដ** នោះទេ។ នៅពេលដែលគេមិនប្រើប្រាស់ព័ត៌មានក្នុងពាណិជ្ជកម្មទេ វាជាភស្តុតាងក្នុងការបង្ហាញថា វាពុំមានតម្លៃសេដ្ឋកិច្ចឡើយ។ កត្តាពេលវេលា និងថវិកា សម្រាប់បង្កើតនូវព័ត៌មានក៏មានប្រយោជន៍ផងដែរ ក្នុងការកំណត់ថាព័ត៌មាននោះមានតម្លៃខាងសេដ្ឋកិច្ច។ ប៉ុន្តែក្នុងតម្លៃណាក៏ដោយ ទោះជាតម្លៃពិតប្រាកដ ឬសក្តានុពលសុទ្ធតែជាតម្លៃគ្រប់គ្រាន់ដើម្បីកំណត់ ព័ត៌មាននេះថាជាការសម្ងាត់ពាណិជ្ជកម្មដែលត្រូវបានការពារ។ ព័ត៌មាននៅក្នុងករណីនេះ អាចមិនទាន់ត្រូវបានដាក់ ឲ្យប្រើប្រាស់នៅឡើយទេ ហើយវាអាចត្រូវបានប្រើប្រាស់តែម្តងគត់ ឬព័ត៌មាននេះជាព័ត៌មានអវិជ្ជមាន ក្នុងន័យដែលថាវាបានធ្វើបុគ្គលណាមួយដឹងនូវអ្វីដែលមិនត្រូវធ្វើ ប្រសើរជាងអ្វីដែលត្រូវធ្វើ។ ឧទាហរណ៍ រឿងក្តីមួយបានឲ្យដឹងថា ផែនការទីផ្សារមួយដែលទាក់ទងនឹងផលិតផល ឬទាក់ទងនឹងសេវាកម្មផ្សេងៗនាពេលអនាគត អាចមានតម្លៃសេដ្ឋកិច្ចសំខាន់ ដោយសារតែបច្ចេកទេស ឬទិដ្ឋភាពផលិតដែលពាក់ព័ន្ធនៅក្នុងការដាក់បង្ហាញលើទីផ្សារ។

ធាតុផ្សំនៃតម្លៃខាងពាណិជ្ជកម្ម មានន័យយ៉ាងទូលាយ និងមិនច្បាស់លាស់ដែលទុកលទ្ធភាពយ៉ាងទូលាយឲ្យតុលាការធ្វើការបកស្រាយតាមរយៈការបង្ហាញភស្តុតាងតាមករណីនីមួយៗ។

## ផ្នែកទី២៖ លក្ខខណ្ឌនៃការកំណត់សម្គាល់ការសម្ងាត់ពាណិជ្ជកម្ម

### កថាខណ្ឌទី១៖ អត្ថន័យនៃមាត្រា ៣៩(១) និងមាត្រា ៣៩(២) នៃកិច្ចព្រមព្រៀង TRIPS

មានលក្ខខណ្ឌជាច្រើន ដែលអាចធ្វើការកំណត់សម្គាល់ការសម្ងាត់ពាណិជ្ជកម្មបាន ហើយលក្ខខណ្ឌទាំងនេះគឺមានចែងនៅក្នុងច្បាប់ក្នុងប្រទេសនីមួយៗ ជាពិសេស មាត្រា ៣៩ នៃកិច្ចព្រមព្រៀង TRIPS ដែលប្រទេសជាច្រើន ដែលជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកទទួលយកមកធ្វើជាគោលការណ៍ច្បាប់របស់ខ្លួន។

កថាខណ្ឌទី១៖ អត្ថន័យនៃមាត្រា៣៩(១) និងមាត្រា៣៩(២) នៃកិច្ចព្រមព្រៀង TRIPS
មាត្រា ៣៩(១) ចែងថា:

> *ដើម្បីធានាអោយមានកិច្ចការពារប្រកបដោយប្រសិទ្ធភាព ប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់ ដូចមានចែងក្នុងមាត្រា ១០ ស្ទួននៃអនុសញ្ញាទីក្រុងប៉ារីសឆ្នាំ ១៩៦៧ សមាជិកទាំងឡាយត្រូវការពារព័ត៌មានសម្ងាត់តាមកថាខណ្ឌទី២ នឹងការពារទិន្នន័យដែលបានដាក់ជូនរដ្ឋាភិបាល ឬភ្នាក់ងាររដ្ឋាភិបាល តាមកថាខណ្ឌទី៣។*

សន្និសីទកាសែតរបស់អង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ (UNCTAD) និងមជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកខាងពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ដោយចិរភាព (Sustainable

Development) (ICTSD) ក្នុងការបោះពុម្ពផ្សាយសៀវភៅស្តីពីកិច្ចព្រមព្រៀង TRIPS និងការអភិវឌ្ឍន៍[12] បញ្ជាក់ថា មាត្រា ៣៩(១) ចែងអំពី **វិធានអនុវត្តសំខាន់ៗ** និង **បរិបទក្នុងការបកស្រាយដ៏ត្រឹមត្រូវ** នៃកថាខណ្ឌទី២ នៃមាត្រា ៣៩ នេះ។ ស្ថាប័នទាំងពីរនេះបានបញ្ជាក់ទៀតថា ការណែនាំនៅក្នុងកថាខណ្ឌនៃមាត្រា ៣៩(១) បានបញ្ជាក់អោយកាន់តែច្បាស់ថា កិច្ចការពារនេះត្រូវពឹងផ្អែកលើមូលដ្ឋានច្បាប់ស្តីពីការប្រកួតប្រជែងមិនស្មោះត្រង់ ដូចដែលមានចែងក្នុងមាត្រា ១០ ស្ទួននៃអនុសញ្ញាទីក្រុង ប៉ារីស ដែលចែងថា ៖

*(១). ប្រទេសសមាជិកនៃសហគមន៍ ត្រូវចាត់វិធានការការពារថ្នាក់ជាតិដ៏មានប្រសិទ្ធភាពសម្រាប់ប្រទេសរបស់ខ្លួន ប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់។*

*(២). សកម្មភាពនៃការប្រកួតប្រជែងណាមួយ ដែលផ្ទុយទៅនឹងការអនុវត្តមិនស្មោះត្រង់ខាងផ្នែកឧស្សាហកម្ម ឬ ពាណិជ្ជកម្មត្រូវចាត់ទុកថា ជាអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។*

*(៣). សកម្មភាពទាំងឡាយខាងក្រោមនេះ ត្រូវហាមឃាត់ ៖*

*i. គ្រប់សកម្មភាពដែលធ្វើអោយមានការភន្តច្រឡំ ដោយមូលដ្ឋានផ្សេងៗ ជាមួយនឹងគ្រឹះស្ថាន ផលិតផល ឬសកម្មភាពពាណិជ្ជកម្ម ឬឧស្សាហកម្មនៃអ្នកប្រកួតប្រជែងណាមួយ។*

*ii. ការនិយាយបំផ្លើសទាំងឡាយណានៅក្នុងដំណើរការពាណិជ្ជកម្ម ដែលធ្វើអោយប៉ះពាល់ដល់សហគ្រាស ផលិតផល ឬ សកម្មភាពពាណិជ្ជកម្ម ឬ ឧស្សាហកម្មរបស់អ្នកប្រកួតប្រជែងណាមួយ។*

*iii. ការបង្ហើបបង្ហាញ ឬការនិយាយបំផ្លើសលើការប្រើប្រាស់ដែលអាចនាំអោយមានការយល់ខុស ពីសំណាក់សាធារណៈជនទៅលើទម្រង់ដើម ដំណើរការ ផលិតលក្ខណៈសម្គាល់ គោលដៅស្រេមស្រប ឬគុណភាពរបស់ផលិតផល នៅពេលធ្វើពាណិជ្ជកម្ម។*

UNCTAD/ICTSD បានបកស្រាយថា៖

*ជាទូទៅ គេត្រូវបានទទួលស្គាល់ថា ការប្រកួតប្រជែងមិនស្មោះត្រង់ គឺជាមែកធាងមួយនៃកម្មសិទ្ធិឧស្សាហកម្ម។ ដូចដែលបាននិយាយដូចខាងលើ កិច្ចការពារបែបនេះត្រូវអោយមានដំណោះស្រាយតាមផ្លូវច្បាប់ ប្រឆាំងនឹងការអនុវត្តមិនស្មោះត្រង់ខាងពាណិជ្ជកម្ម ប៉ុន្តែកិច្ចការពារបែបនេះមិនបានបង្កើតអោយមានសិទ្ធិផ្តាច់មុខនោះទេ។ ការណ៍ដែលព័ត៌មានសម្ងាត់នេះត្រូវបានចាត់ទុកថាជាប្រភេទមួយនៃកម្មសិទ្ធិបញ្ញា (មាត្រា ១(២) នៃកិច្ចព្រមព្រៀង) មិនសំដៅទៅលើអត្ថិភាពនៃកម្មសិទ្ធិ* ***កម្មសិទ្ធិ*** *នៅក្នុងពត៌មានសម្ងាត់ឡើយ។ វាមានការកាន់កាប់ ឬ ការត្រួតពិនិត្យតាមអង្គហេតុ (de facto control) នៃពត៌មាននោះប៉ុណ្ណោះ។ ដូច្នេះ មាត្រា ៣៩(២) និង៣៩(៣) នៃកិច្ចព្រមព្រៀងនេះ*

---

[12] United Nations Conference on Trade and Development (UNCTAD) and the International Centre for the Trade and Sustainable Development (ICTSD), *Resource Book on TRIPS and Development*, 2005, Cambridge University Press, ទំព័រ ៥២៦-៧។

*សំដៅលើបុគ្គលដែលត្រួតពិនិត្យព័ត៌មានសម្ងាត់ ដោយផ្ទុយទៅនឹងសញ្ញាណកម្មសិទ្ធិពិតប្រាកដ ដែលត្រូវបានប្រើក្នុងផ្នែកដែលទាក់ទងនឹងប្រភេទផ្សេងទៀតនៃកិច្ចព្រមព្រៀង TRIPS*[13] ។

ការណ៍ដែលបុគ្គលម្នាក់ត្រូវត្រួតពិនិត្យលើព័ត៌មានសម្ងាត់ខាងលើនេះ មិនអាចទទួលបាននូវសិទ្ធិផ្តាច់មុខលើព័ត៌មានសម្ងាត់នេះ គឺជាលក្ខណៈសំខាន់ និងខុសគ្នាពីមាត្រា ៣៩(២) ហើយខុសពីទម្រង់ដើមផ្សេងៗទៀតនៃកម្មសិទ្ធិបញ្ញា។ នៅក្នុងករណីមួយចំនួន ការប្រើប្រាស់ ឬសម្រិតសម្រាំងព័ត៌មាននេះ ដោយអ្នកប្រកួតប្រជែង នឹងអតីតនិយោជិតជាការស្របច្បាប់ ប៉ុន្តែនៅក្នុងករណីមួយទៀត ការប្រើប្រាស់ នឹងការសម្រិតសម្រាំងព័ត៌មាននេះ អាចត្រូវបានហាមឃាត់។ បញ្ហាដែលបានចោទឡើងគឺថា តើនៅក្នុងដំណើរការទីផ្សារធម្មតា ការប្រប្រាស់ព័ត៌មាននោះអាចត្រូវបានចាត់ទុកថា **មិនស្មោះត្រង់** នៅក្នុងន័យដែលការប្រើប្រាស់នេះមិនត្រឹមត្រូវ ឬមិនស្មោះត្រង់ ឬលម្អៀង ឬមិនស្របច្បាប់[14]។

មាត្រា ៣៩(២) នៃកិច្ចព្រមព្រៀង TRIPS ចែងថា៖

*រូបវន្តបុគ្គល នឹងនីតិបុគ្គលទាំងឡាយ ត្រូវមានលទ្ធភាពទប់ស្កាត់ព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងស្របច្បាប់របស់ខ្លួនពីការបង្ហាញ ការទទួលបាន ឬការប្រើដោយបុគ្គលផ្សេងទៀត ដោយគ្មានការយល់ព្រម ដែលផ្ទុយពីការអនុវត្ត*[15]*ទៀងត្រង់ក្នុងវិស័យពាណិជ្ជកម្ម អោយតែព័ត៌មានទាំងនេះ៖*

*ក. សម្ងាត់ក្នុងន័យថា ព័ត៌មាននេះ ទោះជាទាំងមូល ឬក្នុងទិដ្ឋភាពជាក់លាក់នឹងបណ្តុំនៃធាតុក៏ដោយ មិនត្រូវបានដឹង ឬមិនអាចទទួលបានយ៉ាងងាយដោយបុគ្គលក្នុងមជ្ឈដ្ឋានដែលមានទំនាក់ទំនងជាធម្មតាជាមួយប្រភេទព័ត៌មាននេះ*

*ខ. មានតម្លៃពាណិជ្ជកម្មដោយសារតែព័ត៌មាននេះសម្ងាត់ នឹង*

---

[13] United Nations Conference on Trade and Development (UNCTAD) and the International Centre for the Trade and Sustainable Development (ICTSD), *Resource Book on TRIPS and Development,* 2005, Cambridge University Press, ទំព័រ ៥២៧។ វាត្រូវដាក់ក្នុងលេខយោង ១០២៥ ដែលការប្រើពាក្យ **កាន់កាប់** ខុសពី **កម្មសិទ្ធិ** ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅពេលដែលគេធ្វើការប្រៀបធៀបមាត្រា ៣៩(៣) ជាមួយនឹងមាត្រា ១៦(១) នឹង ២៨(១) នៃកិច្ចព្រមព្រៀងពី ទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងសិទ្ធិលើកម្មសិទ្ធិបញ្ញា ដែលសំដៅលើពាក្យ **ម្ចាស់សិទ្ធិ** លើម៉ាកពាណិជ្ជកម្ម និងប្រកាសនីយបត្រតក្កកម្មដោយស្របច្បាប់។

[14] United Nations Conference on Trade and Development (UNCTAD) and the International Centre for the Trade and Sustainable Development (ICTSD), *Resource Book on TRIPS and Development,* 2005, Cambridge University Press, ទំព័រ ៥២៧។ ដកស្រង់ចេញពីនិយមន័យនៃពាក្យ **មិនស្មោះត្រង់** ដែលត្រូវបានកំណត់នៅក្នុងវចនានុក្រម Concise Oxford Dictionary, Seventh Edition, Oxford University Press, Oxford, 1989។

[15] [កំណត់សម្គាល់របស់កិច្ចព្រមព្រៀង TRIPS ] ជាគោលបំណងនៃបទប្បញ្ញត្តិនេះ ពាក្យថា "ផ្ទុយនឹងការអនុវត្តទៀងត្រង់ក្នុងវិស័យពាណិជ្ជកម្ម" យ៉ាងហោចណាស់មានន័យជាការអនុវត្តនានា ដូចជា ការរំលោភកិច្ចសន្យា ការរំលោភទៅលើទំនុកចិត្ត និងការជម្រុញអោយមានការរំលោភបំពាន ហើយរួមបញ្ចូលនូវការទទួលបានព័ត៌មានសម្ងាត់ដោយតតីយជនដែលបានដឹង ឬមានការធ្វេសប្រហែសយ៉ាងធ្ងន់ធ្ងរដែលមិនអាចដឹងបាន ថាការអនុវត្តន៍បែបនេះពាក់ព័ន្ធនឹងការទទួលបានព័ត៌មាន។

*គ. ជាកម្មវត្ថុនៃវិធានការសមស្របតាមកាលៈទេសៈ របស់បុគ្គលដែលបានសិទ្ធិគ្រប់ គ្រងស្របច្បាប់លើព័ត៌មាននេះ ដើម្បីជាការសម្ងាត់។*

## កថាខណ្ឌទី២៖ អត្ថន័យនៃសេចក្តីព្រាងច្បាប់ស្តីពីព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម

នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងមិនទាន់ចេញជាច្បាប់ ស្តីពីព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្មនៅឡើយទេ គឺមានតែសេចក្តីព្រាងច្បាប់តែប៉ុណ្ណោះ។ ប៉ុន្តែយើងឃើញមានអនុក្រឹត្យ ស្តីពីការសម្ងាត់ពាណិជ្ជកម្ម ដែលមិនទាន់ចូលជាធរមានផងដែរ។ ខាងក្រោមនេះនឹងធ្វើការបកស្រាយអំពីអត្ថន័យរបស់សេចក្តីព្រាងច្បាប់នេះ។

នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានចែងជា ១៩ មាត្រា ហើយគោលការណ៍ និងនិយមន័យគឺទាញយកពីមាត្រា ៣៩ នៃកិច្ចព្រមព្រៀង TRIPS និងការអនុវត្តន៍ពីប្រទេសអភិវឌ្ឍន៍ផ្សេងទៀតដែលបានអនុម័តច្បាប់នេះអស់រយៈពេលយូរមកហើយ ដូចជា សហរដ្ឋអាមេរិក កាណាដា ឬសហភាពអ៊ឺរ៉ុបជាដើម។ គោលបំណងនៃច្បាប់នេះ គឺផ្តល់នូវការការពារដល់ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម និងផ្តល់អនុភាពដល់សេចក្តីសម្រេចស្តីពីការអនុវត្តន៍ កថាខណ្ឌទី៦ នៃសេក្តីប្រកាសទីក្នុង ដូហា ស្តីពីកិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា និងសុខភាពសាធារណៈផងដែរ[16]។ ម្យ៉ាងវិញទៀត ច្បាប់នេះ មិនប៉ះពាល់ទៅដល់អនុភាពគតិយុត្តនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជានោះទេ ប៉ុន្តែគ្របដណ្តប់ទៅលើកាតព្វកិច្ច នៃការរក្សាការសម្ងាត់កើតឡើងទាក់ទិនទៅនឹង ការទទួលបាន ការបង្ហើបបង្ហាញ ឬការប្រើប្រាស់ព័ត៌មានសម្ងាត់តែប៉ុណ្ណោះ[17]។

### វាក្យខ័ណ្ឌទី១៖ ព័ត៌មានសម្ងាត់ សម្រាប់វិញ្ញាបនបត្រអនុញ្ញាតឲ្យចែកចាយលក់ផលិតផលឱសថ និងផលិតផលគីមីសកម្ម

នៅក្នុងផ្នែកនេះ គេបានអោយនិយមន័យទៅលើសារធាតុគីមីមួយចំនួន ដែលអាចមានលទ្ធភាពក្នុងការទទួលបានវិញ្ញាបនបត្រអនុញ្ញាតឲ្យចែកចាយលក់ផលិតផលឱសថ ឬផលិតផលគីមីកសិកម្ម និងកាលបរិច្ឆេទនៃការទទួលបានវិញ្ញាបនបត្រលើអង្គធាតុគីមីថ្មី។ សារធាតុគីមីទាំងអស់នោះមានដូចជា[18]៖

- **សារធាតុសកម្ម:** *ជាម៉ូលេគុល ឬអ៊ីយ៉ុង តែមិនរាប់បញ្ចូលសមាសភាពបន្ថែមនៃម៉ូលេគុលដែលបណ្តាលឲ្យឱសថក្លាយជា អេស្ទែរ និងអំបិល (រួមបញ្ចូលទាំងអំបិលមានសារធាតុអ៊ីដ្រូសែន ឬសារធាតុគីមី*

[16] សេចក្តីព្រាងច្បាប់ស្តីពី ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម, មាត្រា ១។

[17] សេចក្តីព្រាងច្បាប់ស្តីពី ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម, មាត្រា ២។

[18] សេចក្តីព្រាងច្បាប់ស្តីពី ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម, មាត្រា ៦។

*ពាក់ព័ន្ធ) ឬ និទ្ទស្សវត្តគ្មានកូវ៉ាឡង់ផ្សេងទៀត (ដូចជាសមាសធាតុសាំញ៉ាំ បណ្តុំ ម៉ូលេគុល និងក្លាវ៉េត) នៃម៉ូលេគុលដែលទ្រង់ទ្រាយសម្រាប់សកម្មភាពសរីរសាស្ត្រ និងឱសថសាស្ត្រនៃសារធាតុឱសថ។*

- **ជី ឬជាសារធាតុសកម្មនៅក្នុងផលិតផលគ្រប់គ្រងជាតិពុល:** *សារធាតុ ឬការបន្សំនៃសារធាតុ ដែលមានជាតិ នីត្រូហ្សែន ផូស្វរ ប៉ូតាស្យូម ឬអាហាររុក្ខជាតិ ដែលត្រូវបានប្រើប្រាស់ជាសារធាតុបំប៉នរុក្ខជាតិ។*
- **ផលិតផលព្យាបាលរោគ**

  *(ក). ផលិតផលមួយ អង្គធាតុ ឬសារធាតុមួយ ដែលមានផ្ទុកនូវសារធាតុសកម្ម Formulants និង Contaminant ហើយដែលត្រូវបានផលិត ចែកចាយ ឬប្រើប្រាស់ជាមធ្យោបាយក្នុងការពិនិត្យ បំផ្លាញ ទាក់ទាញ ឬ repelling ដោយផ្ទាល់ ឬដោយប្រយោលនូវមេរោគ ឬសម្រាប់បន្ទុ ឬទប់ស្កាត់នូវការឈឺចាប់ ពុល ឬជម្ងឺផ្សេងៗ ទៀត។*

  *(ខ). សារធាតុសកម្មមួយដែលត្រូវបានប្រើប្រាស់ដើម្បីផលិតអ្វីមួយ ដែលមានចែងនៅក្នុងកថាខណ្ឌ (ក) ឬ*

  *(គ). សារធាតុផ្សេងទៀត ដែលត្រូវបានកំណត់ថា ជាផលិតផលព្យាបាលជម្ងឺ។*

- Growth Regulator: *សារធាតុ ឬបន្សំនៃសារធាតុមួយចំនួន ដែលកើនឡើង ថយចុះ ឬផ្លាស់ប្តូរការលូតលាស់តាមលក្ខណៈធម្មតា ឬ ការផលិតឡើងវិញជាធម្មតានៃរុក្ខជាតិ ឬ សត្វ។*
- **អង្គធាតុគីមីថ្មី:**
  - *សម្រាប់ផលិតផលឱសថ ដែលមិនមានសារធាតុសកម្មណាមួយ ដែលត្រូវបានប្រើក្នុងផលិតផលឱសថណាមួយឡើយ។*
  - *សម្រាប់ផលិតផលគីមីកសិកម្ម*

មិនត្រឹមតែប៉ុណ្ណោះ បទប្បញ្ញត្តិនេះក៏បានអោយនិយមន័យទៅលើពាក្យបច្ចេកទេសមួយចំនួនទៀតដែលដូចជា:

- **កិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា:** *សកម្មភាពពិសេស ឬយកចិត្តទុកដាក់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដែលមានវិសាលភាពធំ និងប្រើពេលយូរក្នុងការបង្កើតទិន្នន័យពិសោធន៍ជាសម្ងាត់ ឬ ទិន្នន័យដទៃទៀត។*
- **ការប្រើប្រាស់នៅក្នុងពាណិជ្ជកម្មដោយមិនស្មោះត្រង់:** *ជាការប្រើប្រាស់ ឬបំលែងទិន្នន័យពិសោធន៍ជាសម្ងាត់ ឬទិន្នន័យដទៃទៀត ដោយស្មោះត្រង់ ដើម្បីទទួលបានផលប្រយោជន៍។*

ដើម្បីទទួលបានវិញ្ញាបនបត្រឲ្យចែកចាយនេះផងដែរ ក្រសួងទទួលបន្ទុក (ក្រសួងសុខាភិបាល) ត្រូវផ្តល់ការការពារទល់នឹងការប្រើប្រាស់ទិន្នន័យពិសោធន៍ជាសម្ងាត់ ឬទិន្នន័យដទៃទៀតក្នុងពាណិជ្ជកម្មមិនស្មោះត្រង់ ដែលអ្នកដាក់ស្នើសុំ បានដាក់ជូនពិនិត្យក្នុងពេលបំពេញតាមលក្ខខណ្ឌតម្រូវរបស់ក្រសួងទទួលបន្ទុកនោះ ប្រសិនបើទិន្នន័យនោះ កើតចេញពីកិច្ចខិតខំប្រឹង

ប្រែងយ៉ាងខ្លាំងក្លា។ វិញ្ញាបនបត្រនេះ ទទួលបានការការពាររយៈពេល ៥ ឆ្នាំ ហើយក្រសួងទទួលបន្ទុកមិនត្រូវផ្ដល់ការយល់ព្រមទៅលើពាក្យស្នើសុំថ្មីទៅដល់បុគ្គលម្នាក់ផ្សេងទៀតឡើយ ប្រសិនបើគ្មានការយល់ព្រមពីអ្នកដាក់ពាក្យស្នើសុំដើម[19]។ ម៉្យាងវិញទៀតនោះ មុននឹងចេញវិញ្ញាបនបត្រនេះ ក្រសួងទទួលបន្ទុក ត្រូវធ្វើការស្រាវជ្រាវរកប្រកាសនីយបត្រតក្កកម្មដែលផ្ដល់ឲ្យ ថាតើត្រូវបានចេញឲ្យទៅបុគ្គលណាម្នាក់ហើយ ឬនៅ។ ប្រសិនបើ មានប្រកាសនីយបត្រតក្កកម្មណាមួយដែលទាក់ទង ត្រូវបានចេញឲ្យទៅបុគ្គលណាម្នាក់ក្រៅពីអ្នកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតអោយចែកចាយលក់រួចហើយ ពាក្យសុំនេះមិនត្រូវបានគេយកទៅពិចារណាទេ រហូតដល់កាលបរិច្ឆេទនៃប្រកាសនីយបត្រតក្កកម្មមុន ផុតសុពលភាព[20]។

ក្រសួងទទួលបន្ទុក មិនអាចបង្ហើបបង្ហាញទិន្នន័យពិសោធន៍ជាសម្ងាត់ជាឡើយលុះត្រាតែក្នុងករណីចាំបាច់ដើម្បីការពារផលប្រយោជន៍សាធារណៈ និង មានវិធានការធានាថា ទិន្នន័យទាំងនោះនឹងទទួលបានការការពារទល់នឹងការប្រើប្រាស់ក្នុងពាណិជ្ជកម្មដោយមិនស្មោះត្រង់។ យ៉ាងណាក៏ដោយ ការបង្ហើបបង្ហាញណាមួយ ត្រូវកម្រិតតែផ្នែកនៃទិន្នន័យដែលចាំបាច់សម្រាប់គោលដៅនេះតែប៉ុណ្ណោះ[21]។ លើសពីនេះទៀតនោះ ទោះជាមានប្បញ្ញត្តិចែងយ៉ាងនេះក្ដី ក្រសួងទទួលបន្ទុកអាចទទួលបានការអនុញ្ញាតអោយប្រើទិន្នន័យនោះ ក្នុងករណីមានអាជ្ញាប័ណ្ណបង្ខំ ឬអាជ្ញាប័ណ្ណមិនស្ម័គ្រចិត្ត ដោយអនុលោមតាមច្បាប់ស្ដីពី ការផ្ដល់អាជ្ញាប័ណ្ណបង្ខំសម្រាប់សុខភាពសាធារណៈ[22]។

## **វាក្យខ័ណ្ឌទី២៖ សេចក្ដីប្រកាសនៅទីក្រុង ដូហា ស្ដីពីសុខភាពសាធារណៈ**

ការអនុវត្តន៍កថាខណ្ឌទី ៦ នៃសេចក្ដីប្រកាសទីក្រុង ដូហា ដែលទាក់ទងនឹងបញ្ហានៃការផ្ដល់អាជ្ញាប័ណ្ណបង្ខំសម្រាប់សុខភាពសាធារណៈ[23] ធ្វើអោយឲ្យមានតុល្យភាពក្នុងការអនុវត្តមាត្រា ៣៩(៣) នៃកិច្ចព្រមព្រៀង TRIPS។ ធនាគារពិភពលោក បានធ្វើការកត់សម្គាល់ពីសារៈសំខាន់នៃវត្តមានឱសថ generic ដែលមានតម្លៃថោកនៅកម្ពុជា។ នៅក្នុងការវាយតម្លៃដែលត្រូវបានផ្សព្វផ្សាយនៅខែ កុម្ភៈ ២០០៦ ធនាគារពិភពលោកបានកត់សម្គាល់ឃើញថា ការចំណាយដ៏ច្រើនលើសលុបទៅលើការព្យាបាល និងសេវាកម្មទាក់ទងនឹងសុខភាព អាចជាមូលហេតុជំរុញឲ្យក្រុមគ្រួសារអ្នកជំងឺធ្លាក់ចូលក្នុងភាពក្រីក្រ[24]។ របាយការណ៍នេះបានធ្វើការសម្គាល់បន្តទៀតថា កម្ពុជា

---

[19] សេចក្ដីព្រាងច្បាប់ស្ដីពី ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម, មាត្រា ៧ (១) និង (២)។

[20] ច្បាប់ស្ដីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្ម ឆ្នាំ ២០០៣, មាត្រា ៣ និង ១៣៦។

[21] សេចក្ដីព្រាងច្បាប់ស្ដីពី ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម, មាត្រា៧ (៣)។

[22] សេចក្ដីព្រាងច្បាប់ស្ដីពី ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម, មាត្រា ៧ (៥)។

[23] Frederick M. Abbott, Rudolf V. Van Puymbroeck, *Compulsory Licensing for public Health, A Guide and Model Documents for Implementation of the Doha Declaration Paragraph 6 Decision*, World Bank Working Paper No. 61, 2005.

[24] ការកាត់បន្ថយភាពក្រីក្ររបស់កម្ពុជានៅក្នុងឆ្នាំ ២០១៥? របាយការណ៍វាយតម្លៃលើភាពក្រីក្រ ឆ្នាំ ២០០៦, របាយការណ៍សុខភាពពិភពលោក លេខ ៣៥១៣-KH ចុះថ្ងៃទី ៧ កុម្ភៈ ២០០៦ ទំព័រ ១២៤។ របាយការណ៍នេះបានអោយដឹង

ជាប្រទេសមួយក្នុងចំណោមប្រទេសដ៏តិចតួចនៅលើពិភពលោក ដែលទទួលបានជោគជ័យនៅក្នុងការចែកចាយថ្នាំព្យាបាលមេរោគអេដស៍មិនឲ្យរីរាលដាលដល់អ្នកជម្ងឺ និងសម្រេចគោលបាន ៣/៥ ដែលធានាថា អ្នកជម្ងឺអេដស៍ចំនួន ៣ លាននាក់ នឹងទទួលបានការព្យាបាលអោយអស់នៅឆ្នាំ ២០០៥។ ប៉ុន្តែគោលដៅដំបូង ដែលបានធ្វើឡើងសម្រាប់តែអ្នកកើតរោគអេដស៍តែ ១០,០០០ នាក់ ប៉ុណ្ណោះសម្រាប់កម្ពុជា[25] ហើយចំនួននេះជាភាគរយតិចតួចបំផុតនៃអ្នកឆ្លងមេរោគអេដស៍។ យោងតាមរបាយការណ៍ មូលនិធិ William J. Clinton បានអោយដឹងថា យុវជនផ្ទុកមេរោគអេដស៍ (អាយុពី ១៥ ដល់ ៤៩ឆ្នាំ) មានចំនួន ១២៣ ០០០ នាក់ កុមារដែលត្រូវបានចម្លងមេរោគអេដស៍ ១៥,០០០ នាក់ និងមានក្មេងកំព្រាដែលផ្ទុកមេរោគអេដស៍ចំនួន ៧៧,០០០នាក់ ដោយមានអត្រា prevalence ធៀបជាមួយយុវជនគឺ ១.៩ ភាគរយ[26]។ ធនាគារពិភពលោកក៏បានធ្វើការកត់សម្គាល់ផងដែរ ពីការធ្លាក់ចុះនៃជម្ងឺរបេង ជម្ងឺគ្រុនចាញ់ និងជម្ងឺ រាគរុស។ ប៉ុន្តែ យោយតាមរបាយការណ៍ស្ទង់មតិមួយបានអោយដឹងថា មេភូមិនៅក្នុងភូមិដែលត្រូវធ្វើការព្យាបាលសាកល្បងចំនួន ៩០០ ត្រូវបានសាកសួរនូវអ្វីដែលជាបញ្ហាចំបងផ្នែកសុខភាព និងឱសថប្រភេទណាខ្លះដែលខ្វះខាតនៅក្នុងការដោះស្រាយបញ្ហានេះ[27]។ ជាលទ្ធផលនៃការស្ទង់មតិនេះ គឺគេទាមទារអោយមានសមត្ថភាពក្នុងការដោះស្រាយបញ្ហាបន្ទាន់ៗខាងលើ និងបញ្ហាជម្ងឺផ្តាសាយបក្សី ហើយដែលទាមទារអោយអាជ្ញាធរសុខាភិបាលនៅកម្ពុជា មានលទ្ធភាពនៅក្នុងការចែកចាយឱសថ និងលក់ឱសថនៅក្នុងតម្លៃថោក។

ដំណោះស្រាយចំពោះកង្វះខាតឱសថដែលមានតម្លៃថោក និងមានប្រសិទ្ធិភាពនេះមាននៅក្នុងលក្ខខណ្ឌនៃការចេញអាជ្ញាប័ណ្ណបង្ខំ ដែលមានចែងនៅក្នុងមាត្រា ៣១ នៃកិច្ចព្រមព្រៀង TRIPS ដែលជាបទប្បញ្ញត្តិសំខាន់បំផុតដែលបានកែប្រែដូចខាងក្រោម:

*អ្នកអនិវត្តសិទ្ធិត្រូវធ្វើការខិតខំប្រឹងប្រែងមុនគេបង្អស់ ដោយមូលហេតុពេលវេលា ដើម្បីចចារសុំការអនុញ្ញាតពីម្ចាស់សិទ្ធិលើលក្ខខណ្ឌ និងអាជ្ញាយុកាលពាណិជ្ជកម្ម (មាត្រា ៣១ (ខ));*

*ប៉ុន្តែសមាជិកទាំងឡាយអាចចែកចាយបាន ក្នុងករណីដែលមានការបន្ទាន់ថ្នាក់ជាតិ ឬកាលៈទេសៈផ្សេងទៀតនៃការបន្ទាន់បំផុត ឬនៅក្នុងករណីនៃការប្រើប្រាស់មិនមានលក្ខណៈ មិនមែនពាណិជ្ជកម្មសាធារណៈ (មាត្រា (ច); និង*

*កម្រៃជើងសារដ៏សមរម្យត្រូវបានបង់អោយទៅម្ចាស់សិទ្ធិ (មាត្រា ៣១ (ជ)[28]។*

---

ថា ក្រុមគ្រួសារជាច្រើនអាចត្រូវបានបង្ខំអោយលក់ ឬដាក់បញ្ចាំទ្រព្យគ្រួសាររបស់គេ (ដូចជា ដីធ្លី ឬសត្វចិញ្ចឹម) ឬការដាក់ជួលធម្មតានូវឧបករណ៍ដែលអាចពង្រឹងដល់ជីវភាពគ្រួសារសម្រាប់រយៈពេលខ្លី ឬវែង។

[25] Merges, Menell, Lemley, *Intellectual Property in the New Technoligical Age*, Aspen, 3rd Ed, 2003, ទំព័រ 113។

[26] http://www.clintonfoundation.org/cf-pgm-hs-ai-countries3.htm, (ចូលមើលចុងក្រោយនៅថ្ងៃទី ២៣ ឧសភា ២០១៥)។

[27] Merges, Menell, Lemley, *Intellectual Property in the New Technoligical Age*, Aspen, 3rd Ed, 2003, ទំព័រ ១១០។

[28] Frederick M. Abbott, Rudolf V. Van Puymbroeck, *Compulsory Licensing for public Health, A Guide and Model Documents for Implementation of the Doha Declaration Paragraph 6 Decision*, World Bank Working Paper No. 61, 2005, ទំព័រ ៧-៨។

សេចក្តីប្រកាសទីក្រុង ដូហា ចែងដូចខាងក្រោម៖

*៤. យើងយល់ព្រមថា កិច្ចព្រមព្រៀង TRIPS មិនធ្វើការហាមឃាត់ ឬ/នឹងមិនធ្វើការហាមឃាត់ សមាជិកមិនអោយចាត់វិធានការដើម្បីការពារសុខភាពសាធារណៈឡើយ។ ដូច្នេះ នៅពេលដែលមានការដាក់បញ្ចូលការសន្យារបស់យើងនៅក្នុងកិច្ចព្រមព្រៀង TRIPS យើងអះអាងថា កិច្ចព្រមព្រៀងនេះអាចត្រូវបកស្រាយ និងត្រូវបានអនុវត្តនៅក្នុងលក្ខខណ្ឌមួយ ដែលមានការគាំទ្រសិទ្ធិរបស់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីការពារសុខភាពសាធារណៈ និងជាពិសេសដើម្បីផ្សព្វផ្សាយឱសថ សម្រាប់ប្រទេសសមាជិកទាំងនោះ។ នៅក្នុងចំនុចនេះ យើងសូមអះអាងម្តងទៀតសិទ្ធិរបស់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក ក្នុងការប្រើប្រាស់យ៉ាងពេញលេញនូវបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង TRIPS ដែលចែងពីភាពបទបែននៅក្នុងគោលដៅដើម្បីការពារសុខភាពសាធារណៈនេះ។*

*៥. យោងតាមកថាខណ្ឌទី៤ ខាងលើនេះ ដោយរក្សានូវការសន្យារបស់ពួកយើងនៅក្នុងកិច្ចព្រមព្រៀង TRIPS យើងទទួលស្គាល់នូវភាពបទបែនខាងក្រោមនេះ ៖*

*(ខ). សមាជិកនីមួយៗមានសិទ្ធិក្នុងការផ្តល់អាជ្ញាប័ណ្ណបង្ខំ និងមានសេរីភាពក្នុងការកំណត់នូវមូលដ្ឋាន ក្នុងការចេញអាជ្ញាប័ណ្ណនេះ។*

*(គ). សមាជិកនីមួយៗមានសិទ្ធិក្នុងការកំណត់នូវលក្ខខណ្ឌនៃភាពបន្ទាន់ថ្នាក់ជាតិ ឬកាលៈទេសៈផ្សេងទៀតនៃភាពបន្ទាន់បំផុត ភាពបន្ទាន់ថ្នាក់ជាតិ ឬកាលៈទេសៈដទៃទៀតនៃការបន្ទាន់បំផុត រួមមានវិបត្តិសុខភាពសាធារណៈ ដែលរួមបញ្ចូលទាំងវិបត្តិដែលទាក់ទងទៅនឹងជម្ងឺអេដស៍ របេង គ្រុនចាញ់ និងជម្ងឺឆ្លងផ្សេងៗទៀត...*

សេចក្តីប្រកាសទីក្រុង ដូហា បានរកដំណោះស្រាយដែលត្រូវធ្វើឡើងមុនបំណាច់ឆ្នាំ ២០០២ ប៉ុន្តែការស្វែងរកដំណោះស្រាយនេះ ត្រូវបានអូសបន្លាយពេលរហូតដល់ថ្ងៃទៅ ៣០ ខែសីហា ឆ្នាំ២០០៣ (ដែលជាកាលបរិច្ឆេទមុនកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី Cancun) មុនសេចក្តីសម្រេចដែលទាក់ទងនឹងការអនុវត្តន៍សេចក្តីប្រកាសនេះ ត្រូវបានទទួលយក[29]។

បញ្ហាមួយដែលមិនទាន់បានដោះស្រាយនៅក្នុងសេចក្តីប្រកាសទីក្រុង ដូហា ត្រូវបានកត់ត្រាទុកនៅក្នុងកថាខណ្ឌទី៦ ដែលរាល់សមាជិកទាំងអស់របស់អង្គការពាណិជ្ជកម្មពិភពលោក ដែលពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការផលិត ឬពុំមានសមត្ថភាពផលិតឱសថ អាចប្រឈមមុខនឹងឧបសគ្គនៅក្នុងការប្រើប្រាស់អាជ្ញាប័ណ្ណបង្ខំ ប្រកបដោយប្រសិទ្ធិភាព ក្រោមកិច្ចព្រមព្រៀង TRIPS។ បញ្ហានេះ ត្រូវបានបញ្ជាក់ដូចខាងក្រោមនេះ៖

*ប្រសិនបើប្រទេសកំពុងអភិវឌ្ឍន៍ មិនមានសមត្ថភាពខាងឧស្សាហកម្ម ដើម្បីផលិតឱសថចាំបាច់មួយដោយខ្លួនឯងក្រោមអាជ្ញាប័ណ្ណបង្ខំទេ ឬប្រសិនបើ ប្រទេសនេះមិនមានសមត្ថភាពគ្រប់*

[29] ការអនុវត្តន៍កថាខណ្ឌទី៦ នៃសេចក្តីប្រកាសទីក្រុង ដូហា ស្តីពី TRIPS និងសុខភាពសាធារណៈ ៖ សេចក្តីសម្រេចរបស់អគ្គក្រុមប្រឹក្សា ចុះថ្ងៃទី ៣០ សីហា ២០០៣។

*គ្រាន់ ក្នុងការ ផលិត ប្រទេសនេះមិនមានលទ្ធភាពណាផ្សេងក្រៅពីការនាំចូលឱសថឡើយ។ ប៉ុន្តែ ប្រសិនបើ ប្រទេសនេះចង់ធ្វើការនាំចូលឱសថ generic ដែលត្រូវបានផលិតក្រោមអាជ្ញាប័ណ្ណបង្ខំ ផលិតផលដែលអាចធ្វើការនាំចេញបាន ត្រូវបានកំណត់ត្រឹមការផ្គត់ផ្គង់ក្នុងទីផ្សារក្នុងស្រុកតែ ប៉ុណ្ណោះ ដែលមានលក្ខខណ្ឌនេះមានចែងនៅក្នុងកថាខណ្ឌ (ច) នៃមាត្រា ៣១ របស់ TRIPS[30]។*

ប្រទេសជាច្រើន ដូចជា ប្រទេសឥណ្ឌា ប្រេស៊ីល និងប្រទេសចិន ត្រូវបានគេដឹងថាមានឧស្សាហកម្ម generic ក្នុងស្រុកជាច្រើនទៀត ហើយអាចធានាការផលិត បើទោះបីជាមានការកម្រិតដោយ មាត្រា ៣១ (ច) របស់ TRIPS ក៏ដោយ។ ប្រទេសឥណ្ឌា បានបង្កើតដោយខ្លួនឯងនូវអ្នកផ្គត់ផ្គង់ដ៏សំខាន់បំផុតខាងផ្នែកឱសថ generic ទៅឲ្យបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានានៅលើពិភពលោក[31]។ ថ្វីបើប្រទេសឥណ្ឌាធ្វើការនាំចេញនូវផលិតផលឱសថ generic របស់ខ្លួនតែ ២០ ភាគរយក៏ដោយ ក៏បរិមាណនេះបញ្ជាក់អោយឃើញថា ប្រទេសឥណ្ឌា បានផ្គត់ផ្គង់ឱសថចំនួន ៦៧ ភាគរយ ដែលត្រូវបានទិញដោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានា[32]។ នៅប្រទេស ប្រេស៊ីល ផលិតផលឱសថនៅក្នុងស្រុកប្រឆាំងវីរុស ត្រូវបានភ្ជាប់ដោយផ្ទាល់នៅក្នុង គម្រោងស្តីពីសុខភាពសាធារណៈរបស់ ប្រេស៊ីល នៅឆ្នាំ ១៩៩៦។ នៅក្នុងឆ្នាំ ២០០៥ នៅប្រេស៊ីល មានក្រុមហ៊ុនឱសថប្រមាណជា ៣៧០ ដែលក្នុងនោះមានក្រុមហ៊ុនចំនួន ២៩៦ ជាក្រុមហ៊ុនក្នុងស្រុក និង ៧៤ ក្រុមហ៊ុន ជាកម្មសិទ្ធិរបស់បរទេស។ ប្រេស៊ីល ត្រូវបានគេរាយការណ៍ថា ជាទីផ្សារឱសថដែលធំជាងគេបង្អស់ទី ១១ នៅលើពិភពលោក។ នៅប្រទេសចិន ឧស្សាហកម្មឱសថ ត្រូវបានគេរាយការណ៍ថា

[30] Frederick M. Abbott, Rudolf V. Van Puymbroeck, *Compulsory Licensing for public Health, A Guide and Model Documents for Implementation of the Doha Declaration Paragraph 6 Decision*, World Bank Working Paper No. 61, 2005, ទំព័រ ៨-៩។

[31] Sorcha O'Carroll, ការនាំចេញឱសថ generic របស់ឥណ្ឌា ស្របតាមកិច្ចព្រមព្រៀង TRIPS : ករណីសិក្សាពី Zambia និង Kenya, http://www.law.utoronto.ca/accesstodrugs/resource.htm,, ២៨ មេសា ២០០៥ April 28th, (ចូលមើលចុងក្រោយនៅថ្ងៃទី ២០ ឧសភា ២០១៥), ទំព័រ ១។ ការធ្វើវិសោធនកម្មរបស់ ឥណ្ឌា ទៅលើច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម ដើម្បីឲ្យស្របតាមកិច្ចព្រមព្រៀង TRIPS និងឥទ្ធិពលនេះនឹងផ្តល់ផលឲ្យអ្នកផលិតឱសថ generic របស់ប្រទេសឥណ្ឌាវិញ។ ការអនុវត្តតាមប្រព័ន្ធ Mailbox របស់ប្រទេសនេះ ធ្វើឲ្យមានហានិភ័យចំពោះផលិតផលឱសថ generic មួយចំនួន ដែលត្រូវបានចុះបញ្ជីនៅថ្ងៃទី ១ មករា ១៩៩៥។

[32] Sasha Kontic, ដែលជាអ្នកវិភាគលើក្រុមហ៊ុនឱសថ generic នៅប្រទេស ប្រេស៊ីល និងចិន នៅក្នុងបរិបទនៃកិច្ចព្រមព្រៀង TRIPS និង HIV/AIDS, http://www.law.utoronto.ca/accesstodrugs/resources.htm, មេសា ២០០៥, (ចូលមើលចុងក្រោយនៅថ្ងៃទី ២៥ ឧសភា ២០១៥), ទំព័រ ៤។ យោងតាមការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មក្រោយថ្ងៃទី ១ មករា ១៩៩៥ : ឥណ្ឌាបានធ្វើការបើកឲ្យមានប្រព័ន្ធ Mailbox នៅថ្ងៃទី ១ មករា ២០០៥ ហើយការិយាល័យប្រកាសនីយបត្រតក្កកម្មរបស់ឥណ្ឌា ត្រូវត្រួតពិនិត្យមើលការដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មចំនួន ៨,៩២៦ ដែលត្រូវការប្រកាសនីយបត្រតក្កកម្មរយៈពេលវែងសម្រាប់ឱសថ និងសម្ភារៈសុខាភិបាល។ ជាការល្អ នៅក្នុងករណីការព្យាបាលមេរោគអេដស៍/HIV ឱសថដែលត្រូវបានការប្រើក្នុងការព្យាបាលលើដំបូង មានប្រកាសនីយបត្រតក្កកម្មមុនឆ្នាំ ១៩៩៥ ហើយកិច្ចព្រមព្រៀងTRIPS មិនជះឥទ្ធិពលអ្វីដល់ការផលិតផល generic នៅឥណ្ឌាឡើយ។ ប៉ុន្តែ នៅពេលដែលមានការទាមទារឱសថសម្រាប់ព្យាបាលជម្ងឺអេដស៍ ដែលមានប្រកាសនីយបត្រតក្កកម្មក្រោយឆ្នាំ ១៩៩៥ មានការកើនឡើង ការគ្រប់គ្រងលើតម្លៃដើមរបស់ឱសថ generic នៅក្នុងការប្រកួតប្រជែងនៅឥណ្ឌា នឹងមិនមានទៀតឡើយ, ទំព័រ ៥។

បានកើនឡើង ១៧.៥ ភាគរយ ចាប់តាំងពីឆ្នាំ ១៩៧៩ ដោយមានអ្នកផលិតច្រើនជាង ៧,៥០០ ដែលក្នុងនោះផលិតផល ៩៧ ភាគរយ ជាផលិតផលឱសថ generic។

បញ្ហាដែលចោទឡើងគឺថា ក្រុមហ៊ុនឱសថ generic ជាច្រើនមិនអាចផ្គត់ផ្គង់ឱសថដល់កម្ពុជា ឬប្រទេសផ្សេងទៀតដែលមានវិបត្តិខាងការបន្ទាន់ផ្នែកសុខភាព ហើយដែលមិនមានសមត្ថភាពក្នុងការផលិតឱសថ generic។ សេចក្តីសម្រេចរបស់អគ្គក្រុមប្រឹក្សា មានគោលដៅដោះស្រាយបញ្ហានេះ ដោយបញ្ជាក់ថា:

*កាតព្វកិច្ចទាំងឡាយរបស់ប្រទេសនាំចេញ ដែលមានចែងនៅក្នុងមាត្រា ៣១ (ច) នៃកិច្ចព្រមព្រៀង TRIPS ត្រូវបានលើកលែង ចំពោះការផ្តល់អោយសមាជិកនេះ នូវអាជ្ញាប័ណ្ណបង្ខំក្នុងការពន្យាដែលមានការចាំបាច់ដើម្បីផលិតឱសថ និងការនាំចេញរបស់ខ្លួនទៅកាន់ប្រទេសដែលមានសិទ្ធិនាំចូល ដោយយោងតាមលក្ខខណ្ឌដែលត្រូវបានកំណត់ ក្នុងកថាខណ្ឌដូចខាងក្រោមនេះ ៖*

*(ក). ប្រទេសដែលមានសិទ្ធិនាំចូល បានជូនដំណឹងទៅកាន់ក្រុមប្រឹក្សាទទួលបន្ទុកលើកិច្ចព្រមព្រៀង TRIPS ដែល:*

*i. បញ្ជាក់ពីឈ្មោះ បរិមាណកំណត់នៃផលិតផលដែលត្រូវការ*

*ii. អះអាងថា ប្រទេសដែលមានសិទ្ធិនាំចូល ក្រៅពីសមាជិកប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផលិត ឬមិនមានសមត្ថភាពផលិតផលិតផលឱសថតាមមធ្យោបាយណាមួយដែលត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានេះ និង*

*iii. អះអាងថា នៅក្នុងករណីដែលផលិតផលឱសថមួយមានប្រកាសនីយបត្រតក្កកម្ម នៅក្នុងប្រទេសនាំចូល ប្រទេសនេះត្រូវផ្តល់ឲ្យ ឬមានបំណងនឹងផ្តល់ឲ្យអាជ្ញាប័ណ្ណបង្ខំ ដោយស្របតាមមាត្រា ៣១ នៃកិច្ចព្រមព្រៀង TRIPS និងបទប្បញ្ញត្តិផ្សេងៗទៀតនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានេះ។*

*(ខ). អាជ្ញាប័ណ្ណបង្ខំដែលចេញដោយប្រទេសនាំចេញ ស្របតាមសេចក្តីសម្រេចនេះ ត្រូវកំណត់លក្ខខណ្ឌដូចខាងក្រោម:*

*i. មានតែបរិមាណចាំបាច់ ដែលត្រូវបំពេញតាមតម្រូវការនៃប្រទេសដែលមានសិទ្ធិនាំចូលទើបផលិតផលឱសថនេះអាចត្រូវបានផលិតក្រោមអាជ្ញាប័ណ្ណនេះ ហើយផលិតផលឱសថទាំងអស់នេះនឹងត្រូវនាំចេញទៅកាន់បណ្តាប្រទេស ដែលបានជូនដំណឹងពីតម្រូវការរបស់ពួកគេទៅអោយក្រុមប្រឹក្សាទទួលបន្ទុកលើកិច្ចព្រមព្រៀង TRIPS*

*ii. ផលិតផលឱសថដែលបានផលិតក្រោមអាជ្ញាប័ណ្ណនេះ ត្រូវកំណត់យ៉ាងច្បាស់លាស់ថាត្រូវបានផលិតក្រោមប្រព័ន្ធមួយ ដែលកំណត់ដោយសេចក្តីសម្រេចនេះ តាមរយៈការបិទម៉ាក ឬការបិទផ្លាកយីហោច្បាស់លាស់។ អ្នកផ្គត់ផ្គង់ ត្រូវធ្វើការបែងចែកនូវផលិតផលទាំងនេះ តាមរយៈការវេចខ្ចប់ជាពិសេស និង/ឬ តាមរយៈទម្រង់ ការលាបពណ៌ច្បាស់លាស់លើ*

*ផលិតផលទាំងនេះ ហើយត្រូវធ្វើយ៉ាងណាអោយគេឃើញថា មានភាពខុសគ្នាពិតប្រាកដ ហើយការធ្វើបែបនេះមិនធ្វើអោយប៉ះពាល់ទៅលើតម្លៃឡើយ និង*

*iii. មុនពេលចាប់ផ្តើមធ្វើការដឹកជញ្ជូន អ្នកទទួលអាជ្ញាប័ណ្ណត្រូវប្រកាសលើគេហទំព័រនូវព័ត៌មាន ដូចខាងក្រោម:*

- *បរិមាណដែលត្រូវផ្គត់ផ្គង់ទៅដល់គោលដៅ ដូចដែលមានចែងនៅក្នុងចំណុច (i) ខាងលើ*
- *ការធ្វើអោយឃើញពីភាពខុសប្លែកគ្នានៃលក្ខណៈផលិតផលឱសថ ដូចដែលមានចែងនៅក្នុងចំណុច (ii) ខាងលើ។*

*(គ). សមាជិកនាំចេញត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាទទួលបន្ទុកលើកិច្ចព្រមព្រៀង TRIPS ពីការចេញអាជ្ញាប័ណ្ណ ដោយរួមបញ្ចូលទាំងលក្ខខណ្ឌភ្ជាប់ជាមួយអាជ្ញាប័ណ្ណនេះផងដែរ។ ព័ត៌មានផ្តល់អោយនេះត្រូវភ្ជាប់មកជាមួយនូវ ឈ្មោះ និងអាស្រ័យដ្ឋានរបស់អ្នកទទួលអាជ្ញាប័ណ្ណ ផលិតផលមានអាជ្ញាប័ណ្ណ បរិមាណផលិតផលឱសថដែលត្រូវផ្គត់ផ្គង់អោយដល់គោលដៅ និងអាជ្ញាយុកាលនៃអាជ្ញាប័ណ្ណនេះ។ ការជូនដំណឹងត្រូវបញ្ជាក់ផងដែរ នូវអាស័យដ្ឋានគេហទំព័រដូចដែលមានចែងនៅក្នុងចំនុច (ខ)(iii) ខាងលើ។*

តាមពិត អ្វីដែលបានបង្កើតក្រោមកថាខណ្ឌទី៦ នៃសេចក្តីប្រកាសទីក្រុង ដូហា គឺជាការហាមឃាត់ទៅលើការកំណត់នូវបរិមាណលើសលុបសម្រាប់ទីផ្សារក្នុងស្រុកចំពោះប្រទេសនាំចេញ និងជាការហាមឃាត់លើការបង់កម្រៃសមស្របអោយប្រទេសនាំចូល[33]។ ការហាមឃាត់លើការបង់កម្រៃសមស្របនឹងត្រូវបានបង់នៅក្នុងប្រទេសនាំចេញ ហើយកម្រៃជើងសារនេះត្រូវគិតដល់ **តម្លៃខាងសេដ្ឋកិច្ចរបស់ប្រទេសដែលនាំចូលនូវការប្រើប្រាស់ដែលត្រូវបានអនុញ្ញាតនីក្នុងប្រទេសនាំចេញ**។ ប៉ុន្តែ ពុំមានការបញ្ជាក់ណាមួយត្រូវបានផ្តល់អោយចំពោះការអនុវត្តន៍តាមស្តង់ដារនោះទេ។ ការជូនដំណឹង និងលក្ខខណ្ឌផលិតកម្ម ត្រូវបានដាក់ឲ្យអនុវត្តក្រោមប្រព័ន្ធនេះ ហើយការជូនដំណឹង និងលក្ខខណ្ឌផលិតកម្មទាំងនោះរួមមាន:

*(ក). ប្រទេសនាំចូលត្រូវតែជាសមាជិកនៃបណ្តាប្រទេសដែលមានសិទ្ធិនាំចូល ដែលមានន័យថាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ឬសមាជិកដែលបានជូនដំណឹងដល់ក្រុមប្រឹក្សាទទួលបន្ទុកលើកិច្ចព្រមព្រៀង TRIPS ពីភាពបន្ទាន់ខាងសុខភាព។*

*(ខ). ប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូល ត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាទទួលបន្ទុកលើកិច្ចព្រមព្រៀង TRIPS ដែលជាការជូនដំណឹងនេះរួមមាន:*

*i. ឈ្មោះ និងបរិមាណផលិតផលដែលបានគ្រោងទុក*

*ii. ប្រសិនបើ ប្រទេសមួយមិនមែនជាសមាជិកនៃប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ប្រទេសនោះ ត្រូវបញ្ជាក់ថា (ដោយស្របតាមវិធីសាស្រ្តដែលមានកំណត់នៅ*

---

[33] Sasha Kontic, ដែលជាអ្នកវិភាគលើក្រុមហ៊ុនឱសថ generic នៅប្រទេស ប្រស៊ីល និងចិន នៅក្នុងបរិបទនៃកិច្ចព្រមព្រៀង TRIPS និង HIV/AIDS, http://www.law.utoronto.ca/accesstodrugs/resources.htm, ទំព័រ ៩។

*ក្នុងឧបសម្ព័ន្ធ) ខ្លួនពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផលិត ឬពុំមានសមត្ថភាពផលិតឱសថបាន*

iii. *ការអះអាងថា ប្រទេសជាសមាជិកបានផ្តល់អាជ្ញាប័ណ្ណបង្ខំមួយ ប្រសិនបើប្រកាសនីយបត្រតក្កកម្មមាននៅក្នុងប្រទេសនាំចូលហើយ។*

*(គ). ប្រទេសនាំចេញ ត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាទទួលបន្ទុកលើកិច្ចព្រមព្រៀង TRIPS ពីការផ្តល់អាជ្ញាប័ណ្ណបង្ខំនេះ ដោយភ្ជាប់មកជាមួយនូវលក្ខខណ្ឌដែលផ្តល់ព័ត៌មានទាក់ទងនឹងអាជ្ញាប័ណ្ណ ផលិតផល និងបរិមាណឱសថ គោលដៅ អាជ្ញាយុកាលអាជ្ញាប័ណ្ណ និងគេហទំព័រ ដែលផ្តល់នូវព័ត៌មានជាក់លាក់អំពីផលិតផលនេះ។*

*(ឃ). អាជ្ញាប័ណ្ណបង្ខំត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម:*

i. *មានតែបរិមាណផលិតផលចាំបាច់ ដែលត្រូវផ្គត់ផ្គង់តាមតម្រូវការរបស់ប្រទេសដែលមានសិទ្ធិនាំចូលប៉ុណ្ណោះ ទើបអាចត្រូវបានផលិត ហើយផលិតឱសថទាំងនេះត្រូវនាំចេញទៅកាន់ប្រទេសនោះ។*

ii. *ផលិតផល ត្រូវបានកំណត់អត្តសញ្ញាណយ៉ាងច្បាស់លាស់ តាមរយៈការដាក់ឈ្មោះយីហោ ឬការបិទម៉ាក។*

iii. *អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវផ្សព្វផ្សាយនៅលើគេហទំព័របរិមាណផលិតផល ដែលត្រូវផលិត និងកំណត់ អត្តសញ្ញាណផលិតផលអោយបានច្បាស់លាស់*[34] *។*

ការកម្រិតលើការនាំចេញជាថ្មីម្តងទៀតពីសំណាក់សមាជិកនាំចូល ត្រូវបានហាមឃាត់នៅក្នុងករណីមួយចំនួន។ ឧទាហរណ៍ នៅក្នុងករណីមានកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ លក្ខខណ្ឌផលិតកម្មសម្រាប់តំបន់ទាំងមូល អាចត្រូវបានគេពិចារណា ប្រសិនបើតំបន់ទាំងមូលកំពុងទទួលរងផលប៉ះពាល់ពីបញ្ហាសុខភាពដូចគ្នា។ ប៉ុន្តែកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្នាក់តំបន់ ត្រូវមានការទទួលស្គាល់ពីអង្គការពាណិជ្ជកម្មពិភពលោក ហើយយ៉ាងហោចណាស់សមាជិកពាក់កណ្តាលជា **ប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ដែលត្រូវចុះបញ្ជីជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចនៅអង្គការសហប្រជាជាតិ នៅថ្ងៃអនុម័តសេចក្តីសំរេចនេះ**[35]។ តាមការអនុវត្តជាក់ស្តែង លក្ខខណ្ឌនេះក៏រួមបញ្ចូលទាំងកិច្ចព្រមព្រៀងថ្នាក់តំបន់នៅ អាហ្វ្រិក ផងដែរ ប៉ុន្តែសមាជិកដែលត្រូវនាំចូលឱសថទាំងអស់ ត្រូវមានអាជ្ញាប័ណ្ណបង្ខំមួយ។ គេអាចធ្វើការកត់សម្គាល់បានថា ត្រូវបានផ្តល់ដោយភ្ជាប់មកជាមួយនៅក្នុងសេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សា ដូចខាងក្រោមនេះ៖

*ទីមួយ: សមាជិកទាំងអស់ទទួលស្គាល់ថា ប្រព័ន្ធដែលនឹងត្រូវបានបង្កើតឡើងដោយសេចក្តីសំរេចនេះ នឹងត្រូវយកទៅប្រើប្រាស់ដោយសុច្ឆរិតក្នុ ងកិច្ចការពារសុខភាពសាធារណៈ និងដោយមិនរាប់*

---

[34] Sasha Kontic, ដែលជាអ្នកវិភាគលើក្រុមហ៊ុនឱសថ generic នៅប្រទេស ប្រស៊ីល និងចិន នៅក្នុងបរិបទនៃកិច្ចព្រមព្រៀង TRIPS និង HIV/AIDS, http://www.law.utoronto.ca/accesstodrugs/resources.htm,, មេសា ២០០៥, ទំព័រ ១០-១១។

[35] Frederick M. Abbott, Rudolf V. Van Puymbroeck, *Compulsory Licensing for public Health, A Guide and Model Documents for Implementation of the Doha Declaration Paragraph 6 Decision*, World Bank Working Paper No. 61, 2005, ទំព័រ ១០។

*បញ្ចូលកថាខណ្ឌទី៦ នៃសេចក្តីសំរេចនេះ។ សមាជិកទាំងឡាយ មិនត្រូវប្រើប្រាស់ប្រព័ន្ធនេះ ជាឧបករណ៍ក្នុងគោលបំណងនយោបាយសេដ្ឋកិច្ច ឬឧស្សាហកម្មឡើយ។*

*ទីពីរ: សមាជិកទទួលស្គាល់ថា បំណងរបស់សេចក្តីសំរេចនេះ នឹងមិនត្រូវបានយកទៅអនុវត្តទេ ប្រសិនបើ ផលិតផលឱសថដែលត្រូវចែកចាយក្រោមសេចក្តីសំរេចនេះ ត្រូវបានបំផ្លែងអោយខុសពីការដាក់លក់នៅលើទីផ្សារ របស់ប្រទេសដែលផលិតផលនោះ ត្រូវចែកចាយនោះ*[36]។

សេចក្តីប្រកាសទីក្រុង ដូហា ស្តីពីសុខភាពសាធារណ: មិនមានគោលដៅដើម្បីធ្វើជាឧបករណ៍នយោបាយឧស្សាហកម្ម ដែលអនុញ្ញាតអោយកើតមាននូវការធ្វើពាណិជ្ជកម្មផ្គត់ផ្គង់ឱសថ generic នៅក្នុងស្រុកដែលមិនមានពីមុនមកនេះទេ។ ដូចគ្នាដែរ សេចក្តីប្រកាសនេះមិនមានគោលដៅបង្កើតទីផ្សារសម្រាប់ការនាំចេញជាថ្មីនៃឱសថ generic ទៅក្នុងអនុក្រុមក្នុងតំបន់ឡើយ។

នៅថ្ងៃទី ៣០ សីហា ២០០៣ សេចក្តីសំរេចនេះត្រូវបានរិះគន់ថា នឹងបរាជ័យព្រោះមិនបានចែកចាយឱសថអោយបានគ្រប់ចំនួន ឬការប្រើប្រាស់ឱសថ[37]។ ឥណ្ឌា និងប្រស៊ីល គឺជាប្រភពឱសថ generic ដ៏សំខាន់សម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

អ្នករិះគន់ទាំងនេះបានអះអាងទៀតថា យន្តការនេះមិនសមស្រប និងមិនបង្កើតលក្ខខណ្ឌចាំបាច់សម្រាប់ពាណិជ្ជកម្ម ដើម្បីទាក់ទាញនូវអ្នកផលិត generic ឡើយ។ ក្រុមគ្រូពេទ្យគ្មានព្រំដែន អះអាងថា លក្ខខណ្ឌនៃការចរចារជាអទិភាពសម្រាប់អាជ្ញាប័ណ្ណ ត្រូវបានគេយល់ឃើញថា ជាប្រភពមួយនៃការ ពន្យាពេល នៅពេលដែលការចរចារមុនគេដើម្បីសុំអាជ្ញាប័ណ្ណ ត្រូវបានគេយល់ឃើញថា ជាការខ្ជះខ្ជាយពេលវេលា និងថវិកា[38]។ វិធានការប្រឆាំងនិងការបំផ្លែង ដែលផលិតឱសថនឹងត្រូវបានលក់តែនៅក្នុងទីផ្សារគោលដៅតែប៉ុណ្ណោះ ត្រូវបានគេយល់ឃើញថា ជាការបំបាក់ទឹកចិត្តចំពោះអ្នកផលិត generic មិនអោយចូលរួមក្នុងការលក់ ឬផលិតឱសថ។ ការជូនដំណឹងទៅក្រុមប្រឹក្សាទទួលបន្ទុកលើកិច្ចព្រមព្រៀង TRIPS សម្រាប់ប្រទេសនាំចូល អាចជាការបំបាក់ទឹកចិត្តចំពោះប្រទេសដែលមិនមែនជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ដោយសារតែព័ត៌មានបន្ថែមដែលត្រូវបានផ្តល់អោយ ស្របតាមសមត្ថភាពផលិតឱសថ generic នៅក្នុងប្រទេសនេះ។ សេចក្តីសំរេចនេះ ត្រូវបានគេយល់ឃើញថា មិនអាចអនុវត្តបាននៅក្នុងការចេញនូវសេចក្តីសំរេចតាមផលិតផល តាមប្រទេស និងតាមករណី ដែលតម្រូវអោយមានការកំណត់អត្តសញ្ញាណជាក់លាក់

---

[36] Frederick M. Abbott, Rudolf V. Van Puymbroeck, *Compulsory Licensing for public Health, A Guide and Model Documents for Implementation of the Doha Declaration Paragraph 6 Decision*, World Bank Working Paper No. 61, 2005, ទំព័រ ១១។

[37] Frederick M. Abbott, Rudolf V. Van Puymbroeck, *Compulsory Licensing for public Health, A Guide and Model Documents for Implementation of the Doha Declaration Paragraph 6 Decision*, World Bank Working Paper No. 61, 2005, ទំព័រ ៥៧។ សេចក្តីដកស្រង់ចេញពីកិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សា នៅថ្ងៃទី ៣០ សីហា ២០០៣ (WT/GC/M/82, ១៣ វិច្ឆិកា ២០០៣, កថាខណ្ឌទី២៩)។

[38] ក្រុមគ្រូពេទ្យគ្មានព្រំដែន, *Neither Expeditious, nor a Solution : សេចក្តីសំរេចរបស់អង្គការ WTO ចុះថ្ងៃទី ៣០ សីហា មិនអាចអនុវត្តបានឡើយ, ខែ សីហា ២០០៦* : http://accessmed-msf.org/documents/WTOaugustreport.pdf។

ចំពោះប្រទេសគោលដៅ និងគុណភាពឱសថ។ ការបង្ហាញនេះ ត្រូវបានគេយល់ឃើញថា ជាការបំបាក់ទឹកចិត្តយ៉ាងខ្លាំងចំពោះអ្នកផលិតឱសថ។ ការស្នើសុំ ត្រូវធ្វើម្តងហើយម្តងទៀត នៅពេលដែលអ្នកផលិតឱសថស្វែងរកការអនុញ្ញាត សម្រាប់នាំចេញផលិតផលឱសថ ហើយការស្នើសុំបែបនេះ មិនបានផ្តល់ទីផ្សារបិតថេរ សម្រាប់អ្នក ផលិតឱសថដើម្បីធ្វើដំណើរការផលិត ឬចែកចាយឱសថឡើយ។ ជាបញ្ចប់ គ្រូពេទ្យគ្មានព្រំដែន បានធ្វើការសន្និដ្ឋានថា សេចក្តីសំរេចនេះធ្វើអោយមានគុណវិបត្តិ ដោយសារសេចក្តីសំរេចនេះធ្វើអោយមានភាពយឺតយ៉ាវ ប៉ុន្តែសេចក្តីសំរេចនេះនៅតែអនុវត្តបន្តនូវជំហាននៃនីតិវិធីដ៏ស៊ាំញ៉ាំដដែល[39]។

## ខ.វាក្យខណ្ឌទី៣៖ អនុក្រឹត្យស្តីពី ការសម្ងាត់ពាណិជ្ជកម្ម

យោងតាមនិយមន័យ ការអនុវត្តការសម្ងាត់ពាណិជ្ជកម្មទាក់ទងនឹងសកម្មភាពឯកជន មិនមែនទាក់ទងនឹងស្ថាប័នរដ្ឋាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជាទេ។ ច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម មានជំហរផ្ទាល់ខ្លួន និងបង្កើតបានជាក្រមពេញលេញមួយ។ អនុក្រឹត្យដែលទាក់ទងនឹងការសម្ងាត់ពាណិជ្ជកម្មនេះ មិនត្រូវបានរៀបចំឡើងដើម្បីផ្តល់នៅគោលការណ៍ណែនាំដល់ស្ថាប័នយុត្តាធិការ ដើម្បីសម្រុះស្រួលក្នុងការបកស្រាយច្បាប់ ហើយគោលការណ៍ណែនាំទាំងនេះ ត្រូវបានបញ្ចូលទៅក្នុងសេចក្តីព្រាងអនុក្រឹត្យនេះ។ ដូចអ្វីដែលអនុក្រឹត្យនេះមិនបានបន្ថែមវិធានគតិយុត្តផ្ទាល់ខ្លួន វាអាចត្រូវបានបែងចែកពី អនុក្រឹត្យដែលទាក់ទងនឹង ការបង្ហើបបង្ហាញព័ត៌មានក្នុងការលក់ផលិតផលឱសថ ឬសារធាតុគីមីកសិកម្ម ដែលចែងពីវិធានបច្ចេកទេសដើម្បីបន្ថែមលើច្បាប់ដែលទាក់ទងនឹងបញ្ហាទាំងនេះ។ បទប្បញ្ញត្តិ ឬសារធាតុគីមីកសិកម្ម ដែលចែងពីវិធានបច្ចេកទេសដើម្បីបន្ថែមលើច្បាប់ដែលទាក់ទងនឹងបញ្ហាទាំងនេះ។ បទប្បញ្ញត្តិដែលទាក់ទងនឹងការសម្ងាត់ពាណិជ្ជកម្ម អាចត្រូវបានរកឃើញក្នុងជំពូក ៤ នៃអនុក្រឹត្យស្តីពីការអនុវត្តន៍ច្បាប់ ស្តីពីព័ត៌មាន និងការសម្ងាត់ពាណិជ្ជកម្ម។

[39] ក្រុមគ្រូពេទ្យគ្មានព្រំដែន, *Neither Expeditious, nor a Solution : សេចក្តីសំរេចរបស់អង្គការ WTO ចុះថ្ងៃទី ៣០ សីហា មិនអាចអនុវត្តបានឡើយ, ខែ សីហា ២០០៦* : http://accessmed-msf.org/documents/WTOaugustreport.pdf។ តារាងនៃជំហានទាំង ១១ ដែលត្រូវបានផ្តល់ឲ្យដោយ លោក Geoff Blackie, *Breathing Life into to the August 30th, Agreement*, ខែ សីហា ឆ្នាំ ២០០៦ http://www.utoronto.ca/accesstodrugs/resources.htm ទំព័រ ៥, (ចូលមើលចុងក្រោយនៅថ្ងៃទី ២៩ មេសា ២០១៥)។

# ជំពូកទី២៖ ទម្រង់នៃការការពារការសម្ងាត់ពាណិជ្ជកម្ម

ទម្រង់នៃការការពារការសម្ងាត់ពាណិជ្ជកម្ម បកស្រាយលើការការពារការសម្ងាត់ពាណិជ្ជម្ម ដោយផ្អែកច្បាប់នៅក្នុងប្រទេសនីមួយៗ ថាតើវិធានច្បាប់នៅក្នុងប្រទេសទាំងនោះ ផ្តល់ការអនុគ្រោះយ៉ាងណាខ្លះ។

## ផ្នែកទី១៖ ទម្រង់នៃការការពារការសម្ងាត់ពាណិជ្ជកម្មក្រោមក្របខណ្ឌអន្តរជាតិ

នៅក្នុងទម្រង់នៃការការពារអន្តរជាតិនេះ មិនមានការបកស្រាយទៅលើប្រទេសនឹងស្ថាប័ន ដែលបានអនុវត្តការសម្ងាត់ពាណិជ្ជកម្មជាយូរមកហើយ គឺ សហមន៍អ៊ឺរ៉ុប និងសហរដ្ឋអាមេរិក។ ស្របពេលជាមួយគ្នានេះ នឹងធ្វើការប្រៀបធៀបជាមួយប្រទេសកម្ពុជា ដែលជាប្រទេសមានការអភិវឌ្ឍន៍តិចតួច និងមិនទាន់មានអនុវត្តទម្រង់នេះនៅឡើយ។

### កថាខណ្ឌទី១៖ ទម្រង់នៃការការពារនៅក្រោមក្របខ័ណ្ឌសហគមន៍អ៊ឺរ៉ុប

សហគមន៍សេដ្ឋកិច្ចអ៊ឺរ៉ុប (The European Economic Community "EEC") ត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញាទីក្រុងរ៉ូម (the "Treaty of Rome") ឆ្នាំ ១៩៥៧។ គោលដៅចំបងរបស់សហគមន៍សេដ្ឋកិច្ច អ៊ឺរ៉ុបគឺ ដើម្បីផ្តល់ចំណងសេដ្ឋកិច្ចជិតស្និទ្ធ និងតំណបណ្តាញពន្ធគយតែមួយ រវាងរដ្ឋជាភាគីនៅក្នុងសហគមន៍នេះ។ នៅក្នុងឆ្នាំ ១៩៨៦ រដ្ឋជាភាគីទាំង ១២ របស់ EEC បានចុះហត្ថលេខាទៅលើច្បាប់ Single European Act "*SEA*"។ គោលដៅចំបងរបស់ SEA គឺដើម្បីលប់បំបាត់របាំងទាំងឡាយលើទីផ្សារផ្ទៃក្នុងរបស់ EEC តាមរយៈ ការធ្វើឲ្យមានភាពស៊ីសង្វាក់គ្នានៃនីតិបញ្ញត្តិ (legislative harmonization)។

សហភាពអ៊ឺរ៉ុប ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩២ ដោយសន្ធិសញ្ញា Maastricht ស្តីពីសហភាពអ៊ឺរ៉ុប "Maastricht Treaty"។ សន្ធិសញ្ញា Maastricht នេះ បានប្តូរឈ្មោះ EEC ទៅជា សហគមន៍អ៊ឺរ៉ុប (The European Community "EC")។ សន្ធិសញ្ញា Amsterdam ឆ្នាំ ១៩៩៩ បានធ្វើវិសោធនកម្មលើ សន្ធិសញ្ញា Maastricht និងសន្ធិសញ្ញាទីក្រុងរ៉ូម។ លើសពីនេះទៅទៀត សន្ធិសញ្ញាទីក្រុងនីស (the "Treaty of Nice") ឆ្នាំ ២០០១ បានធ្វើវិសោធនកម្មទៅសន្ធិសញ្ញាទាំងអស់ ដូចដែលបានរៀបរាប់ខាងលើ។ យោងទៅលើការធ្វើវិសោធនកម្មខាងលើ កំណែរួមនៃសន្ធិសញ្ញាទីក្រុងនីស ត្រូវបាន អនុម័តឡើង (the "EC Treaty")។

បច្ចុប្បន្ននេះ ស្ថាប័នសហគមន៍អ៊ឺរ៉ុប រួមបញ្ចូល គណកម្មាការ ជាអង្គនីតិប្រតិបត្តិ (the "Commission") ក្រុមប្រឹក្សា ជាអង្គនីតិបញ្ញត្តិ និងតុលាការយុត្តិធម៌អ៊ឺរ៉ុប (European Court of Justice) ជាមួយនិងតុលាការដំបូង (Court of First Instance) ជាតុលាការ។ សភាអ៊ឺរ៉ុប ត្រូវបានបង្កើតឡើងជាអង្គពិគ្រោះយោបល់ (Consultative body) ខណ:ដែល តុលាការសវនកម្ម (Court of Auditors) បង្ហាញពីទិដ្ឋភាពនៃនីត្យានុកូលភាពនៃគម្រោងថវិកាសហគមន៍អ៊ឺរ៉ុប។ ដំណើរការនៃការ

ធ្វើសេចក្តីសំរេចនៅក្នុងថ្នាក់សហគមន៍ ត្រូវបានកំណត់ដោយ រដ្ឋធម្មនុញ្ញអ៊ឺរ៉ុប (European Constitution) ជាសេចក្តីព្រាងដែលបានព្រមព្រៀងឡើងក្នុងខែ មិថុនា ឆ្នាំ ២០០៤។

នៅក្នុងសហគមន៍អ៊ឺរ៉ុប កម្មសិទ្ធិ ពាណិជ្ជកម្ម និងឧស្សាហកម្ម (industrial and commercial property) ត្រូវបានការពារក្រោមមាត្រា ៣០ នៃសន្ធិសញ្ញាសហគមន៍អ៊ឺរ៉ុប និងបទប្បញ្ញត្តិជាបន្តបន្ទាប់ ដូចជា សេចក្តីបង្គាប់បញ្ជា និងសេចក្តីសំរេចជាដើម។ នៅក្រោមវិធានច្បាប់របស់សហគមន៍អ៊ឺរ៉ុប គោលបំណងនោះគឺសម្រុះសម្រួលវិធានកម្មសិទ្ធិបញ្ញាជាតិរបស់ប្រទេសជាសមាជិកទាំងអស់ ជាផ្លូវមួយសម្រាប់សម្រេចគោលបំណងនៃចលនាដោយសេរីនៃទំនិញ នៅក្នុងទីផ្សារផ្ទៃក្នុងរបស់សហគមន៍អ៊ឺរ៉ុប។ ទោះជាយ៉ាងណា ការរួមបញ្ចូលគ្នានៃច្បាប់របស់សហគមន៍អ៊ឺរ៉ុប លើការសម្គាត់ពាណិជ្ជកម្ម មិនទាន់បានសម្រេចនៅឡើយទេ។ បច្ចុប្បន្ននេះ មានតែលក្ខន្តិកៈសហគមន៍អ៊ឺរ៉ុបមួយចំនួនប៉ុណ្ណោះ ដែលនិយាយអំពីការការពារការសម្គាត់ពាណិជ្ជកម្ម ដូចជា ៖

- មាត្រា ១៣ នៃសេចក្តីបង្គាប់បញ្ជារបស់សភា និងក្រុមប្រឹក្សាអ៊ឺរ៉ុប លេខ ៩៦/៩/EC ស្តីពីការការពារផ្នែកច្បាប់នៃការផ្ទុកទិន្នន័យ (European Parliament and Council Directive No. 96/9/EC on the Legal Protection of Databases)[40]
- មាត្រា ១២ នៃសន្ធិសញ្ញាបង្កើតសហគមន៍ថាមពលអាតូមិកអ៊ឺរ៉ុប (Treaty Establishing the European Atomic Energy Community)[41]
- មាត្រា ៤ នៃសេចក្តីបង្គាប់បញ្ជារបស់ក្រុមប្រឹក្សា លេខ ៨៧/៥៤/EEC ស្តីពីការការពារផ្នែកច្បាប់លើ លក្ខណៈទ្រង់ទ្រាយនៃផលិតផលពាក់កណ្តាលចម្លង (Council Directive No. 87/54/EEC on the Protection of Topographies of Semiconductor Products)[42]
- កថាខណ្ឌទី ៤១ នៃសេចក្តីបង្គាប់បញ្ជារបស់ក្រុមប្រឹក្សា លេខ ៩៥/៤៦ ចុះថ្ងៃទី ២៤ តុលា ១៩៩៥ ស្តីពីការការពារបុគ្គលទាក់ទងនិងដំណើរការទិន្នន័យផ្ទាល់ខ្លួន និងការចលនាដោយសេរីនៃទិន្នន័យនោះ (Council Directive No. 95/46 on the Protection of Individuals with regard to the Processing of Personal Data and the Free Movement of Such Data)[43]
- មាត្រា ៤ និង ៦ នៃសេចក្តីបង្គាប់បញ្ជា លេខ ២០០១/៣៧/EC របស់សភា និងក្រុមប្រឹក្សាអ៊ឺរ៉ុប ស្តីពីការប៉ាន់ប្រមាណ នៃច្បាប់ បទបញ្ជា និងបទប្បញ្ញត្តិរដ្ឋបាល នៃរដ្ឋជាសមាជិកទាក់ទងនិងការផលិត ការបង្ហាញ និងការលក់ទំនិញថ្នាំជក់ (Council Directive No. 2001/37/EC of the European Parliament and of the Council on the Appropriation of

[40] *European Parliament and Council Directive No. 96/9/EC on legal protection of databases* was published with the Official Journal No. L 077 of March 27, 1996.
[41] *The Treaty establishing the European Atomic Energy Community* was published with the Publishing Service of the European Communities, Luxembourg, 1957, p. 7-131.
[42] Official Journal of the European Communities, No. L 24 as of Jaunary 27, 1987.
[43] Official Journal of the European Communities, No. L 194 as of July 18, 2001.

Laws, Regulations and Administrative of the Member States concerning the Manufacture, Presentaion and Sale of Tobacco Products)[44]។

សេចក្តីយោងបែបនេះ ត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃការហាមឃាត់នៃការលាតត្រដាងការសម្ងាត់ពាណិជ្ជកម្មដោយគ្មានការអនុញ្ញាតពីស្ថាប័ននានានៃសហគមន៍អឺរ៉ុប។ ការខ្វែងគំនិតគ្នាក្នុងចំណោមសមាជិកសហគមន៍អឺរ៉ុប ថាតើព័ត៌មានប្រភេទណាដែលសមនឹងទទួលបានការការពារខណៈដែលមិនមានលក្ខន្តិកៈណាមួយបានឲ្យនិយមន័យលើពាក្យ "ការសម្ងាត់ពាណិជ្ជកម្ម" ឲ្យបានសមស្របនៅឡើយទេ។ ទោះយ៉ាងណាក៏ដោយ ការសម្ងាត់ពាណិជ្ជកម្មក៏ទទួលបានម្រិតនៃការការពារដោយសមរម្យក្រោមច្បាប់ជាតិនៃប្រទេសនីមួយៗ ដែលជាសមាជិករបស់សហគមន៍អ៊ឺរ៉ុប។

ផលវិបាកនោះគឺដោយហេតុថា លក្ខន្តិកៈសហគមន៍អឺរ៉ុបជាច្រើនបានប្រើពាក្យជំនួសដែលទាក់ទងទៅនឹងការសម្ងាត់ពាណិជ្ជកម្ម ដូចជាៈ "**ព័ត៌មានពាណិជ្ជកម្ម ឬ ឧស្សាហកម្ម**" ព័ត៌មានដែលទាក់ទងទៅនឹង "**ការសម្ងាត់ជំនាញវិជ្ជាជីវៈនិងអាជីវកម្ម**" ពត៌មាននៃប្រភព "**ការសម្ងាត់ជំនាញវិជ្ជាជីវៈ**" ឬ "**ចំណេះធ្វើ**" (know-how)[45]។

ដោយអនុលោមតាមមាត្រា ២ (១០) នៃបទបញ្ជាគណៈកម្មាការ លេខ ២៦៥៩/២០០០ ស្តីពីការដាក់ពាក្យសុំឲ្យ មាត្រា ៨១ (៣) នៃសន្ធិសញ្ញាទីក្រុងរ៉ូម បែងចែកការស្រាវជ្រាវ និងអភិវឌ្ឍកិច្ចព្រមព្រៀងពាក្យ "**ចំណេះធ្វើ**" ត្រូវបានកំណត់និយមន័យថាជា "**កញ្ចប់ព័ត៌មានជាក់ស្តែងដែលមិនមែនជាប្រកាសនីយបត្រតក្កកម្ម ដែលជាការសម្ងាត់ទទួលបានលទ្ធផលបានមកពីបទពិសោធន៍ និងការធ្វើតេស្តដោយត្រឹមត្រូវ និងអាចកំណត់បាន**"[46]។

ទស្សនៈទៅលើពាក្យ **សម្ងាត់** "secret" **ត្រឹមត្រូវ** "substantial" ឬ **អាចកំណត់បាន** "identified" ត្រូវបានកំណត់ដោយបទប្បញ្ញត្តិដូចខាងក្រោមៈ

- "**សម្ងាត់**" មានន័យថា "ដែលបាន **ចំណេះធ្វើ** មិនត្រូវបានគេស្គាល់ជាទូទៅ ឬ ការចូលដំណើរការបាន"
- "**ត្រឹមត្រូវ**" មានន័យថា "ដែលបាន "**ចំណេះធ្វើ**" ដែលមានរួមបញ្ចូលទាំងព័ត៌មានដែលមានការខ្វះខាតសម្រាប់ការផលិតនៃផលិតផលកិច្ចសន្យា ឬ ការដាក់ពាក្យនៃដំណើរការចុះកិច្ចសន្យា"

[44] England, Germany and France are the EC economic pillars. Therefore, harmonization of EC rules on trade secrets protection must take into account existing rules in such jurisdictions. In England, trade secret protection is predicated upon the common law concept of "breach of confidence" (*see for example* Lord Denning assertions in *Seager v. Copydex* (No. 2), [1969] 2 All E.R. 718, at 719-720 C.A.-Civ.Div).
[45] Directive 2003/4 on public access to environmental information was published with the Official Journal No. L 41 of February 14, 2003 refers in Art. 4 (2d) to the confidentiality of "*commercial or industrial information*".
[46] Commission Regulation No. 2659/2000 was published with the Official Journal No. L 304 of December 5, 2000.

- "**អាចកំណត់បាន**" មានន័យថា "ដែលបាន "**ចំណេះធ្វើ**" ត្រូវបានពិពណ៌នាក្នុងលក្ខណៈទូលំទូលាយគ្រប់គ្រាន់ ដូច្នេះដើម្បីធ្វើឲ្យវាបញ្ជាក់អាចបញ្ជាក់ទៅបានថា វាបានបំពេញលក្ខខណ្ឌនៃ ការសម្ងាត់ និងភាពត្រឹមត្រូវ"។

## កថាខណ្ឌទី៣៖ ទម្រង់នៃការការពារនៅក្រោមក្របខ័ណ្ឌសហរដ្ឋអាមេរិក

## វាក្យខ័ណ្ឌទី១៖ គោលនយោបាយសាធារណៈរបស់សហរដ្ឋអាមេរិក

ដោយយោងតាមបទប្បញ្ញត្តិរបស់សហរដ្ឋអាមេរិក គោលនយោបាយសាធារណៈទៅលើកិច្ចការពារការសម្ងាត់ពាណិជ្ជកម្ម មានន័យថា គឺជាការថែរក្សារក្សានូវក្រមសីលធម៌ពាណិជ្ជកម្ម ការលើកទឹកចិត្តទៅលើការស្រាវជ្រាវ និងភាពមានកម្រិតនៃការលួចនូវការសម្ងាត់ពាណិជ្ជកម្ម ឬចារកម្មសេដ្ឋកិច្ច[47]។

ដើម្បីថែរក្សានូវក្រមសីលធម៌ពាណិជ្ជកម្ម អង្គនីតិបទប្បញ្ញត្តិរបស់សហរដ្ឋអាមេរិកបានយកចិត្តទុកដាក់ទៅលើការអភិរក្ស និងការរក្សាលំនឹងភាពនៃបរិបទពាណិជ្ជកម្ម។ រចនាសម្ព័ន្ធច្បាប់ដែលធ្វើការការពារការសម្ងាត់ពាណិជ្ជកម្ម ក៏ជួយរក្សានៅលំនឹងនៃបរិបទពាណិជ្ជកម្មផងដែរ។ ដោយដឹងពីតថភាពថា ការការពារការសម្ងាត់ពាណិជ្ជកម្មក៏ត្រូវបានប្រព័ន្ធច្បាប់របស់សហរដ្ឋអាមេរិកធ្វើការការពារដែរផងនោះ នាំឲ្យអ្នកវិនិយោគកាន់តែមានទំនុកចិត្តក្នុងការធ្វើពាណិជ្ជកម្មនៅសហរដ្ឋអាមេរិក។ បន្ថែមពីលើនឹងទៅទៀត ក្រមសីលធម៌ពាណិជ្ជកម្ម មិនមែនតែត្រូវបានធានាចំពោះអ្នកវិនិយោគសហរដ្ឋអាមេរិកប៉ុណ្ណោះទេ ថែមទាំងធានាទៅលើអតិថិជន និង សាធារណៈទាំងមូលផងដែរ។ ជាក់ស្តែងយើងដឹងថា ក្រមសីលធម៌ពាណិជ្ជកម្មធ្វើការការពារទៅលើព័ត៌មានដែលមានតម្លៃខាងពាណិជ្ជកម្ម ឯអតិថិជន និងសាធារណៈជាទូទៅ នឹងពឹងផ្អែកទៅលើគុណភាពទៅលើផលិតផលទាំងនោះ ដែលពួកគេក៏បានដឹងយ៉ាងច្បាស់ថា ការផលិតឡើងរបស់ពួកគេត្រូវបានរក្សាជាព័ត៌មានសម្ងាត់។

ប្រព័ន្ធច្បាប់របស់សហរដ្ឋអាមេរិក ចំពោះការសម្ងាត់ពាណិជ្ជកម្ម គឺលើកទឹកចិត្តទៅលើការស្រាវជ្រាវ។ ច្បាប់នេះផងដែរ គឺអ្នកវិនិយោគទទួលបានផលចំនេញជាក់ស្តែងពីការការពារការបង្កើតឡើងរបស់ពួកគេ ដែលក្រៅពីបទដ្ឋានច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងប្រហាក់ប្រហែល ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។ ដូចនេះហើយ ច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម បង្កើតនូវឱកាសសម្រាប់អ្នកច្នៃប្រឌិតនូវអ្វីថ្មីៗ។ ឯអ្នកច្នៃប្រឌិតទាំងនោះ ក៏កាន់តែមានទំនុកចិត្តបន្ថែមទៀតទៅលើការច្នៃប្រឌិត រុករករបស់គេ ព្រោះវាត្រូវបានការពារ ជៀសវាងនូវការក្លែងបន្លំពីច្បាប់ថ្មីៗទៀត។ ឯអតិថិជន ក៏ទទួលបាននូវផលប្រយោជន៍ពីការ ការច្នៃប្រឌិតថ្មីនោះផងដែរ ដែលនាំឲ្យផលិតផលដែលច្នៃប្រឌិតថ្មីនោះ គឺមានវត្តមាននៅលើទីផ្សារ។

[47] Stan Benda, "*Trade Secrets: Remedies for Unauthorized Acquisition, Disclosure, or Use-A Survey of Canada and the US*" (2001-2002) 18 C.I.P.R. ទំព័រ ៥៨៩។

ទាក់ទងទៅនឹងកម្រិតភាពនៃការលួចនូវការសម្ងាត់ពាណិជ្ជកម្ម ឬចារកម្មសេដ្ឋកិច្ច ប្រព័ន្ធច្បាប់របស់សហរដ្ឋអាមេរិក ស្តីពី ការសម្ងាត់ពាណិជ្ជកម្ម បានដាក់នូវបទប្បញ្ញត្តិស្តីពីទោសប្បញ្ញត្តិព្រហ្មទណ្ឌ ដើម្បីការពារនូវការកើតឡើងនូវភាពអនុវត្តដោយគ្មានសមត្ថកិច្ចស្តីពីការសម្ងាត់ពាណិជ្ជកម្ម។

**ខណ្ឌទី២៖ ការការពារការសម្ងាត់ពាណិជ្ជកម្មប្រឆាំងនឹងការផ្សព្វផ្សាយ ដោយអ្នកគ្មានសមត្ថកិច្ចនៃភ្នាក់ងាររដ្ឋាភិបាលរបស់សហរដ្ឋអាមេរិក**

ដូចដែលបានបកស្រាយខាងលើម្តងហើយ អង្គនីតិបញ្ញត្តិចាប់ផ្តើមលើកពីបទប្បញ្ញត្តិ និងអង្គហេតុស្តីពី ការការពារការសម្ងាត់ពាណិជ្ជកម្មរវាងទ្វេនៃភាគីឯកជន។ ក្នុងស្ថានភាពជាក់ស្តែង ម្ចាស់នៃការសម្ងាត់ពាណិជ្ជកម្ម ទាមទារឲ្យដឹងជាមុននូវបុព្វសិទ្ធិ ឬមូលដ្ឋាននៃការសម្ងាត់ទៅលើការសម្ងាត់ពាណិជ្ជកម្មរបស់ពួកគេចំពោះភ្នាក់ងាររដ្ឋាភិបាលរបស់សហរដ្ឋអាមេរិក។ ដូចនេះហើយ សហរដ្ឋអាមេរិកបានបង្កើតឡើងនូវការការពារការសម្ងាត់ពាណិជ្ជកម្មប្រឆាំងទៅនឹងការផ្សព្វផ្សាយព័ត៌មានសម្ងាត់ពាណិជ្ជកម្មដោយអ្នកដែលគ្មានសមត្ថកិច្ច ក្រោមភ្នាក់ងាររដ្ឋាភិបាលរបស់សហរដ្ឋអាមេរិក។

The United States Freedom of Information Act "FOIA" ត្រូវបានប្រកាសឡើងក្នុងឆ្នាំ ១៩៦៦។ FOIA គឺជាផ្នែកមួយនៃការបញ្ញត្តិឡើងដោយសង្គមស៊ីវិលសហរដ្ឋអាមេរិក ដើម្បីលើកទឹកចិត្តឲ្យកាន់តែខិតទៅរករដ្ឋាភិបាល។ ដើម្បីគាំទ្រឲ្យមានការផ្សព្វផ្សាយកាន់តែ ប្រសើរឡើង និងឆាប់រហ័ស ដែលជាហេតុនាំឲ្យ FOIA ត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ ១៩៧៤ ១៩៧៦ ១៩៨៦ ១៩៩៦ និងឆ្នាំ២០០២។

មូលដ្ឋាននៃ FOIA គឺការផ្សព្វផ្សាយ មានន័យថា ធ្វើយ៉ាងណាដើម្បីឲ្យព័ត៌មានរដ្ឋាភិបាលត្រូវបានផ្សព្វផ្សាយឲ្យដឹងជាទូទៅ។ FOIA បម្រើទៅលើផ្នែកកណ្តាលនៃរដ្ឋាភិបាលសហរដ្ឋអាមេរិក ភ្នាក់ងារនៅក្នុងសាខានៃអង្គនីតិប្រតិបត្តិក្នុងសហព័ន្ធនៃរដ្ឋាភិបាលកណ្តាល ក្រុមប្រឹក្សានៃរដ្ឋាភិបាល និងអង្គភាពដែលទទួលបន្ទុកក្នុងការអនុវត្តបទបញ្ជា។ ក្រោមច្បាប់ FOIA បានចែងថា រាល់ឯកសារទាំងអស់ដែលត្រូវបានត្រួតពិនិត្យដោយរដ្ឋាភិបាលកណ្តាល គឺអាចធ្វើការផ្សព្វផ្សាយជាសាធារណៈបាន។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងកថាខណ្ឌ ៥៥២(ខ)(៤) នៃ FOIA រដ្ឋាភិបាលអាចធ្វើការបដិសេធទៅលើការផ្សព្វផ្សាយ ក្រោមលក្ខខណ្ឌ (ក). **ការសម្ងាត់ពាណិជ្ជកម្ម** (ខ). **ព័ត៌មានពាណិជ្ជកម្ម ឬព័ត៌មានសេដ្ឋកិច្ច**។ ព័ត៌មានទាំងនោះ ត្រូវតែបានដាក់ទៅរដ្ឋាភិបាលកណ្តាលរបស់សហរដ្ឋអាមេរិកជាមុនសិន ដោយដាក់ថាជាបុព្វសិទ្ធិ ឬភាពសម្ងាត់។ ឧទាហរណ៍ ក្នុងករណីដែលមានការពាក់ព័ន្ធទៅនឹងការផ្សព្វផ្សាយដែលអនុលោមទៅតាមប្រព័ន្ធច្បាប់សហរដ្ឋអាមេរិក គឺមានដូចជា រោងចក្រចំណីអាហារជាដើម។

នៅក្នុងអង្គហេតុរវាង "National Parks and Conservation Association v. Morton[48]" ដែលបានវិនិច្ឆ័យក្នុងឆ្នាំ ១៩៧៤ តុលាការមួយនៅក្នុងសហរដ្ឋអាមេរិកបានលើកឡើងថា ព័ត៌មាន គឺ"**ត្រូវ**

[48] *National Parks and Conservation Association v Morton,* 498 F.2nd, ទំព័រ៧៦៥ (D.C. Cir. 1974)។

**បានលាក់ជាការសម្ងាត់**" ដែលការធ្វើការផ្សព្វផ្សាយឡើងនាំឲ្យមានការប៉ះពាល់ទៅដល់សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការរក្សានូវព័ត៌មានក្នុងពេលអនាគត សម្រាប់បុគ្គលដែលនឹងត្រូវទទួលបាននូវព័ត៌មានសម្ងាត់មួយនឹង។ សញ្ញាណនៃការសម្ងាត់ពាណិជ្ជកម្ម គឺមិនត្រូវបានបកស្រាយក្នុង FOIA ទេ ប៉ុន្តែ ក្នុង Public Citizen Health Research Group v. FDA ដែលត្រូវបានវិនិច្ឆ័យនៅឆ្នាំ ១៩៨៣ វាបានថែងថា ការសម្ងាត់ពាណិជ្ជកម្ម គឺជាការសម្ងាត់ ដែលមានតម្លៃខាងពាណិជ្ជកម្ម រូបមន្ត ដំណើរការ ឬឧបករណ៍ ដែលត្រូវបានប្រើប្រាស់សម្រាប់ការបង្កើត ការរៀបចំសមាសធាតុ ឬដំណើរការនៃផលិតផលពាណិជ្ជកម្ម ហើយដែលវាត្រូវបានចាត់ទុកថាជាផលិតផលចុងក្រោយរបស់ការច្នៃប្រឌិតថ្មី ឬការប្រឹងប្រែងដែលសំខាន់បំផុត។

Public Citizen Health Research Group v. FDA ចៅក្រមបានបានបកស្រាយពីសញ្ញាណនៃ **ព័ត៌មានពាណិជ្ជកម្ម ឬព័ត៌មានហិរញ្ញវត្ថុ** ដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្ម ឬជំនួញ។ ចៅក្រមក៏បានលើកឡើងនូវពាក្យ **ពាណិជ្ជកម្ម** និង **ហិរញ្ញវត្ថុ** គួរតែផ្តល់និយមន័យតាមលក្ខខណ្ឌទូទៅ (អត្ថន័យធម្មតា)។ ជាក់ស្តែង ព័ត៌មានដែលមិនជាប់ពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្ម ឬការធ្វើជំនួញ គឺមិនត្រូវបានការការពារក្រោមកថាខណ្ឌ ៥៥២(b)(៤) របស់ FOIA ទេ។

ដើម្បីទទួលបានការការពារក្រោមកថាខណ្ឌ ៥៥២(b)៤ របស់ FOIA **ការសម្ងាត់ពាណិជ្ជកម្ម** ឬ **ព័ត៌មានពាណិជ្ជកម្ម** ឬ **ព័ត៌មានហិរញ្ញវត្ថុ** ត្រូវតែត្រួតពិនិត្យដោយភ្នាក់ងាររដ្ឋាភិបាលសហរដ្ឋអាមេរិក ដោយបុគ្គល។ ហើយបុគ្គលនោះ ត្រូវតែជាឯកត្តជន សហកម្មសិទ្ធិ សាជីវកម្ម សមាគម ឬអង្គការឯកជន ឬសាធារណៈ។

សរុបមក FOIA គឺមានន័យថា ព័ត៌មានរបស់រដ្ឋាភិបាលគឺអាចធ្វើការផ្សព្វផ្សាយទៅបានលុះត្រាណាតែមានការស្នើសុំ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងកថាខណ្ឌ ៥៥២(b)៤ ការសម្ងាត់ពាណិជ្ជកម្ម ឬព័ត៌មានពាណិជ្ជកម្ម ឬព័ត៌មានហិរញ្ញវត្ថុ គឺអាចអនុញ្ញាតិឲ្យធ្វើការផ្សព្វផ្សាយបាន។

## ផ្នែកទី២៖ ទម្រង់នៃការការពារការសម្ងាត់ពាណិជ្ជកម្មនៅកម្ពុជា

បុគ្គលដែលកាន់កាប់ពត៌មានសម្ងាត់ ត្រូវបានតម្រូវឲ្យចាត់វិធានការសមស្របដើម្បីការពារភាពសម្ងាត់របស់ព័ត៌មាននេះ និងត្រូវត្រៀមដើម្បីដាក់បង្ហាញនូវវិសាលភាព ដែលភាពសម្ងាត់ត្រូវបានការពារតាមរយៈបណ្តឹងទៅតុលាការ។ ជំហានសមស្របដើម្បីការពារភាពសម្ងាត់ទាំងនេះ ត្រូវរួមបញ្ចូលទាំងការណែនាំនិយោជិតនូវអត្ថិភាពនៃពត៌មានសម្ងាត់ ការបិទផ្លាក ការធានាកិច្ចព្រមព្រៀងធានារក្សាការសម្ងាត់ត្រូវបានចុះហត្ថលេខា ការផ្តល់ពត៌មានទៅឲ្យតែនិយោជិតដែលចង់ដឹងការពិនិត្យលើដំណើរការផលិតតាមតាមរយៈការត្រួតពិនិត្យសុវត្ថិភាព និងគ្រឿងសម្គាល់ផ្សេងៗ ឬប្រព័ន្ធគ្រប់គ្រងអេឡិចត្រូនិកដទៃទៀត ការណែនាំនូវនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងទៀតទាត់ និងការកំណត់ដំណើរការម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនថតចម្លង ម៉ាស៊ីទូរសារ និងទិន្នន័យផ្សេងៗ។ ការប្រើប្រាស់លក្ខខណ្ឌសម្ងាត់ត្រូវតម្រូវឲ្យមាននៅក្នុងក្រុមហ៊ុនចំរុះ និងកិច្ចសន្យាប្រហាក់ប្រហែល ហើយកិច្ចសន្យាមិនបង្ហើបបង្ហាញផ្សេងទៀតនៅក្នុងការចរចារចុះកិច្ចសន្យាបែបនេះក៏សំខាន់ផងដែរ។

ប្រសិនបើភាពសម្ងាត់នេះមិនត្រូវបានការពារទេ ការផ្សព្វផ្សាយពត៌មាននេះអាចនឹងត្រូវបានសុំឲ្យតុលាការពារ បើទោះបីជាការផ្សព្វផ្សាយនេះត្រូវបានធ្វើឡើងដោយការធ្វេសប្រហែសក៏ដោយ។

**កថាខណ្ឌទី១៖ ការការពារដោយការមិនបើកចំហរ**

នៅពេលដែលទិន្នន័យដែលត្រូវបានដាក់ជូនឲ្យអាជ្ញាធរនិយ័តកម្មឪសថដើម្បីធ្វើការពិនិត្យត្រូវបានផ្តល់ការការពាររដ្ឋាភិបាលត្រូវមានកាតព្វកិច្ចពីរដាច់ដោយឡែកពីគ្នា។ ទី១ ជាកាតព្វកិច្ចនៃការមិនបើកចំហរ ដើម្បីធានាថាអ្នកផលិតឪសថ generic នានា និងអ្នកផ្សេងទៀតមិនត្រូវទទួលបានទិន្នន័យពិសោធន៍ព្យាបាល។ កាតព្វកិច្ចនេះធ្វើឲ្យយើងយល់បាន ដោយហេតុថា ការបង្ហើបបង្ហាញដោយកំប្លែង ឬដោយមិនបំប្លែងអាចជះឥទ្ធិពលលើសមត្ថភាពរបស់អ្នកដាក់ពាក្យសុំដំបូង ក្នុងការការពារភាពសម្ងាត់នៅក្នុងទីផ្សារផ្សេងៗទៀត។ ឧទាហរណ៍ ប្រសិនបើព័ត៌មានអាចរកបានជាទូទៅ អ្នកផលិតឪសថ generic មួយណាក៏ដោយក៏អាចធ្វើការអះអាងបានថា ពួកគេមានសិទ្ធិប្រើប្រាស់ព័ត៌មាននេះនៅក្នុងដំណើរអនុញ្ញាតឲ្យដាក់លក់លើទីផ្សារ។ ការខូចខាតដែលត្រូវទទួលរងដោយអ្នកដាក់ពាក្យសុំដំបូងគេនៅខណៈនេះ អាចមានទំហំយ៉ាងធំធេង ប្រសិនបើភាពសម្ងាត់ត្រូវបានបាត់បង់នៅទីកន្លែងណាមួយនោះ។

ពុំមានការកំណត់រយៈពេលនៃកាតព្វកិច្ចមិនបើកចំហរព័ត៌មាន ដូចដែលមានការកំណត់រយៈពេលលើការប្រើប្រាស់នោះទេ[49]។ មាត្រា ៣៩(៣) ពិតជាបានកំណត់នូវ **ការការពារជាសាធារណៈ** លើកលែងតែការបើកចំហរនេះត្រូវបានអនុញ្ញាត្តិ ក្នុងករណីដែលវាមានសារៈសំខាន់ក្នុងការការពារសាធារណៈជន ឬការចាត់វិធានការមួយចំនួនដើម្បីធានាថាទិន្នន័យទាំងនេះនឹងត្រូវបានការពារប្រឆាំងនឹងការប្រើប្រាស់មិនស្មោះត្រង់ខាងពាណិជ្ជកម្ម។ ប្រទេសកម្ពុជានឹងចាត់វិធានការឆន្ទានុសិទ្ធិដើម្បីធ្វើការកំណត់នូវអ្វីដែលមានសារៈសំខាន់ក្នុងការការពារសាធារណៈជន ប៉ុន្តែរដ្ឋាភិបាលអាចត្រូវបានស្នើសុំឲ្យបង្ហាញថា ការបើកចំហរដែលត្រូវធ្វើនោះមានភាពសមមាត្រ ឬបង្ហាញថា វាគួរតែត្រូវបានធ្វើឡើង។ សេចក្តីប្រកាសទីក្រុង ដូហា ស្តីពី កិច្ចព្រមព្រៀង TRIPS និងសុខភាពសាធារណៈបានពង្រីកវិសាលភាពនៃបដិប្បញ្ញត្រនេះ។

**កថាខណ្ឌទី២៖ ការការពារពីការប្រើប្រាស់មិនស្មោះត្រង់ខាងពាណិជ្ជកម្ម**

សំនួរដែលចោទឡើងថា តើអ្វីដែលបង្កើតបានជា **ការប្រើប្រាស់មិនស្មោះត្រង់ខាងពាណិជ្ជកម្ម** នោះគឺជាការវិភាគដ៏សំខាន់មួយក្នុងចំណោមការវិភាគសំខាន់ៗនានានៅក្នុងមាត្រា ៣៩(៣)។ មាត្រា៣៩(៣) បានគូសបញ្ជាក់ពីភាពខុសប្លែកពីគ្នារវាងកាតព្វកិច្ចមូលដ្ឋាននានា ក្រោមកិច្ចព្រម

[49] លោកបណ្ឌិត Carlos Correa, *ការការពារទិន្នន័យដែលត្រូវបានផ្តល់សម្រាប់ការចុះបញ្ជីឪសថ: ការអនុវត្តស្តង់ដារនៃកិច្ចព្រមព្រៀង TRIPS*, សាកលវិទ្យាល័យ Buenos Aries, South Centre, ២០០២, ទំព័រ ១៩។

ព្រៀង TRIPS និងកាតព្វកិច្ចព្រមព្រៀង TRIPS-Plus ដែលប្រទេសកម្ពុជាបានធ្វើការសន្យាដែលជាផ្នែកមួយនៃរបាយការណ៍ក្រុមការងារ។

លោកបណ្ឌិត Correa បានធ្វើការអះអាងថា បទប្បញ្ញត្តិនេះផ្តល់នូវអំណាចឆន្ទានុសិទ្ធិយ៉ាងធំដល់រដ្ឋាភិបាលនៃប្រទេសជាសមាជិកនៅក្នុងការអនុវត្តន៍លើចំនុចនេះ៖

*ដោយយោងទៅតាមមាត្រា ៣៩(៣) ការប្រើប្រាស់ដោយរដ្ឋាភិបាលក្នុងការប៉ាន់ប្រមាណលើប្រសិទ្ធិភាព និងភាពគ្រោះថ្នាក់នៃផលិតផលឱសថ ឬផលិតផលកសិកម្មគីមី មិនមែនជាការប្រើប្រាស់ខាងផ្នែកពាណិជ្ជកម្មទេ។ ដោយអនុលោមតាមភាពស្រដៀងគ្នានៃផលិតផលបន្ទាប់ និងផលិតផលដំបូងដែលត្រូវបានអនុញ្ញាតមុនគេនោះ ការអនុញ្ញាត ឲ្យមានការចែកចាយលើទីផ្សារចំពោះអ្នកនាំចូលបន្ទាប់នេះ មិនមែនជា **ការប្រើប្រាស់** ដែលត្រូវបានហាមឃាត់ ក្រោមមាត្រា ៣៩(៣) នោះទេ។*

*ប្រទេសទាំងនេះត្រូវអនុវត្តនូវកាតព្វកិច្ចនានារបស់ខ្លួនក្នុងការការពារប្រឆាំងនឹង **ការប្រើប្រាស់មិនស្មោះត្រង់ខាងពាណិជ្ជកម្ម** ក្រោមមាត្រា ៣៩(៣) ដោយធ្វើការហាមឃាត់មិនឲ្យមានការប្រើប្រាស់ **មិនស្មោះត្រង់** លើទិន្នន័យពិសោធន៍នេះ។ ការការពារនេះត្រូវតម្រូវឲ្យមាន ជាឧទាហរណ៍ ការហាមឃាត់អ្នកប្រកួតប្រជែងម្នាក់ ដែលទទួលបាននូវលទ្ធផល លើទិន្នន័យពិសោធន៍តាមរយៈការបន្លំការរំលោភលើសេចក្តីទុកចិត្ត ឬការអនុវត្តន៍ **មិនស្មោះត្រង់** ផ្សេងៗទៀត ហើយប្រើទិន្នន័យទាំងនេះដើម្បីដាក់សុំការអនុញ្ញាតក្នុងការចែកចាយលើទីផ្សារ ដើម្បីទទួលបាននូវផលចំណេញផ្ទាល់ខ្លួន។ វាអាចត្រូវបានអនុវត្តផលដែរនៅក្នុងករណីដែលរដ្ឋាភិបាលអនុញ្ញាតិឲ្យទទួលទិន្នន័យពិសោធន៍សម្ងាត់ ដើម្បីផ្តល់ផលប្រយោជន៍ដល់ក្រុមហ៊ុនមួយដែលមិនបានផលិតទិន្នន័យទាំងនេះ ឬមិនបានជួយបង់ថ្លៃរបស់វា។*

លោកបានបញ្ជាក់ទៀតថា បទប្បញ្ញត្តិទាំងមូលនេះត្រូវបានអាចរួមគ្នា ហើយដូច្នេះ មាត្រា ៣៩(៣) ត្រូវបានកំណត់ដោយ៖

*(ក). មាត្រា ១០ ស្ទួននៃអនុសញ្ញានៃក្រុង ប៉ារីស (១៩៦៧) ដែលមានចែងនៅក្នុងមាត្រា ៣៩(១) ដែលដោះស្រាយ តែទៅលើបញ្ហាដែលទាក់ទងទៅនឹង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និង*

*(ខ). ការអនុវត្តន៍ទាំងនេះត្រូវបានដាក់បញ្ចូលនៅក្នុងលេខយោងនៃមាត្រា ៣៩(២) រួមមានការរំលោភបំពានលើ កិច្ចសន្យា ការរំលោភលើសេចក្តីទុកចិត្ត និងការញុះញង់ឲ្យរំលោភបំពានហើយរួមបញ្ចូលទាំងការទទួលបាននូវ ព័ត៌មានសម្ងាត់ដោយតតីយជនដែលបានដឹង ឬមិនបានដឹងដោយការធ្វេសប្រហែសធ្ងន់ធ្ងរ ដែលការអនុវត្តន៍បែបនេះ ត្រូវជាប់ពាក់ព័ន្ធនឹងការទទួលព័ត៌មានសម្ងាត់នេះ។*

មាត្រា ១០ ស្ទួននៃអនុសញ្ញាទីក្រុង ប៉ារីស ស្តីពី ការការពារកម្មសិទ្ធិឧស្សាហកម្ម ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ១៩៧៩ ចែងថា៖

*(១). បណ្តាប្រទេសនៃសហគមន៍ត្រូវមានកាតព្វកិច្ចធានាឲ្យពលរដ្ឋរបស់ខ្លួន នូវការការពារដ៏មានប្រសិទ្ធិភាពប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់*

*(២). អំពើណាមួយរបស់អ្នកប្រកួតប្រជែងដែលផ្ទុយទៅនឹងការអនុវត្តន៍ស្មោះត្រង់ក្នុងវិស័យឧស្សាហកម្ម និងពាណិជ្ជកម្មត្រូវចាត់ទុក ថាជាអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។*

*(៣). អំពើខាងក្រោមនេះត្រូវបានហាមឃាត់៖*

*(ក). ការបង្កើតឲ្យមានការភ័ន្តច្រឡំតាមមធ្យោបាយណាមួយ ជាមួយសហគ្រាសជាមួយទំនិញ*

*(ខ). ការពោលអះអាងមិនត្រឹមត្រូវក្នុងពាណិជ្ជកម្ម ដែលធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ សហគ្រាស ទំនិញ ឬសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូរប្រកួតប្រជែង។*

*(គ). ការបញ្ជាក់ ឬការពោលអះអាងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ហើយដែលអាចធ្វើឲ្យសាធារណៈជនភ័ន្តច្រឡំ អំពីប្រភេទដំណើរការផលិត លក្ខណៈភាពសមស្របសម្រាប់គោលបំណងរបស់គេ ឬបរិមាណនៃទំនិញ។*

លោកបណ្ឌិត Correa បានអះអាងបន្តទៀតថា ការអនុញ្ញាតឲ្យចែកចាយផលិតផលឱសថលើទីផ្សារ គឺជាតួនាទីរដ្ឋាភិបាលសុទ្ធសាធ និងមិនមែនជាតួនាទីផ្នែកពាណិជ្ជកម្មនោះទេ ដូច្នេះហើយវាមិនអាចផ្ទុយពីមាត្រា ៣៩(៣) ឡើយ។ ប៉ុន្តែ វាត្រូវបានដាក់ឲ្យពិភាក្សាដោយមានការអះអាងផ្ទុយមកវិញថា អំពើនៃការទទួលបាននូវការចែកចាយផលិតផលលើទីផ្សារ គឺជាសកម្មភាពពាណិជ្ជកម្មសុទ្ធសាធមួយ។ នៅពេលនោះ អ្វីដែលជាបញ្ហាគឺការកំណត់និយមន័យនៃពាក្យ **ការប្រើប្រាស់ខាងពាណិជ្ជកម្ម។** តើប្រភេទនៃការប្រើប្រាស់ពាណិជ្ជកម្មអ្វីដែលអាចត្រូវបានធ្វើជាទិន្នន័យពិសោធន៍បាន? គេនឹងលក់ទិន្នន័យពិសោធន៍ទាំងនេះទៅឲ្យតតីយជន។ ប៉ុន្តែ មាត្រា ៣៩(៣) មិនបានសំដៅទៅលើ ទិន្នន័យសម្ងាត់ជាទូទៅនេះទេ៖ មាត្រានេះគ្រាន់តែសំដៅទៅលើទិន្នន័យដែលទទួលបាននៅខណៈពេលដែលធ្វើការពិសោធន៍សាកល្បងលើផលិតផលគីមីកសិកម្ម ឬឱសថដែលមានការអនុវត្តន៍ដោយឡែកមួយ។ ដូចនេះ ទិន្នន័យទាំងនេះ មានគោលបំណងជាក់លាក់ណាមួយហើយគ្មានប្រយោជន៍សម្រាប់ផលិតផលផ្សេងទៀតឡើយ។ ដូចនេះ ដើម្បីបង្កើតឲ្យមាន **ការប្រើប្រាស់ខាងពាណិជ្ជកម្ម** លើទិន្នន័យពិសោធន៍មួយ មិនមែនមានន័យថា ជាការលក់ ឬជាសំណើរលក់នូវទិន្នន័យនេះមិនអាចលក់ទិន្នន័យទាំងនេះបានឡើយ គឺមានតែរដ្ឋាភិបាលមួយតែប៉ុណ្ណោះ។ តាមរយៈកម្មវត្ថុនេះ រដ្ឋាភិបាលទាំងឡាយមិនត្រូវសន្សាលក់ព័ត៌មាន ដែលទទួលបានពីពលរដ្ឋ ឬពីក្រុមហ៊ុនដែលកំពុងស្វែងរកនូវនីតិវិធីរដ្ឋបាលជាក់លាក់ណាមួយឡើយ។ **ការប្រើប្រាស់ខាងពាណិជ្ជកម្ម** ត្រូវមានន័យត្រឹមត្រូវថាជាអ្វីមួយផ្សេងទៀត៖ តាមពិតទៅ វាមានន័យថាជាការប្រើប្រាស់ទិន្នន័យសម្រាប់គោលដៅពាណិជ្ជកម្មតែមួយ ដែលពួកគេអាចមានដើម្បីគាំទ្រឲ្យទទួលបាននូវការអនុញ្ញាតចែកចាយលើទីផ្សារ[50]។

[50] Nuno Pires de Carvalho, *The TRIPS Regime of Patent Rights*, 2nd Edition, 2005. *Kluwer Law International*, កថាខណ្ឌទី ៣៩.៣, ទំព័រ ៣៩២-៣។

ការពិភាក្សានេះធ្វើឡើងក្រោមសំនួរមួយថា តើមាត្រា ៣៩(៣) តម្រូវឲ្យមានសិទ្ធិផ្តាច់មុខលើទិន្នន័យដែលកាន់កាប់ដោយរដ្ឋាភិបាលផ្តល់នូវសិទ្ធិផ្តាច់មុខនេះចំពោះតែអ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ ដែលអាចប្រើប្រាស់ទិន្នន័យនេះបានដោយផ្ទាល់ ឬមិនផ្ទាល់ តាមមធ្យោបាយណាក៏ដោយ។ សិទ្ធិផ្តាច់មុខលើទិន្នន័យត្រូវបានគាំទ្រយ៉ាងខ្លាំងខ្លាពីសំណាក់សហរដ្ឋអាមេរិក អឺរ៉ុន និងប្រទេសស្វីស។ អំនះអំនាងដែលគាំទ្រលើសិទ្ធិផ្តាច់មុខលើ ទិន្នន័យនេះ គូសបញ្ជាក់ឲ្យឃើញថាក្នុងដំណើរការនៃការផលិតឪសថមានតម្លៃខ្ពស់។ ឧទាហរណ៍៖

ក្រុមហ៊ុនឪសថដែលផ្អែកលើមូលដ្ឋាន ស្រាវជ្រាវនៅក្នុងសហរដ្ឋអាមេរិកបានបណ្តាក់ទុនចំនួន ២១.៨ រយកោដដុល្លា នៅក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍន៍ (R&D) នៅឆ្នាំ ១៩៩៨ ដែលត្រូវជា ១០ ភាគរយច្រើនជាងឆ្នាំ ១៩៩៧ ដោយមាន ៤០ ភាគរយនៃការចំនាយរបស់ R&Dសម្រាប់ដំណាក់កាលមុនការព្យាបាល និង ៣០ ភាគរយត្រូវចំនាយនៅក្នុងការបំពេញការសាកល្បងព្យាបាលជំហ៊ានទី ១ ទី២ និងទី៣ ដែលត្រូវបានតម្រូវដោយ FDA។ ការចំណាយ ៧០ ភាគរយនៃការចំណាយសរុបរបស់ R&Dនៅក្នុងសហរដ្ឋអាមេរិកត្រូវចំណាយទៅលើការចេញការអនុញ្ញាត។ ឪសថថ្មីៗមាន តម្លៃជាមធ្យម ៥០០ លានដុល្លា និងតម្រូវឲ្យមានរយៈពេល ១៥ ឆ្នាំដើម្បីផលិត បើយើងរាប់បញ្ចូននូវដំណាក់ មុនការព្យាបាល និងដំណាក់កាលព្យាបាល។ មានតែឪសថ ៣ ប្រភេទក្នុងចំណោមឪសថ ១០ ប្រភេទប៉ុណ្ណោះដែលត្រូវបានដាក់ឲ្យប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិកពីឆ្នាំ ១៩៨០ ដល់ ១៩៨៤ បានទទួលប្រាក់ចំណេញខ្ពស់ជាងតម្លៃ R&D បន្ទាប់ពីគិតពន្ធរួច។ គ្រាន់តែការសាកល្បង ឪសថនៅក្នុងដំណាក់ការព្យាបាលប៉ុណ្ណោះ មានតម្លៃប្រហែល ១៥០ លានដុល្លាក្នុងការប្រើឪសថតែមួយមុខ ហើយមានតែសងពី ១០ ទៅ ២០ ភាគរយប៉ុណ្ណោះដែលមានប្រសិទ្ធភាពសម្រាប់ការសាកល្បងព្យាបាល និងដំណាក់កាលព្យាបាល។ ផ្ទុយទៅវិញចំពោះអ្នកផលិតឪសថ generic វិញ (manufacturer of generic alternative)គេមិនតម្រូវឲ្យបង្កើតជាទិន្នន័យធ្វើការសាកល្បងផ្ទាល់ខ្លួនដើម្បីទទួលបានការអនុញ្ញាត្តិឲ្យចែកចាយលក់លើទីផ្សារឡើយ ហើយគេត្រូវការថវិកាតែ ១ លានដុល្លាប៉ុណ្ណោះ ដើម្បីដាក់លក់ឪសថនេះ ឲ្យតែឪសថនេះមានជីវសមមូលបាន[51]។

ឧត្តមក្រុមប្រឹក្សានៃតំណាងខាងផ្នែកពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកត្រូវបានដកស្រង់ប្រសាសន៍ដូចខាងក្រោម៖

> *អ្នកចរចារលើកិច្ចព្រមព្រៀង TRIPS បានយល់ថាពាក្យ* ***ការប្រើប្រាស់មិនស្មោះត្រង់ខាងផ្នែកពាណិជ្ជកម្ម*** *មានន័យថាទិន្នន័យនឹងមិនត្រូវបានប្រើប្រាស់ដើម្បីគាំទ្រ ដើម្បីធ្វើឲ្យឃើញច្បាស់ ឬម្យ៉ាងវិញទៀត ដើម្បីពិនិត្យ លើពាក្យស្នើសុំផ្សេងទៀតក្នុងការសុំសិទ្ធិចែកចាយលើទីផ្សារសម្រាប់រយៈពេលមួយនោះទេ វាលែងតែមានការអនុញ្ញាតពីអ្នកដាក់ទិន្នន័យឲ្យពិនិត្យដំបូងគេជាមុនសិន។*

[51] *Encouragement of New Clinical Drug Development: The Role of Data Exclusivity*, 2000, International Federation of Pharmaceutical Manufacturers Associations, Geneva, Switzerland, ទំព័រ ៦-៧។

*និយមន័យ ផ្សេងៗទៀតចំពោះពាក្យនេះ មិនមានសមរម្យទេ ហើយក៏មិនសមស្របទៅនឹងប្រវត្តិនៃការចរចារពីបទប្បញ្ញត្តិនេះទេ*[52]។

លោកបណ្ឌិត Correa បានធ្វើការវិភាគលើប្រវត្តិនៃការចរចារលើមាត្រា ៣៩(៣) នៃកិច្ចព្រមព្រៀង TRIPS ហើយឈានដល់ការធ្វើសេចក្តីសន្និដ្ឋានមួយដែលមានលក្ខណៈផ្ទុយពីការវិភាគដែលធ្វើឡើងដោយឧត្តមក្រុមប្រឹក្សា USTR ។ លោក Correa បានផ្តល់យោបល់ថា ប្រវត្តិនៃការធ្វើសេចក្តីព្រាងច្បាប់នេះបង្ហាញឲ្យឃើញថា **ភាពផ្តាច់មុខលើទិន្នន័យ** ត្រូវបានបដិសេធចោលដើម្បីជាប្រយោជន៍ដល់ស្តង់ដានៃ **ការប្រកួតប្រជែងមិនស្មោះត្រង់**[53]។ ដើមឡើយសំណើររបស់សហរដ្ឋអាមេរិក ដែលទាក់ទងនឹងមាត្រា ៣៩(៣) បានតម្រូវឲ្យបណ្តាប្រទេសជាសមាជិកធ្វើការបង្អាការប្រើប្រាស់ទិន្នន័យពិសោធន៍ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់សិទ្ធិ ឬដោយមិនមានការបង់ថ្លៃលើ **តម្លៃសមស្របនៃការប្រើប្រាស់** ប្រសិនបើ ការប្រើប្រាស់នេះនាំឲ្យមាន **ផលចំណេញខាងផ្នែកប្រកួតប្រជែង ឬខាងពាណិជ្ជកម្មដល់រដ្ឋាភិបាលណាមួយ ឬដល់បុគ្គលណាម្នាក់**។ បទប្បញ្ញត្តិនេះមិនត្រូវបានទទួលយកទេ ហើយសំណើរចុងក្រោយបានកំណត់យកពាក្យថា **ការអនុវត្តន៍មិនស្មោះត្រង់ខាងផ្នែកពាណិជ្ជកម្ម**។ អត្ថន័យជាក់លាក់នោះគឺថា គេអាចប្រើទិន្នន័យនេះនៅក្នុងស្ថានភាព **ស្មោះត្រង់**។ កាលៈទេសៈដំបូងបង្អស់ ត្រូវជាក់ពាក់ព័ន្ធទៅនឹងភាពបន្ទាន់ខាងផ្នែកសុខភាព។

ការតម្រូវឲ្យមានសិទ្ធិផ្តាច់មុខលើទិន្នន័យ ជាលក្ខណៈសម្គាល់លើសិទ្ធិដែលបានការពារប្រកបដោយប្រសិទ្ធិភាពនូវឪសថ ទោះបីបើឪសថនេះ **អស់សិទ្ធិការពារពីប្រកាសនីយបត្រតក្កកម្ម** ហើយក៏ដោយ។ ទស្សនៈនៃ **ការអនុវត្តន៍មិនស្មោះត្រង់ខាងពាណិជ្ជកម្ម** មានន័យដូចទៅនឹងពាក្យ **ការរំលោភបំពានលើកាតព្វកិច្ចនៃការសម្ងាត់** ឬសកម្មភាពនៃការប្រើប្រាស់មិនសមស្របលើព័ត៌មានសម្ងាត់ជាងសិទ្ធិលើកម្មសិទ្ធិ។ នៅក្នុងកំណត់ហេតុសង្ខេបនាពេលថ្មីៗនេះ អង្គការសុខភាពពិភពលោកបានពិពណ៌នាពីការអនុវត្តន៍អវិជ្ជមានក្នុងការផ្តល់សិទ្ធិផ្តាច់មុខលើទិន្នន័យនេះដូចតទៅនេះ៖

*ដរាបណាសិទ្ធិផ្តាច់មុខនៅតែបន្ត ដោយយោងទៅលើការអនុវត្តន៍ អ្នកផលិតឪសថ generic ត្រូវដាក់ទិន្នន័យផ្ទាល់ខ្លួនរបស់គេ ដើម្បីបញ្ជាក់ពីសុវត្ថិភាព និងប្រសិទ្ធិភាព ដែលអាចតម្រូវឲ្យពួកគេធ្វើការពិសោធន៍ព្យាបាល និងធ្វើការពិសោធន៍ផ្សេងៗទៀតឡើងវិញ។ ការធ្វើបែបនេះអាចបណ្តាលឲ្យមានភាពយឺតយ៉ាវដែលអ្នកផលិតឪសថ generic មិនអាចធ្វើទៅបាន។ លើសពីនេះទៅទៀត វានឹងលេចឡើងនូវសំនួរដែលទាក់ទងនឹងសីលធម៌យ៉ាងធ្ងន់ធ្ងរ នៅពេលដែលវាមានន័យថាការសាកល្បងពិសោធន៍ព្យាបាលនឹងត្រូវបានធ្វើឡើងម្តងទៀតតែក្នុងគោលដៅ ពាណិជ្ជកម្មតែប៉ុណ្ណោះ។*

[52]ដកស្រង់៖ ការការពារលើទិន្នន័យពិសោធន៍សម្ងាត់ ដោយស្របតាមមាត្រា ៣៩(៣) នៃកិច្ចព្រមព្រៀង TRIPS៖ សារណាដែលមិនអាចចែកចាយបាន ដែលត្រូវបានព្រាងដោយ ការិយាល័យនៃអគ្គក្រុមប្រឹក្សា USTR ទទួលបន្ទុកលើការរៀបចំកិច្ចប្រជុំទ្វេភាគី ជាមួយនឹង អូស្ត្រាលី នៅខែ មេសា ១៩៩៥។

[53] លោកបណ្ឌិត Carlos Correa, *ការការពារទិន្នន័យដែលត្រូវបានផ្តល់សម្រាប់ការចុះបញ្ជីឪសថ: ការអនុវត្តស្តង់ដារនៃកិច្ចព្រមព្រៀង TRIPS*, សាកលវិទ្យាល័យ Buenos Aries, South Centre, ២០០២, ទំព័រ ៥៥៣-៦។

*ផ្ទុយមកវិញ (ហើយដែលមាននៅក្នុងការអនុវត្តន៍ស្រដៀងគ្នានេះ) អ្នកផលិតឱសថ generic ត្រូវពន្យាពេលក្នុងការដាក់លក់ផលិតផលរបស់ខ្លួន រហូតដល់ផុតអាជ្ញាយុកាលនៃសិទ្ធិផ្តាច់មុខនេះ។ ដូច្នេះ សិទ្ធិផ្តាច់មុខលើទិន្នន័យនេះ បានកាត់បន្ថយនូវលក្ខណៈដូចគ្នានៃ ផលិតផល generic ដែលមានកំណើនយ៉ាងឆាប់រហ័សនៅលើទីផ្សារ ហើយដែលពន្យាពេលការប្រកួតប្រជែង និងការកាត់បន្ថយតម្លៃ*[54]។

អង្គការសុខភាពពិភពលោក បានធ្វើការបែងចែកប្រព័ន្ធកម្មសិទ្ធិបញ្ញា និងប្រព័ន្ធនិយ័តភាពឱសថ ដោយធ្វើការចង្អុលបង្ហាញថា **ប្រព័ន្ធទាំងពីរនេះមានកម្មវត្ថុខុសពីគ្នា ត្រូវបានគ្រប់គ្រងដោយឡែកពីគ្នា និងមានមុខងារឯករាជ្យពីគ្នា**។ ការដាក់បញ្ចូលនេះហាក់ដូចជាមានការអនុវត្តន៍អវិជ្ជមានចំពោះការប្រើប្រាស់ឱសថទាំងនេះ។ ដូច្នេះ គេបានណែនាំថា **ប្រទេសកំពុងអភិវឌ្ឍន៍គួរតែរក្សាប្រព័ន្ធទាំងពីរនេះឲ្យដាច់ដោយឡែកពីគ្នា ហើយគួរតែបដិសេធនូវការខំប្រឹងប្រែងទាំងឡាយក្នុងការភ្ជាប់ប្រព័ន្ធទាំងពីរនេះ**។

កាតព្វកិច្ចបន្ថែម ដែលត្រូវដាក់ឲ្យព្រះរាជាណាចក្រកម្ពុជាអនុវត្ត ដោយអនុលោមតាមកថាខណ្ឌទី ២០៥ នៃរបាយការណ៍ក្រុមការងារ បានផ្តល់នូវមូលដ្ឋានមួយដែលថាប្រទេសកម្ពុជាត្រូវតែផ្តល់ **សិទ្ធិផ្តាច់មុខលើទិន្នន័យ** នេះ។ ការផ្តល់ឲ្យនេះ វាហាក់ដូចជាធ្វើឡើងក្នុងគោលដៅដើម្បីអនុវត្តនូវពាក្យថា **ពុំមានបុគ្គលណាមួយក្រៅពីបុគ្គលដែលបានដាក់ទិន្នន័យនេះឲ្យត្រួតពិនិត្យអាចប្រើប្រាស់ទិន្នន័យនេះ ក្នុងការគាំទ្រពាក្យស្នើសុំនោះ ដោយគ្មានការអនុញ្ញាត្តិរបស់ខ្លួនឡើយ**។ ការនិយាយបែបឆ្លើយតបដោយផ្ទាល់ទៅនឹងបញ្ហាចម្បង ដែលថា តើរដ្ឋាភិបាលអាចប្រើយន្តការផ្សេងមួយចំនួនទៀតដើម្បីកាត់បន្ថយនូវដំណើរការអនុញ្ញាត្តិឲ្យចែកចាយឱសថលើទីផ្សារ ដែលមិនពឹងផ្អែកដោយផ្ទាល់លើទិន្នន័យព្យាបាលដែលត្រូវបានផ្តល់ឲ្យដោយអ្នកដាក់ពាក្យសុំដំបូងគេ។ យន្តការបែបនេះ ត្រូវបានផ្តល់ឲ្យដោយអាស្រ័យទៅលើវិញ្ញាបនបត្រ **ជីវសមមូល និងជីវសុពលភាព**។

[54] អង្គការសុខភាពពិភពលោក, របាយការណ៍សង្ខេប, *Access to Medicines, Data Exclusivity and other "TRIPS-Plus" Measures,* មីនា ២០០៦, ទំព័រ ១-២។

## ជំពូកទី៣៖ ទំនួលខុសត្រូវចំពោះការបំពានលើការសម្ងាត់ពាណិជ្ជកម្ម

## ផ្នែកទី១៖ ការបំពានលើការសម្ងាត់ពាណិជ្ជកម្ម (តើស្ថានភាព ឬសកម្មភាពណាខ្លះដែលចាត់ទុកថាជាការបំពាន?)

ការបំពានលើការសម្ងាត់ពាណិជ្ជកម្ម អាចជា ការទទួលព័ត៌មានមិនស្របច្បាប់ ឬការប្រើប្រាស់ ឬបង្ហើបបង្ហាញព័ត៌មានមិនស្របច្បាប់។

### កថាខណ្ឌទី១៖ ការទទួលបានព័ត៌មានមិនស្របច្បាប់

មាត្រា១០ នៃច្បាប់ស្តីពី ការសម្ងាត់ពាណិជ្ជកម្មដែលចែងពី **ការទទួលបានព័ត៌មានមិនស្របច្បាប់** បានចែងថា៖

*១. បុគ្គលដែលកាន់កាប់ការសម្ងាត់ពាណិជ្ជកម្មស្របច្បាប់ មានសិទ្ធិចាត់វិធានការប្រឆាំងទល់នឹងបុគ្គលណាដែលទទួលបានការសម្ងាត់ពាណិជ្ជកម្មនោះដោយមិនស្របច្បាប់ ផ្ទុយទៅនឹងការអនុវត្តន៍ពាណិជ្ជកម្មដោយស្មោះត្រង់។*

*២. ការសម្ងាត់ពាណិជ្ជកម្មដែលទទួលបានមានលក្ខណៈមិនផ្ទុយទៅនឹងការអនុវត្តពាណិជ្ជកម្មដោយស្មោះត្រង់ បើសិនបើវាត្រូវបានបង្កើតឡើងដោយឯករាជ្យ ឬបានមកដោយវិស្វកម្មបញ្ច្រាស់។*

បុគ្គលដែលកាន់កាប់ការសម្ងាត់ពាណិជ្ជកម្មដោយស្របច្បាប់ គឺជាបុគ្គលដែលមានសិទ្ធិស្របច្បាប់លើការសម្ងាត់ពាណិជ្ជកម្ម និងជាអ្នកដែលមានសិទ្ធិលើផលចំណេញពីព័ត៌មាននេះ។ ពាក្យនេះត្រូវបានប្រើប្រាស់ដើម្បីជៀសវាងការកំណត់លើលក្ខណៈស្របច្បាប់ពិតប្រាកដនៃការសម្ងាត់ពាណិជ្ជកម្ម ឧទាហរណ៍ ថាតើការសម្ងាត់នេះបង្កើតនូវសិទ្ធិលើកម្មសិទ្ធិ ឬសិទ្ធិបុគ្គល។

ពាក្យ **ដោយគ្មានការអនុញ្ញាត្តិស្របច្បាប់** មានន័យថា ការទទួលបានការសម្ងាត់ពាណិជ្ជកម្មមិនត្រូវបានអនុញ្ញាត្តិដោយបុគ្គលដែលកាន់កាប់ស្របច្បាប់លើការសម្ងាត់ពាណិជ្ជកម្មនោះឡើយ។

ពាក្យ **ផ្ទុយទៅនឹងការអនុវត្តន៍ស្មោះត្រង់ខាងពាណិជ្ជកម្ម** ត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា ២ នៃច្បាប់ដែលត្រូវបានស្នើនេះ។ តាមពិតទៅ កម្មសិទ្ធិនៃការទទួលបាននេះត្រូវតែត្រូវបានវាយតម្លៃដោយយោងទៅតាមករណីនីមួយៗ។

### កថាខណ្ឌទី២៖ ការប្រើប្រាស់ ឬការបង្ហើបបង្ហាញព័ត៌មានមិនស្របច្បាប់

មាត្រា១១ នៃច្បាប់ស្តីពី ការសម្ងាត់ពាណិជ្ជកម្មដែលចែងពី **ការប្រើប្រាស់ ឬការបង្ហើបបង្ហាញព័ត៌មានមិនស្របច្បាប់** បានចែងថា៖

*បុគ្គលដែលកាន់កាប់ការសម្ងាត់ពាណិជ្ជកម្មស្របច្បាប់ មានសិទ្ធិចាត់វិធានការប្រឆាំងទល់នឹងបុគ្គលណាដែលបង្ហើបបង្ហាញ ឬប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម មានលក្ខណៈផ្ទុយ*

*ទៅនឹងការអនុវត្តពាណិជ្ជកម្ម ដោយស្មោះត្រង់ បើសិនជាអ្នកបង្កើបបង្ហាញ ឬអ្នកប្រើប្រាស់នោះ បានដឹង ឬគួរតែបានដឹងថា ខ្លួនគ្មានការអនុញ្ញាតិស្របច្បាប់ឲ្យធ្វើការបង្កើបបង្ហាញ ឬប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្មបែបនោះឡើយ។*

មាត្រានេះគ្របដណ្តប់ទាំងស្ថានភាព ដែលបុគ្គលម្នាក់បានបង្កើបបង្ហាញ ឬប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្មដោយខុសច្បាប់ ដោយមិនមានការអនុញ្ញាតិឲ្យធ្វើដូច្នេះឡើយ។ នៅក្នុងករណីនេះ មាត្រានេះគ្របដណ្តប់លើស្ថានភាព ដែលនិយោជិតរបស់ក្រុមហ៊ុនមួយ ដែលកាន់កាប់ការសម្ងាត់ពាណិជ្ជកម្មដោយស្របច្បាប់ បានលក់ដោយខុសច្បាប់ទៅឲ្យបុគ្គលណាមួយផ្សេងទៀត ឬដោយទុកឲ្យក្រុមហ៊ុននោះ ប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្មដើម្បីបំរើផលប្រយោជន៍ផ្ទាល់របស់គាត់។ ដើម្បីរួចផុតពីការទទួលខុសត្រូវ អ្នកបង្កើបបង្ហាញ ឬអ្នកប្រើប្រាស់ត្រូវតែបង្ហាញពីការអនុញ្ញាតស្របច្បាប់ដើម្បីធ្វើការបង្កើបបង្ហាញ ឬដើម្បីប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្មនេះ ដោយការយល់ព្រមដោយតណ្ហឹ ឬដោយជាក់លាក់។ ការបកស្រាយដោយសេរី និងដោយទូលាយត្រូវបានធ្វើឡើងដោយការបង្កើតពាក្យថា **ការអនុញ្ញាតិស្របច្បាប់**។

## ផ្នែកទី២៖ ប្រភេទនៃការទទួលខុសត្រូវការបំពានការសម្ងាត់ពាណិជ្ជកម្ម

### កថាខណ្ឌទី១៖ ប្រភេទនៃការទទួលខុសត្រូវក្រោមក្របខ័ណ្ឌអន្តរជាតិ

ទោះបីជាប្រទេសមួយចំនួន បានទទួលស្គាល់ និងអនុវត្តការការពារការសម្ងាត់ជាមកហើយក៏ដោយ ក៏ការទទួលខុសត្រូវមានភាពខុសគ្នាទៅតាមច្បាប់ និងគោលការណ៍នៅក្នុងប្រទេសនោះ។

### វាក្យខ័ណ្ឌទី១៖ ការទទួលខុសត្រូវក្រោមក្របខ័ណ្ឌសហគមន៍អឺរ៉ុប

វិធានការ នីតិវិធី និងដំណោះស្រាយមានចែងនៅក្នុងសំណើសម្រាប់សេចក្តីបង្គាប់បញ្ជារបស់សភា និងក្រុមប្រឹក្សាអឺរ៉ុប ស្តីអំពីការការពារការលាក់បាំង **ចំណេះធ្វើ និងព័ត៌មានអាជីវកម្ម** ប្រឆាំងនឹងលទ្ធកម្ម ការប្រើប្រាស់ និងបង្កើបបង្ហាញខុសច្បាប់[55]។ ជំពូកទី ៣ នៃ បានបង្កើតវិធានការ នីតិវិធី និងដំណោះស្រាយ ដែលគួរតែមានសម្រាប់អ្នកកាន់កាប់ការសម្ងាត់ពាណិជ្ជកម្ម នៅក្នុងករណីមានលទ្ធកម្ម ការប្រើប្រាស់ ឬការបង្កើបបង្ហាញខុសច្បាប់នៃការសម្ងាត់ពាណិជ្ជកម្មដោយតតីយជន។ ផ្នែកទី ១ កំណត់ពីគោលការណ៍ទូទៅ ដែលអនុវត្តចំពោះឧបករណ៍អនុវត្តស៊ីវិលដើម្បីទប់ស្កាត់និងបង្ក្រាបសកម្មភាពនីតិវិកម្មធន (misappropriation) នៃការសម្ងាត់ពាណិជ្ជកម្មឲ្យមានប្រសិទ្ធិភាពគួរឱ្យកត់សម្គាល់ យុត្តិធម៌ និងសមាមាត្រ[56] និងការការពារដើម្បីទប់ស្កាត់វិវាទដោយរំលោភបំពាន[57]។

---

[55] Proposal for a *Directive of the European Parliament and of the Council on the Protection of Undisclosed Know-how and Business Information (trade secrets) against their unlawful acquisition, use and disclosure*/*COM/2013/0813final-2013/0402 (COD)*

[56] ដូចលេខខាងលើ, មាត្រា ៥។

[57] ដូចលេខខាងលើ, មាត្រា ៦។

យ៉ាងណាមិញ យើងមិនមានឃើញមានបញ្ញត្តិណានៅក្រោមសេចក្តីបង្គាប់បញ្ជានេះ ចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយគឺមានតែការទទួលខុសត្រូវ និងនីតិវិធីរដ្ឋប្បវេណីប៉ុណ្ណោះ នៅពេលមានការរំលោភបំពានកើតឡើង។ សំណង ត្រូវបានផ្តល់ទៅម្ចាស់សិទ្ធិពិតប្រាកដ សមស្របទៅនឹងតម្លៃដែលខូចខាត[58]។ នេះអាចកើតមានឡើងតែនៅក្នុងច្បាប់របស់សហគមន៍អ៊ឺរ៉ុបតែប៉ុណ្ណោះ មានន័យថា ការទទួលខុសត្រូវព្រហ្មទណ្ឌ ឬការទទួលខុសត្រូវផ្សេងៗទៀត អាចត្រូវបានអនុវត្តនៅក្រោមច្បាប់ជាតិ នៃសមាជិកអ៊ឺរ៉ុបនីមួយៗ។

## **វាក្យខ័ណ្ឌទី២៖ ការទទួលខុសត្រូវក្រោមក្របខ័ណ្ឌអាមេរិក**

ការការពារការសម្ងាត់ពាណិជ្ជកម្ម គឺអាចអនុវត្តបានក្រោមបទប្បញ្ញត្តិព្រហ្មទណ្ឌផ្សេងៗរបស់សហរដ្ឋអាមេរិក។ ច្បាប់ជាតិ ស្តីពី អំពើនៃការលួចទ្រព្យសម្បត្តិ នៅឆ្នាំ១៩៩៤ (National Stolen Property Act "NSPA") ត្រូវបានយកមកអនុវត្តនៅក្នុងកាលៈទេសៈមួយ នៅពេលដែលមានការលួចទ្រព្យសម្បត្តិជាក់ស្តែង ដែលទាក់ទងទៅនឹងការសម្ងាត់ពាណិជ្ជកម្ម។

បន្ថែមពីនេះទៅទៀត នៅក្រោមបទប្បញ្ញត្តិស្តីពី ការកែសារតាមរយៈបណ្តាញអេឡិចត្រូនិច និងការលួចបន្លំខាងបណ្តាញខ្សែភ្លើង នៅឆ្នាំ១៩៩៤ (the 1994 Mail and Wire Fraud Statutes "MWFS") ទោសប្បញ្ញត្តិព្រហ្មទណ្ឌ ត្រូវបានអនុម័តឲ្យប្រើ ឬការប្រើប្រាស់សាកល្បង នូវសេវាសារតាមរយៈបណ្តាញអេឡិចត្រូនិច និងខ្សែភ្លើង ដើម្បីទប់ស្កាត់នូវអំពើលួចបន្លំ/បោកប្រាស់។ ភាពខុសគ្នាពី ច្បាប់ស្តីពី ការលួចទ្រព្យសម្បត្តិ នៅឆ្នាំ១៩៩៤ គឺមានបទប្បញ្ញត្តិខ្លះ អាចអនុវត្តបានចំពោះការលួចទ្រព្យសម្បត្តិជាក់ស្តែង ឬសិទ្ធិនៃការលួចដោយមិនជាក់លាក់ដែលទាក់ទងទៅនឹងការសម្ងាត់ពាណិជ្ជកម្ម។ នៅក្នុងរាល់អង្គហេតុទាំងអស់ ដើម្បីចាត់ទុកថាជាការលួចបន្លំបាន លុះត្រាណាតែមានការប្រើប្រាស់នូវសារអេឡិចត្រូនិច ឬបណ្តាញខ្សែភ្លើងនោះជាមុនសិន។

ទោសប្បញ្ញត្តិព្រហ្មទណ្ឌ ចំពោះការលួចការសម្ងាត់ពាណិជ្ជកម្មក៏បានចែងផងដែរ នៅក្រោម *1994 Racketeer Influenced and Corrupt Organizations Act "RICO")*។ អត្ថន័យនៃពាក្យ "racketeering activity" មានន័យសំដៅទៅលើការលួចក្នុងបរិបទស្តីពីច្បាប់ស្តីពី ការសម្ងាត់ពាណិជ្ជកម្ម រាប់បញ្ចូលទាំងការលួចបន្លំសារអេឡិចត្រូនិច ឬខ្សែភ្លើង គឺជាសកម្មភាពដែលត្រូវបានហាមឃាត់ដោយច្បាប់ជាតិ ស្តីពី អំពើនៃការលួចទ្រព្យសម្បត្តិ នៅឆ្នាំ១៩៩៤ និងជាសម្អាងនៃការលួចទ្រព្យសម្បត្តិ[59]។

សរុបមក សហរដ្ឋអាមេរិកមានការយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើប្រព័ន្ធច្បាប់របស់ប្រទេសខ្លួន ជាក់ស្តែងច្បាប់នានាដែលចែងទាក់ទងទៅនឹងការសម្ងាត់ពាណិជ្ជកម្មក៏មិនតិចដែរ ដូចដែលបានបកស្រាយយ៉ាងខ្លះៗនោះ ព្រោះថាវិស័យពាណិជ្ជកម្ម គឺជាគោលជំហរដ៏រឹងមាំមួយទៅលើវិស័យសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក ក៏ដូចជាប្រទេសផ្សេងៗទៀតផងដែរ។

---

[58] ដូចលេខខាងលើ, មាត្រា ១៣។

[59] *1994 Racketeer Influenced and Corrupt Organizations Act,* as published with U.S Code : *18-Crimes and Criminal Procedure,* Chapter 96, Sections 1961 to 1968.

ជាក់ស្តែងដូចជា FOIA ការផ្សព្វផ្សាយការសម្ងាត់ពាណិជ្ជកម្ម ដែលត្រូវបានផ្សព្វផ្សាយដោយគ្មានការអនុញ្ញាត្តិជាមុនរវាងម្ចាស់នៃព័ត៌មានសម្ងាត់ និងភ្នាក់ងាររដ្ឋាភិបាល គឺត្រូវបានហាមឃាត់។ វាអាចធ្វើទៅបានដរាបណាតែមានការស្នើសុំតែប៉ុណ្ណោះ។

ម្យ៉ាងទៀត ទាក់ទងទៅនឹងច្បាប់ស្តីពី ការសម្ងាត់ពាណិជ្ជកម្ម របស់សហរដ្ឋអាមេរិក ទោសប្បញ្ញត្តិវា គឺមានដូចជាសំណង រួមទាំងទោសព្រហ្មទណ្ឌផងដែរ ដែលវាឆ្លុះបញ្ចាំងថា ព័ត៌មានសម្ងាត់ខាងវិស័យពាណិជ្ជកម្ម គឺត្រូវបានសហរដ្ឋអាមេរិកយកចិត្តទុកដាក់យ៉ាងខ្លាំង។

## កថាខណ្ឌទី២៖ ប្រភេទនៃការទទួលខុសត្រូវក្រោមក្របខ័ណ្ឌជាតិ (កម្ពុជា)

ការទទួលខុសត្រូវនៅកម្ពុជាបែងចែកចេញជាពីរ គឺសំណងការខូចខាត និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ។

### វាក្យខ័ណ្ឌទី១៖ សំណងការខូចខាត

ក្រៅពីសេចក្តីសម្រេចបណ្តោះអាសន្ន TRIPS ក៏បានផ្តល់នូវសំណង និងកម្រៃខាងផ្លូវច្បាប់ផងដែរ។ មាត្រា ៤៥ ចែងថា៖

១. អាជ្ញាធរយុត្តធិការត្រូវមានសិទ្ធិអំណាចបញ្ជាអ្នករំលោភបំពានចេញសំណងសមស្របឲ្យអ្នកកាន់កាប់សិទ្ធិ ដែលទទួលរងការខូចខាតនូវការខូចខាតរបស់ខ្លួនដែលបង្កពីការរំលោភបំពានសិទ្ធិលើកម្មសិទ្ធិបញ្ញារបស់បុគ្គលនោះ ដោយអ្នករំលោភបំពានម្នាក់ ដែលបានដឹង ឬមានមូលហេតុគ្រប់គ្រាន់នឹងដឹង ហើយមានចំណែកពាក់ព័ន្ធនឹងសកម្មភាពរំលោភរំពាននោះ។

២. អាជ្ញាធរយុត្តាធិការត្រូវមានសិទ្ធិអំណាចផងដែរ ដើម្បីបញ្ជាឲ្យអ្នករំលោភបំពានចេញសំណងចំពោះការចំណាយទាំងឡាយរបស់អ្នកកាន់កាប់សិទ្ធិដែលអាចរួមមានទាំងកម្រៃសមស្របរបស់មេធាវីផងដែរ។ នៅក្នុងករណីសមស្រប សមាជិកទាំងឡាយអាចអនុញ្ញាត្តិឲ្យអាជ្ញាធរខាងយុត្តាធិការធ្វើការបញ្ជាឲ្យរកមកវិញនូវប្រាក់ចំណេញ និង/ឬ ពុំមានហេតុផលសមស្របនឹងដឹង ហើយបានជាប់ជំពាក់ទៅនឹងសកម្មភាពរំលោភបំពាននេះ។

### វាក្យខ័ណ្ឌទី២៖ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ

យោងតាមមាត្រា ៦១ នៃផ្នែកទី៥ នីតិវិធីព្រហ្មទណ្ឌ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា បានចែងថា:

*សមាជិកទាំងឡាយត្រូវចែងពីនីតិវិធីព្រហ្មទណ្ឌ និងទោសប្បញ្ញត្តិ ដើម្បីអនុវត្តយ៉ាងហោចណាស់នៅក្នុងករណីនៃការក្លែងបន្លំម៉ាកដោយចេតនា ឬការលួចចម្លងសិទ្ធិអ្នកនិពន្ធក្នុងកម្រិតពាណិជ្ជកម្ម។ ទណ្ឌកម្មទាំងឡាយ រួមមានការដាក់ពន្ធនាគារ និង/ឬទោសពិន័យជាប្រាក់ដែលសមស្របដើម្បីឲ្យភាពរាងចោល ហើយឲ្យស្របតាមកម្រិតនៃភាពធ្ងន់ធ្ងររបស់បទល្មើសដែលពាក់ព័ន្ធ។ ក្នុងករណីសមស្រប ទណ្ឌកម្មទាំងឡាយ រួមមានផងដែរ ការរឹបអូស ការដកហូត និងការបំផ្លាញចោលទំនិញល្មើស និងសម្ភារៈ និងឧបករ*

*ណីទាំងឡាយដែលប្រើប្រាស់ជាចម្បងដើម្បីប្រព្រឹត្តបទល្មើស។ សមាជិកទាំងឡាយ អាចចែងអំពីនីតិវិធីព្រហ្មទណ្ឌ និងទោសប្បញ្ញត្តិ ដើម្បីអនុវត្តក្នុងករណីផ្សេងទៀតនៃការរំលោភបំពានកម្មសិទ្ធិបញ្ញា ជាពិសេសករណីដែលការរំលោភបំពានទាំងនេះត្រូវបានធ្វើឡើងដោយចេតនា និងក្នុងកម្រិតពាណិជ្ជកម្ម។*

ដោយច្បាប់ស្តីពី ការសម្ងាត់ពាណិជ្ជកម្មពុំទាន់បានចែងពីទោសប្បញ្ញត្តិខាងព្រហ្មទណ្ឌ នាំឲ្យមាត្រាខាងលើនេះ ត្រូវបានយកមកអនុវត្ត មានន័យថា ប្រសិនបើមាននូវការរំលោភបំពាននូវការសម្ងាត់ពាណិជ្ជកម្ម ដែលប្រព្រឹត្តឡើងដោយចេតនា និងក្នុងកម្រិតពាណិជ្ជកម្ម នោះសំណងការខូចខាតត្រូវតែមាន ហើយទោសព្រហ្មទណ្ឌក៏មិនត្រូវលើកលែងផងដែរ។

## ផ្នែកទី៣៖ នីតិវិធីនៃការដោះស្រាយវិវាទ

### កថាខណ្ឌទី១៖ ដំណោះស្រាយក្នុងប្រព័ន្ធតុលាការ

#### វាក្យខ័ណ្ឌទី១៖ សិទ្ធិទទួលបានការជំនុំជំរះដោយយុត្តិធម៌

ប្រសិនបើ ឋានៈនៃការសម្ងាត់ពាណិជ្ជកម្មនឹងត្រូវបានបង្កើតឡើង ដំណោះស្រាយដែលត្រូវធ្វើឡើយនៅចំពោះមុខតុលាការកម្ពុជាគឺជា *លទ្ធភាពនៃកិច្ចការពារស្របច្បាប់លើព័ត៌មានសម្ងាត់នេះនៅក្នុងការត្រួតពិនិត្យរបស់តុលាការពីការបង្ហើបបង្ហាញ ការទទួលបាន ឬការប្រើដោយបុគ្គលផ្សេងទៀត។* និយាយឲ្យចំ វាសំដៅទៅលើដីកាសម្រេចបណ្តោះអាសន្ន ដែលអនុញ្ញាត្តិឲ្យក្រុមហ៊ុនមានសិទ្ធិលើការសម្ងាត់ពាណិជ្ជកម្ម ក្នុងការហាមឃាត់បុគ្គលផ្សេងទៀត ពីការប្រើប្រាស់ព័ត៌មាននេះ។ សិទ្ធិដែលត្រូវបានកំណត់ដោយដីកាសម្រេចបណ្តោះអាសន្ននេះអាចធ្វើទៅបានតែក្នុងករណីមួយចំនួនប៉ុណ្ណោះ។ ឧទាហរណ៍ តុលាការកម្ពុជាអាចត្រូវបានស្នើសុំឲ្យទទួលយក និងអនុវត្តសេចក្តីសម្រេចបណ្តោះអាសន្នរបស់តុលាការបរទេស នៅពេលដែលការប្រើប្រាស់ខុសច្បាប់លើព័ត៌មាននោះកំពុងតែកើតមានឡើងនៅកម្ពុជា។ បញ្ហានេះជាប់ពាក់ព័ន្ធនឹងវិវាទច្បាប់ និងការទទួលស្គាល់ និងការអនុវត្តន៍សេចក្តីសម្រេចតុលាការបរទេសជាទូទៅ។

ជាចុងក្រោយ គឺការដោះស្រាយបញ្ហានៃការធ្វើសំណងលើការខូចខាតដោយការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្មមិនស្របច្បាប់។ បញ្ហានេះទាក់ទងនឹងផ្នែកទី ៣ នៃកិច្ចព្រមព្រៀង TRIPS ដែលពាក់ព័ន្ធនឹង *ការអនុវត្តន៍សិទ្ធិលើកម្មសិទ្ធិបញ្ញា*។ បញ្ហាដែលចោទឡើងគឺថា តើការខូចខាតទាំងនេះត្រូវតែកំណត់ដោយការបាត់បង់ដែលកើតមានឡើងពីលទ្ធផលនៃ ការប្រើប្រាស់ព័ត៌មានសម្ងាត់មិនស្របច្បាប់ ដោយក្រុមហ៊ុនដែលធ្វើឲ្យខូចខាត ឬក៏ធៀបទៅនឹងផលប្រយោជន៍ដែលទទួលបានដោយបុគ្គលដែលរំលោភបំពាននោះ ឬក៏ធៀបនឹងផលប្រយោជន៍ដែលនឹងទទួលបានដោយអ្នកការពារព័ត៌មាននោះ។

ការណែនាំទី ១ ដែលទាក់ទងនឹងព័ត៌មានសម្ងាត់ត្រូវផ្អែកទៅលើបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង TRIPS ដែលទាក់ទងនឹងដំណោះស្រាយនានា។ ប៉ុន្តែ វាគ្រាន់តែជាទិដ្ឋភាពបន្ទាប់បន្សំបន្ថែមនៃការពិភាក្សាប៉ុណ្ណោះ ដោយសារតែអង្គហេតុនោះពាក់ព័ន្ធនឹងសកម្មភាពសាធារណៈ។ គេ

សន្មត់ថា ការចែងជាច្បាប់បែបនេះ ហាក់បីដូចជាបង្កើតស្ថាប័នក្នុងកិច្ចការពារការសម្ងាត់ពាណិជ្ជកម្មនៅក្នុងរដ្ឋាភិបាល ហើយដែលដំណើរការទាំងអស់ត្រូវគ្រប់គ្រងដោយក្រសួងសុខាភិបាល។ បទប្បញ្ញត្តិនៃដីកាសម្រេចបណ្តោះអាសន្នត្រូវបានកំណត់យ៉ាងសមស្រប នៅក្នុងកាលៈទេសៈបែបនេះ ដោយរក្សានូវឆន្ទានុសិទ្ធិរបស់ក្រសួងសុខាភិបាលក្នុងករណីចាំបាច់ និងកិច្ចការពារអភ័យឯកសិទ្ធិផ្តាច់មុខរបស់កម្ពុជានៅក្នុងប្រព័ន្ធយុត្តាធិការរបស់ខ្លួន។ ចំពោះបញ្ហាការសម្ងាត់ពាណិជ្ជកម្មដែលប្តឹងដោយឯកជន ប្រឆាំងនឹងសកម្មភាពរបស់រដ្ឋាភិបាល ការឲ្យសងគឺជាចំនុចសំខាន់ ដោយសារជាយន្តការមួយដែលទាក់ទងនឹងការគ្រប់គ្រងមិនត្រឹមត្រូវ។ ដូច្នេះ វាជាលក្ខណៈពិសេស នៅក្នុងវិស័យច្បាប់ដែលជាធម្មតាទាក់ទងនឹងការប្រព្រឹត្តិខុសដោយចេតនា។

ដំណោះស្រាយទាំងនេះ មានចែងនៅក្នុងផ្នែកទី ៣ នៃកិច្ចព្រមព្រៀង TRIPS ហើយវាទាមទារឲ្យមានដីកាសម្រេចបណ្តោះអាសន្ន និងសំណងលើការខូចខាតដែលត្រូវចែងដោយច្បាប់ក្នុងស្រុករបស់បណ្តាប្រទេសសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។

### ខាក្យខ័ណ្ឌទី២៖ ដីកាសម្រេចបណ្តោះអាសន្ន

កាតព្វកិច្ចទាំងនេះ មានរាប់ទាំងគោលការណ៍នៃការជំនុំជំរះដោយយុត្តិធម៌។ ដំណោះស្រាយសំខាន់មួយតាមរយៈដីកាសម្រេចបណ្តោះអាសន្ន ដែលមានចែងក្នុងមាត្រា ៤៥៖

*១. អាជ្ញាធរខាងយុត្តាធិការ ត្រូវមានអំណាចក្នុងការបញ្ជាឲ្យភាគីមួយបញ្ឈប់សកម្មភាពរំលោភបំពាន ដូចជា ការដាក់បញ្ជាដើម្បីការពារកុំឲ្យជ្រៀតចូលទៅក្នុងចរន្តពាណិជ្ជកម្មនៅក្នុងដែនយុត្តាធិការរបស់ខ្លួននូវទំនិញនាំចូល ដែលពាក់ព័ន្ធនឹងការរំលោភបំពានកម្មសិទ្ធិបញ្ញា ដែលការនេះបានធ្វើភ្លាមៗក្រោយពីការបំពេញបែបបទគយរបស់ទំនិញពាក់ព័ន្ធនេះរួចហើយ។ សមាជិកទាំងឡាយ មិនបានតម្រូវឲ្យប្រើប្រាស់អំណាចនេះចំពោះ ប្រធានបទដែលត្រូវបានការពារដែលទទួលបាន ឬបញ្ជាដោយបុគ្គលណាមួយមុនពេលដឹង ឬមុនពេលមានហេតុផលគ្រប់គ្រាន់ ដើម្បីដឹងថា ទំនិញដែលជាប្រធានបទពាក់ព័ន្ធនោះ មានជាប់ជំពាក់នឹងការរំលោភបំពានកម្មសិទ្ធិបញ្ញាណាមួយ។*

*២. ដោយមិនគិតពីបទប្បញ្ញត្តិផ្សេងៗនៃជំពូកនេះ និងចែងថា បទប្បញ្ញត្តិនានានៃជំពូកទី ២ ដែលពាក់ព័ន្ធជាពិសេសដល់ការប្រើប្រាស់ដោយរដ្ឋាភិបាល ឬដោយតតីយជនដែលបានទទួលការអនុញ្ញាត្តិពីរដ្ឋាភិបាល ដោយគ្មានការអនុញ្ញាត្តិពីអ្នកកាន់កាប់សិទ្ធិ ដែលត្រូវបានគោរពតាមនោះទេ សមាជិកទាំងឡាយអាចកំណត់ព្រំដែននៃដំណោះស្រាយ ដែលអាចធ្វើបានប្រឆាំងទល់នឹងការប្រើប្រាស់នេះ ដើម្បីផ្តល់ជាណងលាភការៈតាមខ្លឹមសារនៃ អនុកថាខណ្ឌ (ជ) នៃមាត្រា ៣១។ ក្នុងករណីផ្សេងទៀត ដំណោះស្រាយតាមជំពូកនេះនឹងត្រូវបានអនុវត្ត ឬនៅពេលដែលដំណោះស្រាយទាំងនេះមិនស៊ីសង្វាក់គ្នាទៅនឹងច្បាប់នៃប្រទេសសមាជិកមួយនោះ ដីកាប្រកាសវិនិច្ឆ័យសេចក្តី និងសំណងគ្រប់គ្រាន់មួយត្រូវតែបានគេផ្តល់ឲ្យ។*

### កថាខណ្ឌទី២៖ ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ

នៅក្រោមច្បាប់ស្តីពីព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏មានចែងអំពី ដំណោះស្រាយក្រៅប្រព័ន្ធតុលាការផងដែរ។ មាត្រា ១៩នៃច្បាប់នេះចែងថា៖

*ភាគីនៃវិវាទដែលពាក់ព័ន្ធនឹងការសម្ងាត់ពាណិជ្ជកម្ម អាចព្រមព្រៀងគ្នាលើកទៅដោះស្រាយតាមរយៈការផ្សះផ្សារ សន្ធានកម្ម ឬមជ្ឈត្តការ នូវវិវាទណាមួយដែលបានកើតឡើង ឬអាចកើតឡើងរវាងភាគីពាក់ព័ន្ធទៅនឹងព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្មក្រោមវិសាលភាពនៃច្បាប់នេះ ដោយអនុឡោមតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។*

បទប្បញ្ញត្តិនេះ លើកទឹកចិត្តដល់ភាគីជម្លោះ ដើម្បីពិចារណាលើដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។ ការផ្លាស់ប្តូរដ៏សំខាន់បំផុតមួយនៅក្នុងការធ្វើបណ្តឹងនៅកាណាដា និងប្រទេសដទៃទៀត គឺជាការបញ្ជាក់បន្ថែមលើមធ្យោបាយនៃការដោះស្រាយជម្លោះ ឬការកំណត់នូវរឿងក្តីទាំងឡាយ ដោយពុំចាំបាច់ប្តឹងទៅតុលាការឡើយ។ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការមានការវិវត្តន៍ជាច្រើនទម្រង់។

**វាក្យខ័ណ្ឌទី១៖ ដំណោះស្រាយតាមការផ្សះផ្សារ ឬការសម្រុះសម្រួល**

ដំណោះស្រាយតាមរយៈការផ្សះផ្សារ ឬការសម្រុះសម្រួល គឺមិនចងកាតព្វកិច្ចទេ ដោយមិនប៉ះពាល់ដល់ការចចាររវាងភាគីដែលដឹកនាំដោយមេធាវីឯករាជ្យ ឬអតីតចៅក្រម។ អ្នកសម្រុះសម្រួល ជាធម្មតាមិនត្រូវកាន់ជើងភាគីណាមួយ ឬផ្តលនូវគំនិតលើលទ្ធផលនៃរឿងក្តីឡើយ វៀរលែងតែភាគីទាំងនោះស្នើសុំរួមគ្នាអោយអ្នកសម្រុះសម្រួលធ្វើដូច្នេះ។ ការសម្រុះសម្រួល គឺជាដំណោះស្រាយបែបបច្ចេកទេសមួយដ៏មានតម្លៃបំផុត ដោយការពិភាក្សាជាមួយភាគីទាំងនោះលើហានិភ័យ និងតម្លៃនៃបណ្តឹង និងដោយការលើកទឹកចិត្តដល់ភាគីទាំងនោះក្នុងការដោះស្រាយជម្លោះ។ គេតែងតែនិយាយថា ដំណោះស្រាយដោយការសម្រុះសម្រួល គឺជាដំណោះស្រាយមួយដែលភាគីទាំងពីរជៀសផុតពីការសម្រុះសម្រួលដែលមិនសប្បាយចិត្ត ដោយសារតែភាគីទាំងពីរត្រូវធ្វើតាមការសន្យា។

**វាក្យខ័ណ្ឌទី២៖ ដំណោះស្រាយតាមមជ្ឈត្តការ**

ដំណោះស្រាយតាមមជ្ឈត្តការ សំដៅលើការបង្កើតតុលាការឯកជន។ ជំនួសដោយចៅក្រមភាគីអាចធ្វើការតែងតាំងមជ្ឈត្តករម្នាក់ ឬបីនាក់ ដើម្បីដោះស្រាយវិវាទ។ ជាទូទៅ ការព្រមព្រៀងនេះមានចែងនៅក្នុងខមជ្ឈត្តការមួយ ដែលមាននៅក្នុងកិច្ចសន្យារវាងភាគី។ កិច្ចព្រមព្រៀងមិនបង្ហើបបង្ហាញ និងការរក្សាការសម្ងាត់រវាងនិយោជិត និងនិយោជក អាចមានចែងពីខមជ្ឈត្តការ។ ករណីមិនមានខនេះ ភាគីអាចព្រមព្រៀងគ្នា ដាក់វិវាទរបស់ពួកគេអោយដោះស្រាយតាមមជ្ឈត្តការ។ ដំណោះស្រាយនេះ មិនទំនងនឹងអាចធ្វើទៅទេ ដោយសារតម្លៃនៃដំណើរការមជ្ឈត្តការថ្លៃពេក។ នៅក្នុងដំណើរការមជ្ឈត្តការនេះ ភាគីត្រូវបានតម្រូវអោយបង់ប្រាក់ដល់មជ្ឈត្តករ ហើយប្រសិនបើមានមជ្ឈត្តករច្រើននាក់ត្រូវបានតែងតាំងនោះ ការដោះស្រាយជម្លោះតាមមជ្ឈត្តការ អាចក្លាយទៅជាដំណើរការមួយដែលមានតម្លៃថ្លៃ។ ប៉ុន្តែ ទោះជាដំណើរការនេះថ្លៃក៏ដោយ ក៏មជ្ឈត្តការនេះនៅតែមានប្រយោជន៍។ ផលប្រយោជន៍ទាំងនេះ ត្រូវរួមបញ្ចូលទាំងការជ្រើសរើសចៅក្រមម្នាក់ ឬច្រើននាក់ ដែលនឹងត្រូវសម្រេចបញ្ចប់ក្នុងជម្លោះនេះ។

មជ្ឈត្តករ អាចត្រូវបានជ្រើសរើសពីអ្នកដែលមានជំនាញជាក់លាក់ទៅតាមប្រភេទជម្លោះ។ ការដោះស្រាយតាមបែបមជ្ឈត្តការ ត្រូវបានធ្វើឡើងយ៉ាងរហ័ស ហើយបើកសិទ្ធិតិចតួចបំផុតអោយប្តឹងឧទ្ធរណ៍។ The UNICITRAL Model Law ស្តីពីមជ្ឈត្តការ ចែងពីសិទ្ធិដ៏តូចចង្អៀតមួយដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋាននៃការកាត់ក្តីដោយគ្មានភាពយុត្តិធម៌ ឬអស់អាជ្ញាយុកាលននៃការពឹងពាក់លើមជ្ឈត្តការ[60]។

បទប្បញ្ញត្តិនៅក្នុងមាត្រានេះ មិនសូវលើកទឹកចិត្តអោយមានដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ប៉ុន្តែមិនបានតម្រូវមិនអោយធ្វើដូចច្នោះដែរ។ ការសម្រុះសម្រួល អាចធ្វើទៅបានចំពោះគ្រប់ភាគី មិនថាភាគីនោះមាន ឬ ក្រុមហ៊ុណ្ណានោះទេ។ ដំណោះស្រាយតាមមជ្ឈត្តការ ទំនងជាតម្រូវអោយមានការវិនោយោគខាងផ្នែកហិរញ្ញវត្ថុច្រើន ដូច្នេះហើយ វាទំនងជាបង្ហាញថា និយោជិត និងនិយោជកមិនត្រូវស្ថិតនៅក្នុងឋានៈមួយស្មើគ្នានោះទេ។

[60] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៤៨៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានកំឡុងពេលខ្លី)។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះ យើងមើលឃើញថា **ការសម្ងាត់ពាណិជ្ជកម្ម** មិនទាន់ក្លាយជាប្រធានបទកំពុងពេញនិយមនៅកម្ពុជានៅឡើយទេ ហើយវាគឺជាប្រធានបទថ្មីក្នុងការពិភាក្សារបស់អ្នកសិក្សាស្រាវជ្រាវ ព្រមទាំងស្ថាប័ននីតិប្រតិបត្តិ។ ប៉ុន្តែប្រធានបទនេះ ត្រូវបានបង្កើតឡើង និងអនុវត្តជាយូរយារណាស់មកហើយនៅក្នុងប្រទេសអភិវឌ្ឍន៍មួយចំនួន ដូចជាប្រទេសជាសមាជិកសហភាពអ៊ឺរ៉ុប សហរដ្ឋអាមេរិក កាណាដា និងរ៉ូម៉ានីជាដើម។

ជាមួយនឹងអន្តរជាតិជាតូបនីយកម្មទីផ្សារ ការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្មបានក្លាយទៅជាចំនុចជាអាទិភាពសម្រាប់ប្រទេសឧស្សាហកម្ម។ តាមរយៈមធ្យោបាយដែលការធ្វើពាណិជ្ជកម្មនេះអាចនឹងសម្រេចទៅបាន គឺត្រូវធ្វើតាមរយៈកិច្ចការពារការសម្ងាត់ពាណិជ្ជកម្ម។ នៅក្នុងបណ្តាប្រទេសពាណិជ្ជកម្មទាំងឡាយ ការសម្ងាត់ពាណិជ្ជកម្មត្រូវបានទទួលស្គាល់ថា ជាសិទ្ធិស្របច្បាប់ ដែលខុសពីសិទ្ធិលើប្រកាសនីយបត្រតក្កកម្ម ដែលជាទូទៅត្រូវបានកំណត់ដោយលក្ខខន្តិកៈយ៉ាងតឹងរឹង បើទោះជាពាក្យនេះមានន័យទូលំទូលាយក៏ដោយ។ ជាធម្មតា កិច្ចការពារដែលត្រូវធ្វើគឺដើម្បីប្រឆាំងទាស់នឹងការទទួលបាននូវការបង្ហើបបង្ហាញ ឬការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្មមិនស្របច្បាប់ ក្នុងគោលដៅធ្វើអោយខូចប្រយោជន៍ដល់បុគ្គលកាន់កាប់សិទ្ធិស្របច្បាប់លើការសម្ងាត់ពាណិជ្ជកម្មនេះ។ កិច្ចការពារសម្ងាត់ពាណិជ្ជកម្ម គឺបញ្ហាថ្មីមិនគួរអោយជឿ និងជាបញ្ហាចាស់គួរអោយកត់សម្គាល់។ វាជាបញ្ហាថ្មីមួយដោយសារតែសម្ពាធលើបណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍ក្នុងការផ្តល់នូវធ្វើ ដែលបណ្តាប្រទេសជឿនលឿនគិតថា ជាកិច្ចការពារកម្មសិទ្ធិបញ្ញាប្រកបដោយប្រសិទ្ធិភាព។

នៅក្នុងប្រទេសដែលជាសមាជិកសហភាពអ៊ឺរ៉ុប បានពង្រីកការការពារការសម្ងាត់ពាណិជ្ជកម្ម និង ទទួលអោយមានបណ្តឹងសងជម្ងឺចិត្តចំពោះការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្មមិនសមរម្យតាំងពីឆ្នាំ ១៨១៧ និង ១៨៣៧ មកម្លេះ។ បើទោះជាការសម្ងាត់ពាណិជ្ជកម្មនេះ បានកើតជាយូរមកហើយក៏ដោយ ក៏មូលដ្ឋានច្បាប់ចំពោះកិច្ចការពារការសម្ងាត់ពាណិជ្ជកម្ម មិនទាន់បានបង្កើតឲ្យច្បាស់លាស់ឡើយ សូម្បីតែនៅតាមបណ្តាប្រទេសអភិវឌ្ឍន៍នានាក៏ដោយ។ ឧទាហរណ៍ នៅតាមបណ្តាប្រទេសដែលប្រកាន់យកប្រព័ន្ធច្បាប់ Common Law តាមករណីជាក់ស្តែង នៅពេលដែលគ្មានច្បាប់ដោយឡែក តុលាការត្រូវពឹងផ្អែកលើសមធម៌ (សញ្ញាណនៃកិច្ចធានា សេចក្តីចម្រើនឥតហេតុ និងការរំលោភលើសេចក្តីទុកចិត្ត) ពឹងលើកិច្ចសន្យា អំពើអនីត្យានុកូល ជាពិសេសការប្រកួតប្រជែងមិនស្មោះត្រង់ និងការសន្មត់តាមផ្លូវច្បាប់ នៅក្នុងបណ្តឹងរដ្ឋប្បវេណីដើម្បីពង្រឹងការសម្ងាត់ពាណិជ្ជកម្ម។

នៅសហរដ្ឋអាមេរិក តុលាការកំពូលជាអ្នកបង្កើតទស្សនៈ **ការសម្ងាត់ពាណិជ្ជកម្មជាកម្មសិទ្ធិ**។ ដូចគ្នានេះដែរ TRIPS ក៏បានអនុម័តបញ្ចូលការសម្ងាត់ពាណិជ្ជកម្មនៅក្នុងនិយមន័យនៃកម្ម

សិទ្ធិបញ្ញា។ តុលាការកំពូលបានទទួលយកនូវទ្រឹស្តីមួយ ដោយសង្កត់ធ្ងន់ទៅលើការដាក់ទោសលើអំពើខុសច្បាប់ ហើយដូច្នេះ នេះជាគំនិតនៃទំនួលខុសត្រូវក្រៅកិច្ចសន្យា និងក្នុងកិច្ចសន្យា។ ការវិវឌ្ឍន៍នៅក្នុងទ្រឹស្តីនៃកិច្ចការពារការសម្ងាត់ពាណិជ្ជកម្មនេះ ត្រូវបានដាក់បញ្ចូលទៅក្នុង First Restatement of Torts របស់សហរដ្ឋអាមេរិក ដែលត្រូវបានផ្សព្វផ្សាយនៅឆ្នាំ ១៩៣៩។ នៅដើមទស្សវត្សន៍ឆ្នាំ ១៩៨០ គម្រោងបង្កើតក្រមសម្រាប់អនុវត្តការសម្ងាត់ពាណិជ្ជកម្មត្រូវបានបង្កើតឡើង។ ហើយការដាក់បញ្ចូលជាក្រមនេះ បានចេញជាលទ្ធផលនៅឆ្នាំ ១៩៨៥ ដោយមានការអនុម័តច្បាប់ការសម្ងាត់ពាណិជ្ជកម្មរួម របស់សហរដ្ឋអាមេរិក ដែលបច្ចុប្បនេះ ត្រូវបានទទួលយកដោយសមាជិក ៤០រដ្ឋរបស់សហរដ្ឋអាមេរិក ដោយមានការកែប្រែតិចតួចទៅតាមរដ្ឋនីមួយៗ។ ការសម្ងាត់ពាណិជ្ជកម្មត្រូវបានដាក់បញ្ចូលក្នុង Third Restatement of Unfair Competition ដោយមានបំណងទទួលស្គាល់ដោយកម្មវត្ថុនៃកិច្ចការពារត្រូវផ្លាស់ពីប្រព័ន្ធនៃទំនួលខុសត្រូវ ទៅជាប្រព័ន្ធកម្មសិទ្ធិវិញ។ ក៏ប៉ុន្តែ សូម្បីតែច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្មរួមខ្លួនឯង គេមិនឃើញមានការអះអាងជាក់លាក់ណាមួយ ដែលបញ្ជាក់ថា ការសម្ងាត់ពាណីជ្ជកម្ម គឺជាមែកធាងនៃកម្មសិទ្ធិបញ្ញាឡើយ។ ផ្ទុយទៅវិញ TRIPS បានធ្វើការកត់សម្គាល់ទៅលើនិយមន័យថា ការសម្ងាត់ពាណិជ្ជកម្ម គឺជាកម្មសិទ្ធិបញ្ញា។

ការកំណត់និយមន័យការសម្ងាត់ពាណិជ្ជកម្ម អាចត្រូវបានធ្វើឡើងខុសប្លែកពីន័យដើមនៃកម្មសិទ្ធិបញ្ញា បើទោះបីជា TRIPS បានកំណត់និយមន័យថាជា ទម្រង់មួយនៃកម្មសិទ្ធិបញ្ញាក៏ដោយ។ ឧទាហរណ៍ ប្រកាសនីយបត្រតក្កកម្ម ត្រូវបានការពារក្នុងកំឡុងពេលកំណត់មួយជាក់លាក់។ នៅពេលដែលកិច្ចការពារប្រកាសនីយបត្រតក្កកម្មផុតកំណត់ អ្នកណាក៏អាចយកស្នាដៃនេះទៅប្រើប្រាស់ ដោយគ្មានសំណងចំពោះម្ចាស់ប្រកាសនីយបត្រតក្កកម្មឡើយ។ ដើម្បីទទួលបានសិទ្ធិផ្តាច់មុខក្នុងរយៈពេលណាមួយជាកំណត់ តក្កកម្មតម្រូវអោយមានការចុះបញ្ជី ប៉ុន្តែការសម្ងាត់ពាណិជ្ជកម្មមិនតម្រូវអោយមានការចុះបញ្ជីទេ។ ច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម តម្រូវអោយក្រុមហ៊ុនរក្សាគំនិតរបស់ខ្លួនជាសម្ងាត់ ហើយបំផ្លែងគំនិតទាំងនេះអោយមានតម្លៃដោយរក្សានូវទំនាក់ទំនងជាមួយការសម្ងាត់នេះអោយមានជាប្រចាំ។ តាមទ្រឹស្តី កិច្ចការពារការសម្ងាត់ពាណិជ្ជកម្ម មានរយៈពេលយូរអង្វែងជាងប្រកាសនីយបត្រតក្កកម្ម។ ដោយឡែក ច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្មមិនបង្កើតអោយមានសិទ្ធិផ្តាច់មុខទេ ហើយបុគ្គលណាក៏ដោយដែលរកឃើញព័ត៌មានដោយការស្រាវជ្រាវឯករាជ្យ ការផ្សព្វផ្សាយដោយចៃដន្យ ឬវិស្វកម្មបញ្រ្ចាស់ មិនអាចត្រូវបានហាមឃាត់មិនអោយប្រើប្រាស់នោះទេ។ ច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្មទាំងអស់ ត្រូវបង្កើតឡើងក្នុងគោលដៅបង្ការការប្រើប្រាស់ដោយគ្មានការអនុញ្ញាត។

បន្ទាប់ពីបានសិក្សា អំពីវិធានការការសម្ងាត់ពាណិជ្ជកម្ម នៅក្នុងក្របខណ្ឌអន្តរជាតិរួចមកកម្ពុជាគួរតែរៀបចំវិធានការការពារការសម្ងាត់ពាណិជ្ជកម្មនៅក្នុងប្រទេសរបស់ខ្លួន ដើម្បីទាក់ទាញវិនិយោគបរទេស អោយចូលមកបណ្តាក់ទុននៅក្នុងកម្ពុជា ដូច្នេះវាអាចផ្តល់ទំនុកចិត្តបន្ថែមសម្រាប់អ្នកវិនិយោគ។ អ្នកវិនិយោគនឹងមិនមកប្រថុយដាក់ទុននោះទេ ប្រសិនបើគ្មានការអនុវត្តកម្មសិទ្ធិ

បញ្ញានោះ ហេតុដូចនេះ កម្ពុជាត្រូវគិតគូរអំពីការការពារកម្មសិទ្ធិបញ្ញារបស់ខ្លួន ដើម្បីទាញយកប្រយោជន៍ពីសេរីភាវូបនីយកម្មក្នុងលំហូរពាណិជ្ជកម្ម និងវិនិយោគអោយបានពេញលេញ។ កម្ពុជាគួរតែមាននូវរបបគតិយុត្តនេះ កាន់តែឆាប់កាន់តែល្អ ដោយហេតុថា វាក៏ជាផ្នែកសំខាន់មួយក្នុងការជួយជំរុញវិស័យសេដ្ឋកិច្ចផងដែរ។

# អនុសាសន៍

ប្រធានបទ **របបគតិយុត្តនៃការសម្ងាត់ពាណិជ្ជកម្មនេះ** ត្រូវបានលើកយកមកពិភាក្សាក្នុងគោលដៅផ្តល់ប្រយោជន៍ដល់កិច្ចការពារកម្មសិទ្ធិបញ្ញា ដើម្បីជាការលើកទឹកចិត្តដល់ការធ្វើវិនិយោគ។ មិនមានក្រុមហ៊ុនណាមួយហ៊ានមកប្រថុយដាក់ទុននោះទេ ប្រសិនជាគ្មានការការពារកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសនោះ។ ហេតុដូច្នេះហើយ ប្រទេសកម្ពុជាត្រូវការពារកម្មសិទ្ធិបញ្ញារបស់ខ្លួន ប្រសិនបើកម្ពុជា មានបំណងទាញប្រយោជន៍ពីសេរីភាវូបនីយកម្ម នៅក្នុងលំហូរពាណិជ្ជកម្ម និងវិនិយោគអោយបានពេញលេញ។ ប៉ុន្តែបញ្ហាចំបងនោះគឺថា កម្ពុជាគួរតែអនុវត្តច្បាប់ស្តីពី **ការសម្ងាត់ពាណិជ្ជកម្ម** នៅពេលនេះដែរ ឬទេ? ជាពិសេស ចំពោះផលិតផលឱសថ ដែលទាមទារឲ្យមានការអនុញ្ញាតដើម្បីដាក់លក់នៅលើទីផ្សារ។ នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ អង្គការពាណិជ្ជកម្មពិភពលោកបានយល់ព្រមថា រាល់សមាជិកនៃប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចទាំងអស់នឹងមិនត្រូវបានតម្រូវអោយអនុវត្តបទប្បញ្ញត្តិទាំងអស់នៃកិច្ចព្រមព្រៀងនេះ លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៣ ដល់មាត្រា ៥ រហូតដល់ថ្ងៃទី ១ កក្កដា ២០១៣ ឬរហូតដល់ប្រទេសទាំងនេះលែងជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចទៀត។

មាត្រា ៣ ដល់មាត្រា ៥ នេះ និយាយពីគោលការណ៍ប្រព្រឹត្តកម្មជាតិ និងលក្ខន្តិកៈដែលទទួលបាននូវភាពអនុគ្រោះជាងគេ ហើយមិនចាំបាច់តម្រូវអោយមានការអនុវត្តមាត្រា ៣៩ឡើយ។ សេចក្តីសម្រេចនេះ ក៏បញ្ជាក់ផងដែរ នូវការបន្តសិទ្ធិរបស់សមាជិកនៃប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ដើម្បីពន្យាពេលអនុវត្តកាតព្វកិច្ច ដូចដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៦៦ នៃកិច្ចព្រមព្រៀង TRIPS។ កម្ពុជាដែលជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច មិនទាន់មានកាតព្វកិច្ចត្រូវអនុម័តច្បាប់ ដើម្បីអនុវត្តមាត្រា ៣៩ នៅឡើយទេ។ គេអាចនិយាយថា សមាជិកភាពរបស់កម្ពុជាទាមទារតែការអនុម័តច្បាប់ដែលការពារតែព័ត៌មានដែលមិនអាចផ្សព្វផ្សាយបាន (ការសម្ងាត់ពាណិជ្ជកម្ម) និងប្រកាសនីយបត្រតក្កកម្មប៉ុណ្ណោះ។ នោះមានន័យថា ការពន្យាពេលនៃការអនុវត្តប្រកាសនីយបត្រតក្កកម្មឱសថរហូតដល់ឆ្នាំ ២០១៦ ក៏មិនស្របផងដែរជាមួយនឹងលក្ខខណ្ឌចូលជាសមាជិករបស់កម្ពុជា ពីព្រោះក្នុងរបាយការណ៍នៃក្រុមការងារ និងឯកសារចូលជាសមាជិកក៏មិនបានចែងអំពីការពន្យាពេលនេះដែរ។ ការអះអាងនេះមិនមានយោងទៅដល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា TRIPS ឆ្នាំ ២០០៥ ដែលមានក្រោយកម្ពុជាចូលជាសមាជិកបាន ២ឆ្នាំ។ មើលទៅគេគួរពិចារណាទៅលើការពន្យាពេលការអនុវត្តកាតព្វកិច្ចនេះ ទៅឲ្យប្រទេសណាមួយជាក់លាក់ ហើយមិនគួរឲ្យទៅក្រុមប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចនោះទេ។ គេក៏មិនបានលើកលែងនូវសេចក្តីសម្រេចមិនបញ្ចូលសមាជិកថ្មី ដូចជាកម្ពុជាជាដើម ចេញពីការពន្យាដល់ឆ្នាំ ២០១៣ នោះទេ ហើយកម្ពុជាក៏មានកាតព្វកិច្ចផងដែរក្នុងការបង្កើតច្បាប់អនុវត្តមាត្រា ៣៩ អោយបានមុនពេលការពន្យានេះ ដូចជាប្រទេសដែលមានការអភិវឌ្ឍន៍ដទៃទៀតដែរ។

លើកលែងតែប្រទេសដែលមានចែងនៅក្នុងកថាខណ្ឌទី ២២៤ នៃរបាយការណ៍ក្រុមការងារអំណះអំណាងដែលកម្ពុជាមិនអាចអនុវត្តការពន្យាពេលនេះបាន ដែលមានចែងនៅក្នុងកថាខណ្ឌទី ៣ នៃពិធីសារស្តីពី ការចូលជាសមាជិករបស់រដ្ឋ កាតព្វកិច្ចនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី ដែលមានគោលដៅដើម្បីដាក់អោយអនុវត្តក្នុងរយៈពេលមួយជាកំណត់នឹងត្រូវបានអនុវត្តដោយកម្ពុជា បើទោះបីជាកម្ពុជាបានទទួលស្គាល់កិច្ចព្រមព្រៀងនោះនៅថ្ងៃចូលជាធរមាននៃកិច្ចព្រមព្រៀងនោះក៏ដោយ។ កម្ពុជាអាចធ្វើការពន្យាពេលអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន ប្រសិនបើកម្ពុជាជាសមាជិកដើម ហើយកម្ពុជាក៏អាចទាញប្រយោជន៍ដោយខ្លួនឯងពីការផ្តល់សិទ្ធិពន្យាពេលអនុវត្តនេះដែរ។ ប្រសិនបើ កម្ពុជាបដិសេធនឹងការផ្តល់សិទ្ធិនេះ កម្ពុជានឹងត្រូវអនុវត្តតាមរបាយការណ៍ក្រុមការងារ។ ជាពិសេស នេះគឺជាករណីមួយ តាំងពីការចូលជាសមាជិករបស់កម្ពុជា បានធ្វើឡើងខណៈពេលជាមួយគ្នានឹងសេចក្តីសម្រេចពាក់ព័ន្ធជាមួយកថាខណ្ឌទី ៦ នៃសេចក្តីប្រកាសទីក្រុង ដូហា ស្តីពីសុខភាពសាធារណៈ ត្រូវបានធ្វើឡើងនៅឯកិច្ចប្រជុំរដ្ឋមន្រ្តី Cancun។ ម៉្យាងវិញទៀត ពិធីសារស្តីពីការចូលជាសមាជិករបស់កម្ពុជា បានតម្រូវយ៉ាងច្បាស់លាស់ពីការអនុវត្តន៍លក្ខខណ្ឌរបស់ TRIPS នៅក្នុងរយៈពេលកំណត់មួយនៅក្នុងរបាយការណ៍ក្រុមការងារ និងផែនការសកម្មភាពដែលត្រូវអនុវត្តចាប់ពីថ្ងៃទី ១ មករា ២០០៦ (បានពន្យារួចហើយដល់ថ្ងៃទី ១ មករា ២០០៧)។

ទាំងនេះគឺជាហេតុផលដែលចេញពីការអនុវត្តន៍ ជាហេតុដែលកម្ពុជាគួរតែពន្យាពេលការអនុវត្តន៍មាត្រា ៣៩ ប្រសិនបើកម្ពុជាមានឱកាសក្នុងការពន្យាពេលនេះ។ របាយការណ៍សង្ខេបមួយរបស់ Oxfam នាពេលថ្មីៗនេះ ដែលនិយាយពីការអនុវត្តន៍សិទ្ធិផ្តាច់មុខលើទិន្នន័យនៅប្រទេស Jordan បានធ្វើសេចក្តីសន្និដ្ឋានថា តម្លៃឱសថបានកើនដល់ ២០% ចាប់តាំងពីមានការអនុវត្តលក្ខខណ្ឌរបស់ TRIPS នៅឆ្នាំ ២០០១ មក។ មានសេចក្តីរបាយការណ៍មកថា ឱសថដែលមានតម្លៃងថ្លៃ កំពុងគម្រាមកំហែងដល់ការជួយទ្រទ្រង់កម្មវិធីសុខភាពសាធារណៈរបស់រាជរដ្ឋាភិបាល។ Oxfam បានធ្វើសំណើថា សិទ្ធិផ្តាច់មុខលើទិន្នន័យ ជាកត្តាមួយនៅក្នុងបញ្ហានេះ ដោយអះអាងថា ក្រុមហ៊ុនឱសថភាគច្រើន មិនខ្វាយខ្វល់នឹងការដាក់ពាក្យសុំចុះបញ្ជី សម្រាប់ការពារប្រកាសនីយបត្រតក្កកម្មទេ ផ្ទុយទៅវិញដោយផ្អែកលើវិធាន TRIPS-Plus ជាពិសេសសិទ្ធិផ្តាច់មុខលើទិន្នន័យ គេសុំកិច្ចការពារនូវការប្រកួតប្រជែងតាមប្រភេទសម្រាប់ឱសងមួយចំនួនទៅវិញ។ គេមិនដឹងច្បាស់ទេថាតើ Oxfam បានធ្វើការសិក្សាហ្មត់ចត់បានប៉ុណ្ណា ហើយក៏គេមិនដឹងច្បាស់អំពីចំនួនដែលគេមិនអាចប៉ាន់ស្មានបានត្រឹមត្រូវដែរ។ ប៉ុន្តែនេះបង្ហាញឲ្យឃើញពីការប្រយ័ត្នប្រយែងដែលកម្ពុជាត្រូវប្រមើលនៅពេលដែលមានការអនុវត្តន៍មាត្រា ៣៩.៣ របស់ TRIPS។

រហូតមកដល់ពេលនេះ មិនមានហេតុផលចម្បងណាមួយទេ ថាតើហេតុអ្វីបានជាកម្ពុជាត្រូវបានអនុគ្រោះដោយខុសពីបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចដទៃទៀត។ មកដល់ពេលនេះ ប្រទេសកម្ពុជាបានចេញជាសេចក្តីព្រាងច្បាប់ស្តីពី ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្មដែលអនុញ្ញាតអោយកម្ពុជាទាញផលប្រយោជន៍ពីការពន្យាពេលនេះ។ នេះគឺជាសញ្ញាវិជ្ជមានមួយបង្ហាញឲ្យឃើញថា កម្ពុជានឹងអាចមានច្បាប់មួយនេះ ក្នុងរយៈពេលឆាប់ៗខាងមុខនេះ។ ហេតុដូច

នេះហើយ ដើម្បីឲ្យកម្ពុជា មានច្បាប់មួយដ៏ល្អប្រសើរសម្រាប់អនុវត្តន៍ កម្ពុជាគួរធ្វើការពិចារណារលើអនុសាសន៍ទៅលើសេចក្តីព្រាងច្បាប់របស់ខ្លួន ដូចខាងក្រោមនេះ៖

***ទីមួយ*** កម្ពុជាគួរតែរៀបចំស្នើសុំនូវការពន្យាពេលបន្ថែមទៀត ដើម្បីសិក្សាបន្ថែមទៅលើមាត្រា ៣៩ នៃ TRIPS ពីព្រោះកម្ពុជាមានភាពទន់ខ្សោយនៅឡើយក្នុងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា។ បើទោះបីជាយ៉ាងនេះក្តី កម្ពុជាក៏ពុំគួរមើលរំលង ពីការរៀបចំច្បាប់ស្តីពី ការសម្ងាត់ពាណិជ្ជកម្មនេះឡើយ។

***ទីពីរ*** ចំពោះការធ្វើសេចក្តីព្រៀងច្បាប់នេះ កម្ពុជាគួរគប្បីណាស់ជួលអ្នកជំនាញក្នុងការធ្វើសេចក្តីព្រាងច្បាប់នេះ ព្រោះថាច្បាប់នេះ នឹងមានការជះឥទ្ធិពលយ៉ាងខ្លាំងទៅវិស័យសេដ្ឋកិច្ចរបស់កម្ពុជានាពេលអនាគត។ បន្ថែមពីលើនេះទៀត ក្នុងច្បាប់នេះ កម្ពុជាពុំគួររំលងនូវទោសបញ្ញត្តិព្រហ្មទណ្ឌជាដាច់ខាត ព្រោះថាកាលណាបើការបំពានកើតហើយគ្មានទោសពិន័យជាទោសព្រហ្មទណ្ឌទេ នាំឲ្យបុគ្គលនោះមិនមានការរៀងចាលនោះឡើយ ហើយនាំឲ្យការរំលោភបំពានច្បាប់នេះកាន់តែកើតឡើង។

***ទីបី*** ចំណែកឯខាងវិស័យឪសថវិញ បើទោះបីជាប្រទេសកម្ពុជាត្រូវបានធ្វើការអនុគ្រោះក្តីក៏កម្ពុជាគួរតែមានវិធានការណ៍ទៅលើបញ្ហានេះ ព្រោះថាតម្លៃឪសថអាចនឹងមានការកើនឡើងយ៉ាងខ្លាំងនៅពេលដែលប្រទេសកម្ពុជាលែងមាននូវការអនុគ្រោះ។ ទោះបីជាយ៉ាងនេះក្តី កម្ពុជាពុំគួរមើលរំលងពីបច្ចុប្បន្នភាពទេ ព្រោះថា ឪសថដែលគ្មានការអនុញ្ញាត្តិត្រឹមត្រូវមួយចំនួន គឺបានធ្វើចរាចរនៅពេញប្រទេស ដែលវាមានការគំរាមកំហែងយ៉ាងខ្លាំងដល់សុខមាលភាពសាធារណៈរបស់ប្រជាជន។

យើងខ្ញុំសង្ឃឹមថា កម្ពុជានឹងធ្វើការពិចារណាទៅលើចំនុចខាងលើនេះ ហើយនឹងបង្កើតការការពារការសម្ងាត់ពាណិជ្ជកម្មនៅក្នុងប្រទេសខ្លួន អោយបានល្អប្រសើរ បន្ទាប់ពីយល់ព្រមអនុវត្តមាត្រា ៣៩ នៃកិច្ចព្រមព្រៀង TRIPS អោយបានឆាប់ដែលអាចធ្វើបាន ដើម្បីទាក់ទាញវិនិយោគក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។